ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-May-2017, 11:09
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៦២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី

*(Ms. Maddalena Ghezzi)*

កញ្ញា ជា ស៊ីវហ៊ាង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉ើន ពៅ

លោក គឹម ម៉េងឃី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក សួន វិសាល | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ញ៉ែម សំណាង (មន្ត្រីគាំពារសាក្សី) | ខ្មែរ |
| លោក ស្វូត្រ សាំង (2-TCCP-304) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក សុក្រ សាំង** (2-TCCP-304)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................... ទំព័រ ៣
សួរដោយលោក គឹម ម៉េងឃី ផ្តើមពី....................................................... ទំព័រ ៦
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................................................... ទំព័រ ១៣
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................................................... ទំព័រ ៥១
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................................... ទំព័រ ៥៥
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................................... ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះ នឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-304 ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគីតាមរយៈអ៊ីម៉ែលរបស់មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងកាលពីរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ រួចហើយ។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៉ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-304។ សូមអរគុណលោកប្រធាន។

[០៩:០៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ៉ង។

បាទ ជាដំបូងនេះ អង្គជំនុំសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៤

ខែមីនា ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលនៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៧:៤៥]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មិនមានការប្រែប្រួលទេ ប៉ុន្តែគាត់ឈឺចង្កេះរ៉ាំរ៉ៃ វិលមុខ ពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ យល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាករនេះ។

បង្គាប់ឲ្យផ្នែក បុគ្គលិកផ្នែកសោទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-304 ដែលបានកំណត់កាលបរិច្ឆេទធ្វើសវនាការនៅថ្ងៃនេះ និងនៅព្រឹកថ្ងៃស្អែក អង្គជំនុំជម្រះនឹងអនុវត្តតាមសេចក្តីសម្រេចលើវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ តាមខ្លឹមសារនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ឯកសារE316/2/2 ដែលអង្គជំនុំជម្រះបង្គាប់ថា រូបភាពនិងសំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនត្រូវផ្សព្វផ្សាយជាសាធារណៈទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបង្គាប់ឲ្យបុគ្គលិគ្រប់គ្រងខាងផ្នែកបច្ចេកទេសសំឡេងនិងរូបភាពនៅក្នុងសាលសវនាការនេះ ឲ្យបំប្លែងរូបភាពផ្ទៃមុខ និងសំឡេងរបស់ដើមបណ្តឹងរដ្ឋ

ប្បវេណីរូបនេះក្នុងអំឡុងពេលគាត់ផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះនេះ។ ហើយព័ត៌មានលម្អិតពីសាវតារផ្ទាល់ខ្លួនដើមបណ្តឹងរូបនេះ ក៏ដូចជាទីកន្លែងកំណើត អាសយដ្ឋានបច្ចុប្បន្ន មុខរបរ ឈ្មោះសមាជិកក្នុងក្រុមគ្រួសារ ដើមបណ្តឹងក៏ត្រូវលាក់ជាការសម្ងាត់ផងដែរ។

ដោយមានបញ្ហាខាងបច្ចេកទេសបំប្លែងសំឡេងដើមបណ្តឹងរដ្ឋប្ប -- អង្គជំនុំជម្រះសាលាដំបូងចាត់បុគ្គលិកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញមួយរូប គឺលោក ញ៉ែម សំណាង ឱ្យអង្គុយនៅក្បែរដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជួយសម្របសម្រួលខាងបច្ចេកទេសបំប្លែងសំឡេងដល់ដើមបណ្តឹងរដ្ឋប្ប-វេណីរូបនេះនៅក្នុងអំឡុងពេលគាត់ផ្តល់សក្ខីកម្ម។

[០៩:១០:៤៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអ្វី? លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ?

*(សម្រាករយៈពេលខ្លី)*

លោកមិនទាន់ឆ្លើយ។ កុំអាលមើលអាហ្នឹង យើងសួរគាត់ គាត់ឆ្លើយនូវសំណួរ បញ្ហាសំណួរហ្នឹង យើងនឹងប្រាប់ឱ្យលោកធ្វើទៀត។ បន្តិចទៀតបានដល់ពេលលោកត្រូវរៀបចំធ្វើ។

អ៊ីចឹងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយនឹងសំណួរ ដែលយើងសួរ តើលោកឈ្មោះអី?

**លោក សូត្រ សាំង៖**

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ សូត្រ សាំង។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកអាចចាំ ហើយប្រាប់អង្គជំនុំជម្រះបានដែរទេ ថ្ងៃខែឆ្នាំកំណើតរបស់លោក?

**ឆ៖** ខ្ញុំបាទកើតនៅក្នុងឆ្នាំ១៩៥៧។

**ស៖** បាទ អរគុណ ហើយតើលោកចេះអក្សរខ្មែរដែរឬទេ? ចេះអាន ឬក៏ចេះសរសេរអក្សរខ្មែរដែរឬទេ?

**ឆ៖** ខ្ញុំបាទ អក្សរខ្មែរសម័យនោះ ខ្ញុំបាទមិនបានរៀនជ្រៅជ្រះ ឬមួយបានរៀនសាលាធំដុំទេ ខ្ញុំបាទដូចមិនចេះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ ដោយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនចេះអក្សរ។ អង្គជំនុំជម្រះចាត់លោក ញ៉ែម សំណាង ជាបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញឲ្យជួយអាននូវសំណួរចម្លើយជម្រាបប្រាប់គាត់តិចៗ និងគូសនូវចម្លើយតបឲ្យចំនៅក្នុងកូឡោននៅពីខាងក្រោយពាក្យចម្លើយត្រូវ ឬក៏ខុសនៅក្នុងឯកសារនេះ។ លោក ញ៉ែម សំណាង មានសំណួរ-ចម្លើយហើយឬនៅ?

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក សំណាង ចាត់ការអានឲ្យគាត់ស្ដាប់ទៅ ហើយឲ្យគាត់គូស ឬក៏លោកអាចគូសបញ្ជាក់ប្រាប់ជំនួសគាត់ក៏បាននៅចម្លើយដែលឆ្លើយតបមានប្រាំសំណួរ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីផងដែរថា សំណួរដែលអង្គជំនុំជម្រះសួរហ្នឹង គឺទីកន្លែងកំណើតរបស់លោក តើកើតនៅទីកន្លែងណា? សំណួរទី២ តើទីលំនៅសព្វថ្ងៃរបស់លោកនៅទីកន្លែងណា? ហើយសំណួរទី៣ តើលោកប្រកបមុខរបរធ្វើអ្វីដែរសព្វថ្ងៃនេះ? ទី៤ តើឪពុករបស់លោកឈ្មោះអី ហើយម្ដាយរបស់លោក គាត់ឈ្មោះអីដែរ? ហើយនិងសំណួរទី៥ ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់? នេះជាប្រភេទសំណួរដែលពាក់ព័ន្ធនឹងការបញ្ជាក់សារតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

តិចៗ ខ្សឹបៗទៅបានហើយ ឲ្យគាត់ ស្មើនឹងគាត់អានហ្នឹង ហើយគាត់ឯកភាពទេថាហ្នឹងត្រឹមត្រូវទេ បើត្រូវដាក់ត្រូវ បើខុសដាក់គូសខុសមកណ៎ះ! ដើម្បីយើងសួរបញ្ជាក់បន្ថែមទៀតក្នុងករណីខុស។

*(សម្រាករយៈពេលខ្លី)*

[០៩:១៥:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ ឆ្លៀតក្នុងឱកាសដែលដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែពិនិត្យទៅលើសំណួររបស់លោកប្រធាន ខ្ញុំសូមមានយោបល់ខ្លីមួយ ទាក់ទងទៅនឹងរបាំងដែលដាក់នេះ ខ្ញុំឃើញដូចវាខ្ពស់ពេក។ បើសិនជាលោកប្រធានអាចរកទាបបន្តិចមក កុំឲ្យវាបាំងដល់ចៅក្រមដែលពីៗខាង*អ័រឌាន*នោះក៏មើល អាច

មានអារម្មណ៍ថាទើស ដោយសារបាំងទាំងអស់នេះបាទ។ ហើយទី២ នៅក្រោមពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួរចម្លើយនេះ សូមលោកប្រធានអនុញ្ញាតឲ្យភាគីបានពិនិត្យផងបាទ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយទី១ ទំនងជាអាចបញ្ជាក់បាននាពេលនេះ ហើយគឺមិនមានរបាំងផ្សេងទេ របាំងដែលយើងត្រៀម គឺមានតែមួយឈុតមួយនេះទេ ដែលយើងអនុវត្ត ហើយជាការចាប់ផ្តើម យើងត្រៀមយូរហើយតាំងពីសំណុំរឿង០០១មក ប៉ុន្តែថាយើងនឹងប្រើប្រាស់នៅពេលនេះទេ ជាការចាប់ផ្តើម ហើយបើសិនជាមានយោបល់ដូច្នេះ អង្គជំនុំជម្រះនឹងពិនិត្យលទ្ធភាពថាតើគួរធ្វើការកែប្រែយ៉ាងម៉េចនាពេលខាងមុខ។

បាទទី២ ហើយមន្ត្រីរដ្ឋបាលតុលាការទទួលនូវសំណួរចម្លើយពីមន្ត្រី -- ពីបុគ្គលិកគាំពារសាក្សីអ្នកជំនាញ យកមកឲ្យយើង។

នេះមន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារនេះ ទៅជូនមេធាវីការពារក្តីពិនិត្យ មុននឹងដាក់បញ្ចូលទៅក្នុងសំណុំរឿង។

[០៩:១៧:២៧]

លោកដើមបណ្តឹងរដ្ឋប្បវេណី ជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោក ក្នុងនាមជាលោកជាដើមបណ្តឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ នេះជាសិទ្ធិរបស់លោក ដែលអង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យលោកនៅពេលចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់លោក។ ហើយដោយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលកន្លះថ្ងៃ និងមួយវគ្គសវនាការនៅរសៀលនេះ នៅក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញសហមេធាវីនាំមុខងតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតផ្តល់វេទិកានេះជូនលោកមេធាវី គឹម ម៉េងឃី ដើម្បីសួរសំណួរ លោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គឹម ម៉េងឃី៖**

បាទសូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ ខ្ញុំបាទ គឹម ម៉េងឃី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-304 នៅថ្ងៃនេះ ខ្ញុំសូមតាំងសំណួរមួយចំនួនទៅកាន់លោកដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម។

**ស៖** បាទជម្រាបសួរលោកពូ! សំណួរទី១ដែលខ្ញុំសួរទៅកាន់លោកពូ សួរថាតើនៅក្នុងមុនៗថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹង លោកពូធ្វើអី? នៅទីណាដែរ?

**លោក សូត្រ សាំង៖**

**ឆ៖** ខ្ញុំបាទក្នុងឆ្នាំ១៩៧៥ ខ្ញុំបាទនៅទ័ពការពារនៅតាកែវ។

**ស៖** លោកពូអាចបញ្ជាក់អំពីអង្គភាពទ័ពហ្នឹងបានទេ? ហើយលោកពូចូលហ្នឹងដោយការស្ម័គ្រចិត្ត ឬក៏ដោយលក្ខខណ្ឌអីផ្សេង?

[០៩:២០:០០]

**ឆ៖** ខ្ញុំបាទក្នុងសម័យនោះ គឺមិនមែនចូលទៅតាមស្ម័គ្រចិត្តទេ គឺមានគេអ្នកបង្ខំពីក្រោយដើម្បីចូលនៅក្នុងកងយុវជន មិនឱ្យនៅក្នុងតាមភូមិ តាមឪពុកម្តាយទេ។

**ស៖** បាទ សូមអរគុណ។ នៅ -- លោកពូអាចរៀបរាប់បានទេអំពីការងារដែលនៅក្នុងអំឡុងពេលដែលលោកពូជាកងយុវជនហ្នឹង ថាតើគេឱ្យធ្វើអីខ្លះ?

**ឆ៖** ខ្ញុំបាទនៅក្នុងកងយុវជនក្នុងសម័យនោះជាដើមដំបូងបំផុតគេឱ្យរែកទំនប់ ជីកប្រឡាយ។

**ស៖** បាទ អរគុណ។ ចុះបន្ទាប់មកទៀត លោកពូអាចរៀបរាប់ជាទូទៅបានទេថា តើលោកពូធ្វើអី? នៅទីណាទៅតាមកាលបរិច្ឆេទដែលលោកពូអាចចាំបាន?

**ឆ៖** ក្នុងសម័យនោះ ខ្ញុំបាទរែកទំនប់ដូចនៅក្នុងខ្ពបត្របែក។ នេះជាជាក់ស្តែងនៅទំនប់ហ្នឹងគឺទំនប់នៅប្រើប្រាស់នៅឡើយ។ ប្រឡាយនៅក្នុងប្រឡាយ ប្រឡាយគេហៅប្រឡាយស្វន្យប៉ុន្មានខ្ញុំមិនបានចាំទេ នៅក្នុងប្រឡាយពីខ្ពបត្របែកមកត្រពាំងគល់នេះ។

**ស៖** ចុះ អត់ទោសលោកពូ សូមលោកពូជួយបញ្ជាក់រឿងហេតុហ្នឹងជាបន្តបន្ទាប់មកថា ថាតើ

រាប់ចប់ពីការងារហ្នឹងទៅ លោកពូទៅធ្វើអី? នៅឆ្នាំ ប្រហែលជាឆ្នាំប៉ុន្មាន? ពីកន្លែងណា? តួនាទីអី? លោកពូអាចរៀបរាប់អង្គហេតុហ្នឹងដើម្បីខ្ញុំសួរបញ្ជាក់បន្ថែមពីរឿងហ្នឹង។ លោកពូអាចរៀបរាប់បានទេ?

**ឆ៖** ខ្ញុំបាទ កាលពីសម័យនោះ ក្នុងឆ្នាំចិត ខ្ញុំសុំទាញខាងដើមមកឆ្នាំខាងដើមខាងឆ្នាំ៧១ គឺខ្ញុំមិនទាន់បានចេញពីក្រុមគ្រួសារឪពុកម្ដាយនៅឡើយទេ។ ក្នុងឆ្នាំ៧១-៧២ ឪពុកខ្ញុំបាទគេយកទៅដាក់ទោសនៅមន្ទីរ២០៤ រហូតដល់ឆ្នាំ៧២ៗ ៧៣ ខ្ញុំបាទបានចូលក្នុងកងទ័ព។ ៧៣ ក្រោយ៧៣ រហូតមកដល់ឆ្នាំ៧៥, ៧៦ ខ្ញុំនៅក្នុងជួរកងទ័ពរហូតមក។ លុះដល់ក្នុងឆ្នាំ១៩៧៥ នៅក្នុងជួរកងទ័ពដដែល តែគេឲ្យខ្ញុំទៅការពារនៅភ្នំដំរីរមៀល។ ទៅការពារនៅក្នុងភ្នំដំរីរមៀលនេះ មូលហេតុគេឲ្យទៅចាប់តា ព្រុំ សាន់ ប៉ុន្តែមិនដឹងតា ព្រុំ សាន់ ហ្នឹងឈ្មោះមុខយ៉ាងម៉េច ខ្ញុំក៏មិនស្គាល់គាត់ដែរ គេឲ្យទៅការពារនៅចាំចាប់តា ព្រុំ សាន់ ហ្នឹង។ គេចោទតា ព្រុំ សាន់ ហ្នឹង – តា ព្រុំ សាន់ ក្បត់។ ខ្ញុំក៏ធ្វើតាមបញ្ជា បានទៅនោះរហូតដល់ឆ្នាំ៧៧។ ៧៧ ខ្ញុំបាទបានគេ អ៊ំ! ក្នុងឆ្នាំ៧០ ក្នុងឆ្នាំ៧៥ហ្នឹង ៧៥ហ្នឹងគេលួចអាវុធខ្ញុំក្នុងកងទ័ពឲ្យការពារ ព្រុំ សាន់ ហ្នឹង គេលួចអាវុធបាន គេចោទខ្ញុំយកទៅ ថាអាវុធយកទៅឲ្យ ព្រុំ សាន់ នៅកន្លែងណា ឬមួយគេថាយក ព្រុំ សាន់ ហ្នឹងនៅក្រោមដើមក្រឡាញ់ នៅពាំងតាសុក។ ខ្ញុំអាវុធនោះគឺគេអ្នកដើររុងល្បាតហ្នឹង គេអ្នកយក។ កាលហ្នឹងខ្ញុំមានជំងឺគ្រុនចាញ់ជាទំងន់។ ក្រោយមកក៏បានគេយកខ្ញុំអប់រំនៅក្នុងកន្លែងចម្ការដូង យុវជន –គេហៅកន្លែងយុវជន– អប់រំខ្ញុំ រយៈពេល១ថ្ងៃរសៀលហ្នឹង ខ្ញុំបាទក៏បានគេណែនាំធ្វើម៉េចយើងក្បត់ពីបក្ស ក្បត់កងទ័ព។ ខ្ញុំហ្នឹងក៏គេឲ្យនៅរស់នៅជាមួយកងទ័ពនៅត្រពាំងលាន ហ្នឹងរហូតទៅដល់ឆ្នាំ៧៦។ ៧៧ គេឲ្យខ្ញុំមកក្រាំងតាចាន់នេះ។

[០៩:២៥:៥០]

**ស៖** បាទ សូមអរគុណលោកពូ។ ខ្ញុំវិលទៅចំណុចមួយដែលលោកពូបានបញ្ជាក់អំពីឈ្មោះ ព្រុំ សាន់ តើគាត់ –ព្រុំ សាន់– ហ្នឹង លោកពូស្គាល់ទេ គាត់ជានរណា? តើចាប់គាត់ពីរឿងអី? ហើយចាប់បានដែរឬទេ នៅពេលនោះ?

**ឆ៖** ខ្ញុំបាទ ព្រុំ សាន់ នេះ ខ្ញុំអត់ដែលស្គាល់គាត់ទេសម័យនោះ។ សម័យដែលរដ្ឋ -- សម័យបដិវត្តន៍ហ្នឹងខ្ញុំអត់ដែលស្គាល់គាត់ ពីព្រោះមិនដែលស្គាល់ ពីព្រោះគាត់នៅឯត្រាំកក់ ហើយខ្ញុំនៅឃុំលាយបូរនេះ ខ្ញុំអត់ដែលស្គាល់គាត់ទេ។ ទើបតែបានសម័យរំដោះ៧៩ ហើយនេះ គាត់ធ្វើប្រធានឃុំ នៅត្រាំកក់ហ្នឹងបានស្គាល់គាត់។ ប៉ុនក្នុងបច្ចុប្បន្នក្រោយមកហ្នឹង គាត់បានស្លាប់ទៅហើយ។ គាត់ស្លាប់នៅក្នុងឃុំត្រាំកក់យើងនេះ សព្វថ្ងៃនេះ។

**ស៖** បាទ សូមអរគុណលោកពូ។ បន្ទាប់មកទៀត លោកពូបានរៀបរាប់ពីអង្គហេតុមួយដែលលោកពូទៅចាប់ ហើយបានធ្វើឲ្យបាត់កាំភ្លើង គេយកទៅអប់រំ។ តើ-- ហើយបន្ទាប់មកទៀតបានលោកពូទៅក្រាំងតាចាន់ តើរឿងហ្នឹងយ៉ាងម៉េចបានគេបញ្ជូនទៅក្រាំងតាចាន់ គេអប់រំយ៉ាងម៉េច លោកពូអាចពន្យល់កន្លែងហ្នឹងបានទេ?

**ឆ៖** បាទ កាលពីខ្ញុំគេលួចកាំភ្លើងបាត់ក្នុងសម័យនោះ ដោយសារខ្ញុំមានគ្រុនចាញ់នៅក្នុងត្រង់សេមួយហ្នឹងគឺមានបីនាក់។ មានបីនាក់ហ្នឹង ពីរនាក់គេធានាខុសត្រូវថាឲ្យខ្ញុំនេះចូលសម្រាកនៅក្នុងត្រង់សេ គេនឹងការពារអាវុធខ្ញុំបាទទុកនៅលើគម្របត្រង់សេពីលើហ្នឹង។ ដល់ក្រោយមកបានគេយកបាត់ទៅបានគេយកខ្ញុំទៅអប់រំនៅកន្លែងយុវជនចម្ការដូងហ្នឹង គេយកទៅរយៈពេលមួយរសៀលហ្នឹង ដល់ហើយបានគេឲ្យខ្ញុំនៅកន្លែងអប់រំនៅកន្លែងទ័ពហ្នឹងរហូតមក។ បានក្រោយមកហ្នឹង មិនដឹងគេយ៉ាងម៉េចឲ្យខ្ញុំមកនៅក្រាំងតាចាន់នេះ ខ្ញុំក៏មិនដឹងមូលហេតុដែរ។ ក្រោយមកបានគេឲ្យខ្ញុំការពារនៅក្រាំងតាចាន់ហ្នឹងតែម្តង។

[០៩:២៨:៤៣]

**ស៖** ដូច្នេះ នៅពេលដែលលោកពូមកដល់ក្រាំងតាចាន់ តួនាទីរបស់លោកពូជាអ្នកការពារគុកក្រាំងតាចាន់ហ្នឹងមែនទេ លោកពូ?

**ឆ៖** បាទ មកដល់ក្រាំងតាចាន់នេះ មិនទាន់បានគេឲ្យចូលមកភ្លាមទេ។ មុននឹងគេឲ្យចូលមកក្រាំងតាចាន់ គេយកខ្ញុំបាទហ្នឹងយកទៅដាក់កងយុវជននៅ គេហៅ វត្តចាក់ជ្រុំ។ នៅវត្តចាក់ជ្រុំហ្នឹងបានប៉ុន្មានខែ ខ្ញុំមិនចាំទេ ក្រោយមកបានមកដល់ខែយើងស្ទូង គេហៅសម័យហ្នឹងគេហៅស្ទូងស្រូវ ក្រមួនស។ សម័យស្ទូងស្រូវក្រមួនស ហ្នឹងបានគេឲ្យខ្ញុំមកស្ទូង បានចូលរួមស្ទូងសម័យក្រមួនសហ្នឹង ខ្ញុំចូលស្ទូងជាមួយគេនៅក្នុងក្រាំងតាចាន់នេះ។

**ស៖** លោកពូថា មុន បន្ទាប់មកចូលដល់វត្តចាក់ជ្រុំ ហើយបានចូលមកស្ទូង ជាការងារជាអ្នកស្ទូងនៅក្រាំងតាចាន់។ តើមកនៅក្នុងនាមជាអ្នកទោស ឬក៏ជាបុគ្គលិកនៅមន្ទីរសន្តិសុខ ដូចគេហៅថាគុកក្រាំងតាចាន់ហ្នឹង?

[០៩:៣០:០០]

**ឆ៖** ខ្ញុំបាទមកដល់ដំបូង មុនដំបូងបំផុតគេបញ្ជូនមកហ្នឹងគេមិនមែនឲ្យមកតែខ្លួនទទេទេ គេឲ្យមកពីក្នុង នៅវត្តចាក់ជ្រុំហ្នឹង គេឲ្យខ្ញុំបាទមកហ្នឹងគឺមានយុវជនគេម្នាក់ដឹកនាំឲ្យខ្ញុំមកចូលនៅក្នុងកន្លែង

ក្រាំងតាចាន់នេះ។ មកដល់ហ្នឹងក៏ប្រគល់ឲ្យក្រាំងតាចាន់រួចហើយចប់សព្វគ្រប់ ខ្ញុំហ្នឹងក៏ខាងយោធា បញ្ជាការយោធានោះក៏គេប្រាប់ថាយើងមកដល់អាមួយគេហៅស្នាក់ការភូមិអីទេ ស្នាក់ការនៅភូមិចាន ទាបអី កាលហ្នឹងដូចចានទាបអីចឹងហើយ។ មកដល់ស្នាក់ការហ្នឹង បានបញ្ជាការគេឲ្យខ្ញុំថាឥឡូវយើង មានផែនការផ្លាស់ចេញពីវត្តចាក់ជ្រុំទៅនៅក្រាំងតាចាន់ ដើម្បីទៅនៅក្រាំងតាចាន់ហ្នឹងគេប្រាប់ថាលត់ដំ ខ្លួន កសាងខ្លួនឲ្យត្រឹមត្រូវ ឲ្យស្មោះត្រង់នឹងបក្ស។ ធ្វើម៉េចយើងប្រគល់ខ្លួនជូនបក្ស ឲ្យស្មោះត្រង់នឹង បក្សដើម្បីការពារបដិវត្តន៍ឲ្យខ្ពស់រុងរឿង។

**ស៖** បាទអរគុណលោកពូ។ ហើយដូចៗ បន្ទាប់មកលោកពូក្លាយទៅជាអ្នកដែលធ្វើការនៅៗ ក្រាំងតាចាន់តែម្តង បន្ទាប់ពីការប្តេជ្ញាថាធ្វើដើម្បីបក្សហ្នឹង។ អីចឹងមែនទេលោកពូ?

**ឆ៖** បាទ ក្នុងនោះដល់បន្ទាប់ពីគេបំពាក់បំប៉នអប់រំខ្ញុំរួចហើយ ខ្ញុំក៏ធ្វើតាមក្នុងបណ្តាំរបស់បក្ស របស់គេតែម្តង រហូតចិតសិប -- ៧៨ ខ្ញុំបានបញ្ជូនទៅទ័ពទៅវាយវៀតណាមវិញ។

**ស៖** លោកពូអាចបញ្ជាក់កាលបរិច្ឆេទម្តងទៀតបានទេ ថាតើនៅក្នុងចន្លោះពីឆ្នាំណាដល់ឆ្នាំណា ដែលលោកពូស្ថិតនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹង?

**ឆ៖** ក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង ខ្ញុំបាទបានចូលបម្រើក្នុងហ្នឹងតាំងពី ៧៧ ដល់ ៧៨ គេដកខ្ញុំទៅ ចូលនៅក្នុងកងពលវិញ នៅក្នុងកងពល២១០ ដើម្បីបញ្ចូលទៅក្នុងវាយវៀតណាម។

[០៩:៣៣:៥៧]

**ស៖** អរគុណ លោកពូ។ តើលោកពូអាចរៀបរាប់បានទេ នៅទីនោះគេឲ្យលោកពូធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំបាទនៅក្នុងក្រាំងតាចាន់នេះ ដំបូងបំផុតគេឲ្យខ្ញុំបាទហ្នឹង បំពាក់បំប៉នខាងផ្នែកមន្ទីរ។ មន្ទីរគេបំពាក់ -- ប្រធានមន្ទីរគេបំពាក់បំប៉នខ្ញុំបាទ ដើម្បីឲ្យខ្ញុំយាមធ្វើម៉េចការពារសុវត្ថិភាព សន្តិសុខ ក្នុងក្រាំងតាចាន់ធ្វើម៉េចឲ្យបាន អាហ្នឹងចំណុចទី១។ ទី២ គេឲ្យខ្ញុំបាទហ្នឹង ប្តេជ្ញាជាមួយថា បើសិនជា រួចអ្នកទោសម្នាក់ ឬបុគ្គលណាម្នាក់ ជីវិតយើងក៏អស់ក្នុងដំណាក់កាលនោះដែរ។

**ស៖** ការងារ -- ដូច្នេះលោកពូទទួលខុសត្រូវការងារពីរ ទី១គឺបំពាក់បំប៉ន ហើយនិងការការងារ ការពារអ្នកទោសមិនឲ្យលួចរត់។ អីចឹងមែនអីលោកពូ?

**ឆ៖** បាទ ខ្ញុំបានដល់ខាងមន្ទីរគេបំពាក់បំប៉នខ្ញុំៗក៏ធ្វើគោរពតាមផែនការរបស់គេ រហូតទាល់ៗ ខ្ញុំរត់ចេញ៧៨ ទៅទ័ពវិញម្ល៉េះ។

**ស៖** តមកទៀត លោកពូអាចបញ្ជាក់បានទេនៅក្នុង -- នៅពេលដែលលោកពូធ្វើការហ្នឹង តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅក្នុងមន្ទីរសន្តិសុខហ្នឹងមានប្រធាន មានអនុប្រធាន ឬក៏មានរចនាសម្ព័ន្ធគ្រប់គ្រងបែបម៉េចដែរ លោកពូអាចរៀបរាប់អំពីឈ្មោះ ហើយថាតើអ្នកណាទទួលខុសត្រូវអីក្នុងហ្នឹងលោកពូចាំទេបាទ?

**ឆ៖** ខ្ញុំបាទចាំខ្លះ ពីព្រោះពេលវេលាកាលហ្នឹងវាចូល៣០ឆ្នាំ ហើយមិនអាចចាំអស់ទេលោកគ្រូ ពីព្រោះក្នុងហ្នឹងប្រធានធំៗ ខ្ញុំចាំបានដូចជា តាអាន់ មួយ, តាពេញ, តាជ័យ អាហ្នឹងជាប្រធាននៅក្នុងក្រាំងតាចាន់នេះ។ ចំណែកខាងមន្ទីរ ពួកមន្ទីរផ្សេងទៀត អាហ្នឹងចាំមិនអស់ទេៗ ចាំតែ តាមឿន មួយ, តាឈៀង មួយ ហើយឯណាទៀតទេ អាហ្នឹងខាងមន្ទីរ ខ្ញុំចាំមិនអស់ទេ លោកគ្រូ។

**ស៖** អរគុណ។ លោកពូអាចរៀបរាប់បានទេជាទូទៅថាតើអ្នកទោសត្រូវបានចាប់ខ្លួននិងបញ្ជូនពីណាមក?

**ឆ៖** បើតាមខ្ញុំឃើញ ឬមួយខ្ញុំការពារនៅកន្លែងនោះ រឿងអ្នកទោសមិនមែនថាពួកមន្ទីរគេចុះទៅយកទេ វាមានតាមភូមិ តាមកង ពិសេសនៅតាមកង កងពិសេសរបស់គេតែម្តង។ កងពិសេសហ្នឹងមានកងពិសេសតាមឃុំ តាមស្រុក តាមតំបន់របស់គេក្នុងកន្លែងនោះ។ បើអ៊ីចឹងគេបញ្ជូនមកតាមរយៈតាមកងរបស់គេហ្នឹង គេបញ្ជូនមកឲ្យពួកមន្ទីរហ្នឹងគេចេញទៅទទួល។

[០៩:៣៨:០៩]

**ស៖** បាទ អរគុណ។ ដោយសារលោកពូធ្វើការជាអ្នកយាមកាមនៅទីនោះ ពេលដែលអ្នកទោសចូលតើមានការកត់ត្រា ឬក៏មានការថតរូប ឬក៏ធ្វើកំណត់ហេតុអីពាក់ព័ន្ធទៅនឹងការចូលរបស់អ្នកទោសហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបាទអត់មានបានកត់ត្រា ឬមួយថាកត់ទុកសម្តីប៉ុន្មាន ឬមួយអ្នកទោសប៉ុន្មាន បងប្អូនជនរងគ្រោះប៉ុន្មាន គឺខ្ញុំបាទអត់បានដឹងទេ។

**ស៖** តើពេលដែលអ្នកទោសចូលទៅដល់មន្ទីរសន្តិសុខនោះ ថាតើគេយកទៅឃុំខ្លួន ឬក៏គេយកទៅដាក់ ទុកដាក់យ៉ាងម៉េចដែរចំពោះអ្នកទោសនៅៗពេលដែលចូលទៅដល់ទីនោះលោកពូ?

**ឆ៖** បាទ អ្នកទោសទៅដល់ក្នុងមន្ទីរក្រាំងតាចាន់នោះ គឺគេយកទៅដាក់នៅក្នុងផ្ទះល្វែង ហើយគេដាក់ខ្នោះជើងទុកក្នុងនោះតែម្តង។

**ស៖** តើមានយកអ្នកទោសទៅធ្វើទារុណកម្ម សួរចម្លើយអីដែរឬទេនៅទីនោះ?

**ឆ៖** បាទ ក្នុងទីនោះគឺមានលោកគ្រូ គឺមាន អ្នកទោសសួរចម្លើយហ្នឹង គឺខាងមន្ទីរគេ គេអ្នកទទួល។

[០៩:៤០:១៤]

**ស៖** តើមានធ្វើទារុណកម្ម ឬក៏សម្លាប់អ្នកទោសនៅទីនោះដែរឬទេ លោកពូ?

**ឆ៖** ធ្វើទារុណកម្ម សួរចម្លើយ បាទ មាន។ មានសួរដូចជា វ៉ៃសួរចម្លើយ ឬមួយចងកំណាត់ផ្កាស្និកមុខបាទ។

**ស៖** ក្រៅពីវ៉ៃ ហើយនិងចងកំណាត់ តើមានមធ្យោបាយធ្វើទារុណកម្មផ្សេងទៀតដែរឬទេ ដែលលោកពូអាចដឹងបាននៅពេលនោះ?

**ឆ៖** បាទ ក្រៅពីនេះ ខ្ញុំបាទក៏មិនបានដឹងដែរ រឿងធ្វើទារុណកម្មក្រៅពីនេះ។ បន្តទៀត ខ្ញុំក៏មិនបាន ខ្ញុំដឹងតែប៉ុណ្ណោះទេ បាទ។

**ស៖** តើមានការដោះលែងអ្នកទោសឱ្យនៅចេញទៅក្រៅវិញដែរឬទេ? ឱ្យមានសេរីភាពដែរឬទេនៅពេលនោះ លោកពូ?

**ឆ៖** បាទមាន។ អ្នកទោសចេញមានសិទ្ធិសេរីភាពវិញ គឺគាត់បានចេញទៅរួមរស់ជាមួយឪពុកម្តាយ បងប្អូនគាត់ មានបាទ។

**ស៖** នៅពេលដែលលោកពូនៅទីនោះ លោកពូចាំបានទេថា តើចូលជាទូទៅប៉ុន្មាននាក់ក្នុង១ថ្ងៃ ហើយអ្នកដែលមានឱកាសចេញវិញបានប៉ុន្មាននាក់នៅក្នុងអំឡុងពេលនោះ?

[០៩:៤២:៣០]

**ឆ៖** ក្នុងចូល តាមខ្ញុំអ្នកយាមនៅខាងក្រៅនេះ មិនជាអចិន្ត្រៃយ៍លោកគ្រូ ជួនកាលមាន ជួនកាលអត់។ មិនប្រាកដថាចូលថ្ងៃណា ឱ្យចូលថ្ងៃណាៗ គឺមិនមានទេ។ វាដូចថា គេយកទៅតាមសហករណ៍ តាមកងចល័ត កងគេហ្នឹង មិនដឹងគេមាន -- ភាគច្រើនបើមុខសញ្ញារបស់ខ្ញុំពីខាងកើត គឺចូលបានពីរឬបី មិនជាអចិន្ត្រៃយ៍ទេ បាទ។

**ស៖** បាទ អរគុណ។ ចុះចំពោះអ្នកដែលចេញ ដែលត្រូវបានគេដោះលែង តើមានច្រើនដែរទេ ដែលត្រូវបានគេដោះលែងឱ្យរួចរស់មានជីវិតវិញ?

**ឆ៖** បាទ គឺបងប្អូនដែលរស់រានមានជីវិតវិញ មិនច្រើនទេ បាទ។

**ស៖** ពាក់ព័ន្ធទៅនឹងប្រភេទនៃអ្នកទោស តើមានអ្នកទោសដែលជាកូនក្មេង ឬក៏ទារកតូចៗដែរឬទេនៅទីនោះលោកពូ?

**ឆ៖** បាទ តាមខ្ញុំសង្កេតឃើញនៅក្នុងទីនោះ គឺកូនក្មេងតូចមានទៅតាមឪពុកម្តាយបាទ។

**ស៖** តើមានការបែងចែករវាងមន្ទីរឃុំកូនក្មេងផ្សេង ទោស -- អ្នកទោសដែលជាស្ត្រីផ្សេង ឬក៏បុរសផ្សេងទេ ឬក៏ដាក់នៅចូលជាមួយគ្នានៅពេលនោះ?

**ឆ៖** បាទ នៅក្នុងពេលនោះ គឺក្មេងនៅជាមួយឪពុកម្ដាយមិនថាបុរស មិនថាស្ត្រីទេ គឺរស់នៅជាមួយបាទ។

**ស៖** បាទ អរគុណលោកពូ។ ពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពអ្នកទោស ហើយនិងអនាម័យអ្នកទោស។ លោកពូអាចបញ្ជាក់បានទេថា តើមានការផ្ដល់ជាថ្នាំសង្កូវ ឬក៏មានការឲ្យ -- អនុញ្ញាតឲ្យអ្នកទោសសម្អាតខ្លួនជាទៀងទាត់ដែរឬទេ នៅពេលនោះ?

**ឆ៖** បាទ បើតាមខ្ញុំនៅខាងក្រៅនេះ គឺមិនបាន អ្នកទោសបងប្អូនដែលជាប់ពិរុទ្ធក្នុងនោះ គឺមិនមានបានថ្នាំសង្កូវ ឬមួយដុសលាងខ្លួន សម្អាតអនាម័យខ្លួនបានត្រឹមត្រូវទេបាទ។

**ស៖** បាទ អរគុណលោកពូ។ តើនៅក្នុងមន្ទីរសន្តិសុខនោះ លោកពូធ្លាប់ឮអំពីករណីធ្វើទារុណកម្ម ឬក៏ចាប់រំលោភលើអ្នកទោសដែលជាស្ត្រីនៅទីនោះដែរឬទេ?

**ឆ៖** បាទ ក្នុង -- បើតាមខ្ញុំសង្កេតក្នុងបុគ្គលិកក្នុងពួកមន្ទីរ ទាំងកងទ័ពក្នុងទីនោះ គឺគ្មានមានការរំលោភនារីនៅក្នុងនោះ ឬមួយធ្វើបាបនារីផ្លូវភេទ គឺគ្មានទេ។ បើចំណុចមានពី គេហៅថាពីខាងក្រៅ ដូចជា រំលោភសេពសន្ថវៈពីខាងក្រៅទៅ គេដឹកនាំមានវិបត្តិចូលទៅក្នុងហ្នឹង អាហ្នឹងគឺមានបាទ។

[០៩:៤៧:០០]

**ស៖** សូមទោសខ្ញុំសូមបញ្ជាក់បន្តិច។ លោកពូថា រំលោភពីខាងក្រៅ មានវិបត្តិយ៉ាងម៉េច ដឹកចូលទៅយ៉ាងម៉េច លោកពូអាចពន្យល់ពីសាច់រឿងហ្នឹងបន្តិចបានទេបាទ?

**ឆ៖** បាទ លោកគ្រូ ខ្ញុំចង់បញ្ជាក់ចំណុចត្រង់ហ្នឹង។ ឧទាហរណ៍ថា បងប្អូនគាត់ខូចសីលធម៌ពីកងផ្សេងៗនៅខាងក្រៅ ដូចជា កងយុវជន កងយុវនារី ខូចសីលធម៌ពីខាងក្រៅមក គេយកមកអប់រំក្នុងកន្លែងនោះ អាហ្នឹងគឺមានហើយបាទ។

**ស៖** បាទ អរគុណ។ ពាក់ព័ន្ធទៅនឹងបញ្ហាចំណីអាហារសម្រាប់អ្នកទោស ថាតើអ្នកទោសទទួលបានអាហារយ៉ាងម៉េចដែរ អ្នកដែល -- សម្រាប់អ្នកដែលត្រូវបានគេឃុំខ្លួននៅទីនោះ?

**ឆ៖** ក្នុងជីវភាពនៅក្នុងទីនោះ គឺបងប្អូនអ្នកទោសមិនបានអាហារគ្រប់គ្រាន់ទេបាទ។ មានបបរមានៗបបរលាយដំឡូងក៏មាន បបរទឹករាយក៏មាន អាហ្នឹងជាការពិតណាស់បាទ។

**ស៖** បាទ អរគុណលោកពូ។ ខ្ញុំអស់សំណួរពាក់ព័ន្ធទៅនឹងបញ្ហាគុកក្រាំងតាចាន់នេះហើយ។

សំណួរមួយចុងក្រោយ ទាក់ទងទៅនឹងថាមូលហេតុបានជានៅក្នុងឆ្នាំមួយពាន់-- លោកពូរៀបរាប់ថា ក្នុងឆ្នាំ១៩៧៨ហ្នឹង គេផ្លាស់ប្តូរលោកពូចេញពីហ្នឹងទៅចូលវ៉ៃវៀតណាម។

**ឆ៖** បាទ ក្នុងនោះ កាលពីក្នុងឆ្នាំ៧៨ គឺគេប្រមូលទ័ពទាំងអស់ ទាំងអម្បាលម៉ាន ទ័ពនៅកន្លែងណាក៏គេបញ្ចូលទៅក្នុងកងពលទៀត កងពលវ៉ៃវៀតណាមវិញដែរ បាទ។

**ស៖** លោកពូចង់មានន័យថា ប្រមូលដើម្បីទៅវ៉ៃប្រទេសវៀតណាម ឬក៏ប្រមូលដើម្បីទប់ទល់ទៅនឹងការវ៉ៃរបស់វៀតណាមចូលនៅក្នុងទឹកដីកម្ពុជា លោកពូអាចបញ្ជាក់កន្លែងហ្នឹងបាទទេ?

[០៩:៥០:00]

**ឆ៖** ក្នុងហ្នឹង ខ្ញុំមិនដឹង តើគេរៀបកងយ៉ាងម៉េចដែរ ប៉ុន្តែថាខ្ញុំកាលឆ្នាំ៧៨ហ្នឹង គេយកកងយករូបខ្ញុំហ្នឹងទៅបំពាក់ចូលកងពល១០២ហ្នឹងនៅ គេឲ្យរៀបចំវ៉ៃវៀតណាមដែលចូលមកទឹកដីខ្មែរបាទ។

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណលោកពូ។ ខ្ញុំមានសំណួរតែប៉ុណ្ណឹងទេ។ ហើយសូមអរគុណអង្គជំនុំជម្រះសាលាដំបូង ដែលបានអនុញ្ញាតឲ្យខ្ញុំបានសួរដើមបណ្តឹងនេះ នៅថ្ងៃនេះ។ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកប្រធាន សូមអរគុណមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អស់សំណួរហើយលោកប្រធាន។ អ៊ីចឹងសូមផ្តល់វេទិកាទៅឲ្យសហព្រះរាជអាជ្ញា លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរសំណួរដែលលោកទើបតែបានផ្តល់សក្ខីកម្មអម្បាញ់មិញនេះ។ លោកបាននិយាយថា លោកមិនបានឃើញការប្រព្រឹត្តមកលើអ្នកទោសស្រីនោះទេ ប៉ុន្តែអ្នកទោសខ្លះគឺថាត្រូវបានគេរំលោភរួចទៅហើយមុនយកមកមន្ទីរសន្តិសុខមួយនេះ។ ហើយ

ក្រោយមកលោកបានពន្យល់ថា "មនុស្សខ្លះបានប្រព្រឹត្តអំពើខុសសីលធម៌ ហេតុដូច្នេះឯងបានជាគេនាំខ្លួនយកមកមន្ទីរសន្តិសុខដើម្បីធ្វើការអប់រំកែប្រែ"។ ខ្ញុំចង់ឲ្យបញ្ជាក់បន្តិច តើលោកចង់មានន័យថាម៉េច ដែលថាស្ត្រីដែលត្រូវបានគេរំលោភហើយ ហើយត្រូវគេយកមកក្រាំងតាចាន់ក្នុងនាមជាអ្នកទោសដោយសារតែអ្នកទាំងនោះបានប្រព្រឹត្តខុសសីលធម៌។ សូមលោកបញ្ជាក់បន្តិច?

**លោក ស្វ្រត សាំង៖**

**ឆ៖** បាទ ក្នុងនោះខ្ញុំក៏មិនដឹងដែរ ប៉ុន្តែគ្រាន់នេះជា ខ្ញុំៗឃើញ។ ឃើញឧទាហរណ៍ដូចខាងបងប្អូនគាត់ខុសសីលធម៌ពីខាងក្រៅមក គេយកមកចូលក្នុងហ្នឹង ខ្ញុំក៏មិនដឹងដែររឿងហ្នឹង វាមិនដឹងគេគិតឃើញយ៉ាងម៉េច ឬមួយគេយល់ឃើញយ៉ាងម៉េចដែរ លោកប្រធាន ខ្ញុំអត់ទេរឿងនេះបាទ។

**ស៖** លោកបាននិយាយថា មានអ្នកទោសស្រីដែលត្រូវបានគេរំលោភនៅឯខាងក្រៅនោះរួចទៅហើយ មុននឹងគេនាំខ្លួនមកមន្ទីរសន្តិសុខ"។ តើលោកដឹងរឿងនេះដោយរបៀបណាដែរ?

**ឆ៖** បាទ លោកប្រធាន ក្នុងនោះគ្រាន់តែឧទាហរណ៍ថា ក្នុងចំណោមនៅក្នុងក្រាំងតាចាន់នោះ ដូចអ្នកខូចសីលធម៌ពីខាងក្រៅ គេមិនឲ្យចេញមកធ្វើការរែកដី រែកដី ឬមួយរែកដីដំបូក ធ្វើជីធម្មជាតិដាក់តាមស្រែ តាមនេះ ធ្វើការជាមួយខ្ញុំបាទហ្នឹង ខ្ញុំបាទចេះតែមានការសាកសួរ ឬមួយខ្ញុំសួរលេងសើចពីនេះ ពីនោះធម្មតា។ បានជាខ្ញុំបាទដឹងរឿងនេះបាទ។

[០៩:៥៤:០៥]

**ស៖** សូមអរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ខ្ញុំចង់សួរសំណួរខ្លះៗទាក់ទងទៅនឹងឋានៈតួនាទីរបស់លោកនៅក្នុងករណីនេះ។ សហចៅក្រមស៊ើបអង្កេតបានសម្ភាសលោកនៅថ្ងៃទី<២៨> ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយឆ្នាំក្រោយមកទៀតនៅក្នុងខែសីហា ឆ្នាំ២០០៨ ក៏បានសម្ភាសម្តងទៀត ក្រោយ<មកលោកត្រូវបាន>សហចៅក្រមស៊ើបអង្កេតសម្ភាសលោកក្នុងនាមជាសាក្សី ប៉ុន្តែលោកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សូមលោកជម្រាបជូនអង្គជំនុំជម្រះផង តើហេតុអ្វីបានជាលោកសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី?

**ឆ៖** បាទក្នុងនោះ ខ្ញុំបាទចង់ដឹងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺខ្ញុំបាទតាំងពីឪពុកខ្ញុំបាទ បងប្អូនខ្ញុំបាទ ដែលបានស្លាប់នៅក្នុងពេលនោះបាទ។

**ស៖** ខ្ញុំសូមសួរលោកអំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ សយ សែន ដែលបានឆ្លើយជូនតុលាការនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ គឺ E1/257.1 <ចាប់ពីម៉ោង ១១:២១:៥៥ ដល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

១១:២៤:២០> ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានឆ្លើយអំពីការទាក់ទងខ្លះៗដែលលោកទាក់ទងជាមួយនឹងគាត់។ ខ្ញុំសូមដកស្រង់៖ "សួរ៖ តើ សាំង ខ្លាចឬក៏អត់ទេ នៅពេលដែល<លោក>និយាយអំពីតួនាទីរបស់គាត់ ដែលគាត់បានធ្វើនៅឯក្រាំងតាចាន់<ប្រាប់ទៅអ្នកស៊ើបសង្កេត និងសវនាការ?> តើគាត់មានបាន<ប្រាប់លោកថាម៉េចខ្លះ> ទាក់ទងនឹងបញ្ហានេះ? ឆ្លើយ៖ គាត់ធ្លាប់និយាយជាមួយខ្ញុំ ហើយបានប្រាប់ខ្ញុំថាប្រសិនណាជាតុលាការសួរៗខ្ញុំអំពីរឿងគាត់ សូមនិយាយអំពីអ្នកទោសនៅកន្លែងនោះ។ ហើយឥឡូវនេះគាត់ហៅខ្ញុំថាបង ហើយគាត់ស្នើសុំថា ឲ្យខ្ញុំនិយាយថាគាត់គឺជាអ្នកទោសនៅទីនោះតែប៉ុណ្ណោះ។ ហើយគាត់ប្រាប់ខ្ញុំម្ដងជាពីរដង គាត់បានស្នើខ្ញុំឲ្យនិយាយបែបនេះម្ដងជាពីរដង"។ បញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំ លោកគឺថាតើត្រូវទេដែលលោកមានការព្រួយបារម្ភក្នុងការមកឆ្លើយជូនតុលាការអំពីអ្វីដែលបានកើតឡើងនៅក្រាំងតាចាន់នោះ?

[០៩:៥៧:៣៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានប្រាប់ថា យើងដូចមិនមានសិទ្ធិប្រើឈ្មោះគាត់ទេ។ អ៊ីចឹងសូមឲ្យប្រើឈ្មោះសម្ងាត់ លោកប្រធាន។

**លោក ឌេល លីសាក់៖**

អនុស្សរណៈដែលខ្ញុំបានទទួល គឺថាអង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីបាន លោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណីលោកចាំសំណួរខ្ញុំអម្បាញ់មិញទេ? សំណួរខ្ញុំហ្នឹងសួរថាតើលោកមានការព្រួយបារម្ភ អំពីការមកឆ្លើយជូនអង្គជំនុំជម្រះអំពីអ្វីដែលកើតឡើងនៅក្រាំងតាចាន់នោះទេ?

**លោក ស្វូត្រ សាំង៖**

**ឆ៖** បាទលោកប្រធាន ខ្ញុំបាទបើនិយាយជាមួយលោក សយ សែន ខ្ញុំបាទមិនដឹងគាត់ចូលពីឆ្នាំណា ខែណា ថ្ងៃណា ខ្ញុំក៏អត់បានដឹងដែរ តាមមើលបាទ។ ក្នុងនោះគឺ សយ សែន ក៏មិនដែលបាននិយាយជាមួយខ្ញុំ ហើយក៏មិនដែលបានមករួមរស់ជាមួយខ្ញុំ ត្បិតតែរស់នៅជាមួយភូមិតែមួយ។ ទើបតែ

ថ្ងៃការនេះ ខ្ញុំបានទៅការកូនគាត់ តែគាត់ក៏មិនដែលនិយាយប្រាប់ខ្ញុំយ៉ាងម៉េចៗ ថាអ្ហ៎! ខ្ញុំខ្លាចជាមួយតុលាការ ខ្លាចនិយាយអារឿងក្រាំងតាចាន់ រឿងអ្នកទោសក្រាំងតាចាន់ រឿងការងារអស់ទាំងនេះ។ ខ្ញុំអត់ដែលបាននិយាយជាមួយទេបាទ។

[០៩:៥៩:៣៦]

**ស៖** សំណួរខ្ញុំគឺអ៊ីចេះទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី ថាតើលោកផ្ទាល់ខ្លួននេះ មានការព្រួយបារម្ភអំពីការដែលចូលខ្លួនមកឆ្លើយជូនអង្គជំនុំជម្រះ និយាយអំពីអ្វីដែលកើតឡើងនៅក្រាំងតាចាន់ដែរទេ?

**ឆ៖** បាទ ក្នុងនោះខ្ញុំបាទគឺ ខ្ញុំតាំងខ្លួនខ្ញុំជាដើមបណ្ដឹង ពេលនោះខ្ញុំអត់ខ្លាចទេ ឃើញយ៉ាងម៉េចខ្ញុំជម្រាបជូនជាក់ស្ដែងចំពោះអង្គជំនុំជម្រះ បាទ។

**ស៖** ខ្ញុំសុំសួរសំណួរមួយចំនួនតូចទាក់ទងទៅនឹងអំឡុងពេលដែលលោកធ្វើការជាកងឈ្លបស្រុកនោះ។ លោកបានជម្រាបជូនតុលាការថាលោកបានធ្វើជាកងឈ្លបនៅស្រុកត្រាំកក់ នៅក្នុងឆ្នាំ១៩៧២ ឬឆ្នាំ១៩៧៣។ លោកចាំទេអំពីការរឹបអូសបាន ឬក៏ការយកជ័យជម្នះទៅលើអង្គតាសោម ដែលខ្មែរក្រហមយកជ័យជម្នះទៅលើអង្គតាសោមបាននៅក្នុងឆ្នាំ៧៣។ លោកចាំទេ?

**ឆ៖** បាទ ក្នុងឆ្នាំ៧៣ ខ្ញុំបាទនៅក្នុងកងឈ្លបពិតប្រាកដមែន ក៏ប៉ុន្តែក្នុងនោះខ្ញុំអត់ទាន់បាននៅកងប្រយុទ្ធទេទាន ខ្ញុំនៅកង គេឲ្យនៅក្នុងកងហៅកងត្រៀមសែងរបួសនៅឡើយទេបាទ។

**ស៖** ខ្ញុំយល់ថាលោកមិនចូលរួមនៅក្នុងការវាយប្រយុទ្ធគ្នាទេ។ លោកចាំទេ ក្រុងអង្គតាសោមគឺត្រូវបានវាយយកបាន<ដោយខ្មែរក្រហមនៅពេលណា ហើយតើគេធ្វើម៉េចចំពោះប្រជាជននៅក្នុងក្រុងនោះ> នៅពេលដែលរំដោះហ្នឹង។ តើលោកចាំទេនៅពេលណាដែរ?

**ឆ៖** បាទ ក្នុងបែកទីក្រុងអង្គតាសោមឆ្នាំ -- ខ្ញុំដឹងថាបែងតែមិនដឹងឆ្នាំណាទេបាទ។

**ស៖** លោកដឹងទេ មានអ្វីកើតឡើងទៅដល់ប្រជាជនដែលរស់នៅឯក្រុងអង្គតាសោមហ្នឹងដែរក្រោយពីរំដោះបាននោះ?

**ឆ៖** ពេលក្រុងអង្គតាសោមរំដោះបានក្រោយមក ខ្ញុំបាទនៅតែខាងត្រៀមខាងមុខទេ អត់ដែលបានមកក្រោយទេបាទ។

[១០:០២:៤៨]

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរមួយចំនួនទាក់ទងនឹងការ<ចាប់>ខ្លួន និងការឃុំខ្លួនឪពុក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

របស់លោកនៅមន្ទីរ២០៤ ដែលលោកបានប្រាប់ថាបានកើតឡើងនៅក្នុងឆ្នាំ១៩៧១ ឬក៏៧២។ នៅក្នុងចម្លើយ ១០៣ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E319.1.23 លោកបានឆ្លើយថា សូមដកស្រង់៖ “លោកមានប្រវត្តិមិនល្អ<ពាក់ព័ន្ធជាមួយ>ដែលឪពុក<>ដែល<ត្រូវបាន>គេចោទ<>ថា ជាគិញ។” ហើយនៅក្នុងចម្លើយ៣០ ទៅ៣១ <នៅក្នុងកិច្ចសម្ភាសន៍ដដែលហ្នឹង> លោកបានឆ្លើយដូចតទៅ។ សូមដកស្រង់៖ “សៈ តើការចាប់ខ្លួនមនុស្សគឺដោយសារមូលហេតុអ្វី? តាមការសម្គាល់របស់ខ្ញុំ ខ្ញុំមិនមានឃើញ<មូលហេតុ>អ្វីទេ។ ប៉ុន្តែ ករណីឪពុកខ្ញុំ នៅឆ្នាំ១៩៧១ កងទ័ពខ្មែរក្រហមចោទឪពុកខ្ញុំថាជាគិញ។ នៅក្នុងឆ្នាំនេះ កងទ័ពខ្មែរ -- ឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅរៀនសូត្រនៅមន្ទីរ២០៤”។ បញ្ចប់ការដកស្រង់។ តើមន្ទីរ២០៤នេះ ជាមន្ទីរអ្វី ហើយមានទីតាំងនៅកន្លែងណាដែរ?

**ឆៈ** បាទ ក្នុងឆ្នាំនោះ ខ្ញុំបាទ --

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សុំអញ្ជើញលោកមេធាវី!

**លោក សួន វិសាល៖**

សូម ខ្ញុំសូមជំទាស់ទៅនឹងសំណួរដែលលោកសហព្រះរាជអាជ្ញាបានលើកឡើង ព្រោះអីរអង្គហេតុហ្នឹងក្រៅយុត្តាធិការរបស់តុលាការបាទ ពីព្រោះអីមុនឆ្នាំ៧៥ បាទ។

[១០:០៥:០០]

**លោក ឌេល លីសាក់៖**

លោកប្រធាន គឺនៅមានការឆ្លើយទាក់ទងទៅនឹងមន្ទីរនេះ។ យើងខ្ញុំចង់ស្វែងយល់ឲ្យឃើញអត្ថិភាពនៃមន្ទីរនេះ<ដែលបង្កើតឡើងនៅមុនអំឡុងពេលហ្នឹង ដើម្បីឲ្យ>ដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហម<។ នេះគឺជាមូលហេតុនៃការតាំងសំណួរនេះ> ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់នេះ។ ពិតមែនតែវាមាន ក្រៅវិសាលភាព ប៉ុន្តែវាមានភាពពាក់ព័ន្ធគ្នាជិតដិត អង្គជំនុំជម្រះត្រូវការស្ដាប់ឆ្លើយ ចម្លើយតបរបស់សាក្សីតបទៅនឹង សំណួរដែលសួរ សំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរអម្បាញ់មិញនេះ។

**លោក ស្មូត្រ សាំង៖**

**ឆ៖** ខ្ញុំបាទ ក្នុងជំនាន់នោះ ៧១ ឪពុកខ្ញុំបាទ បាន -- ថ្ងៃមួយក៏កើតឡើងរឿងនេះ។ សម័យនោះ គឺ សម័យទាហានលន់នល់ និងសម័យកងបដិវត្ត –គេហៅកងបដិវត្ត កងរំដោះៗនោះ– ឪពុកខ្ញុំបាទ ថ្ងៃមួយគាត់ ថ្ងៃ០៨ ត្រូវនឹងថ្ងៃ០៨ កើត ព្រោះអីគាត់ទៅសុំសីលនៅសាលាឆទានមួយហៅថា សាលាឆទាន ត្រពាំងតឹង ភូមិជ្រៃ។ ដល់ពេលទាហានលន់នល់ កងទ័ពរំដោះហ្នឹងគេវ៉ៃគ្នាទៅ គេចាប់ឪពុកខ្ញុំនេះចោទថាគាត់ធ្វើជាគិញ ឲ្យ លន់ នល់ បាទ។

**ស៖** លោកអាចជម្រាបជូនតុលាការបានទេ ឪពុករបស់លោកនៅពេលដែលគេចាប់ខ្លួននោះគាត់មានតួនាទីអ្វីដែរ? ហេតុអ្វីបានជាគេចោទគាត់ថាជាគិញ?

**ឆ៖** គឺគាត់អត់មានតួនាទីអ្វីទេ គាត់ទៅសុំសីល គាត់ជាដូចថា កាលហ្នឹងគាត់ថា -- គេហៅក្នុងបច្ចុប្បន្ន និងសព្វថ្ងៃ គេហៅលោកអាចារ្យក្រុម។ បាទ លោកអាចារ្យក្រុមវេនភូមិត្រពាំងជ្រៃហ្នឹងគឺលោកមកសុំសីល។ បើអ៊ីចឹងគាត់ទៅសុំសីលនៅសាលាឆទានភូមិត្រពាំងតឹងនោះបាទ។

[១០:០៧:៣៥]

**ស៖** ខ្ញុំសួរ<បញ្ជាក់>បន្តិច <តើលោកកំពុងតែនិយាយថា>ឪពុកលោកធ្វើជាអាចារ្យឬ នៅពេលដែលគេចាប់ខ្លួនគាត់ហ្នឹង?

**ឆ៖** គាត់មិនមែនធ្វើជាលោកអាចារ្យធំ លោកអាចារ្យវត្តលោកអាចារ្យអីទេ ថាអាចារ្យក្រុមភូមិ នៅក្នុងភូមិទេបាទ។

**ស៖** លោកដឹងទេ ហេតុអ្វីបានជាគេចោទគាត់ថា ជាគិញ?

**ឆ៖** បាទ គេចោទគាត់ជាគិញ កងរំដោះគេចោទគាត់ជាគិញ កាលនោះមានលោកពី គេហៅពីវត្តខ្សឹង មកឲ្យសីលនៅសាលាត្រពាំងតឹងហ្នឹង កាលកងរំដោះហ្នឹងគេចាប់លោកបានបាទ។ ចាប់លោកបានហ្នឹងគឺលោកហ្នឹង គេហៅ មានអាសាម៉ែលផ្ទុះ ហើយគេចោទតាអាចារ្យៗ ទាំងប៉ុន្មាននាក់ហ្នឹង គេចាប់យកទៅដាក់នៅ២០៤ ទៅបាទ។

**ស៖** លោកដឹងថា មន្ទីរ២០៤ ស្ថិតនៅត្រង់ណាដែរ?

**ឆ៖** បាទ មន្ទីរ២០៤ នោះខ្ញុំបាទឮតែឈ្មោះទេ មិនដែលបានទៅដល់កន្លែងមន្ទីរ២០៤ ទេបាទ។

**ស៖** ក្នុងចម្លើយ៤៥ នៅក្នុងកិច្ចសម្ភាសន៍ដូចគ្នាដដែលនេះ គឺឯកសារ E319.1.23លោកបាននិយាយថា ឪពុករបស់លោកត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧១ ហើយគេឃុំខ្លួនអស់រយៈពេល២ឆ្នាំ។

ក្រោយពីគេដោះលែងគាត់មក ថាតើឪពុកលោកនោះ មានប្រាប់លោកអំពីរឿងរ៉ាវនៅមន្ទីរ២០៤ដែរឬទេ? ហើយតើគាត់មាននិយាយប្រាប់លោកថាមានអ្វីកើតឡើងទេនៅឯមន្ទីរ២០៤ ពេលដែលគេឃុំខ្លួនគាត់នោះ?

**ឆ៖** បាទ ខ្ញុំបាទបានសួរគាត់ជាចុងក្រោយមុននឹង ដែលគាត់ ក្រោយគាត់មកពី២០៤វិញ។ ខ្ញុំបាទបានសាកសួរគាត់ គាត់ក៏ប្រាប់ថា "កូនហើយកុំចង់ដឹង តែបដិវត្តន៍អង្គការគេឲ្យធ្វើអី កូនឯងធ្វើហ្នឹងទៅ រកយកតែសុខទៅកូន"។ ទីចុងបញ្ចប់៧៣ គាត់បានស្លាប់បាទ។

**ស៖** នៅក្នុងសក្ខីកម្មរបស់គាត់ នៅក្នុងថ្ងៃទី២១ មករា ឆ្នាំ២០១៥ នៅចំពោះមុខអង្គជំនុំជម្រះគឺឯកសារ <E1/249.1> គឺនៅម៉ោង<១១:០៧:២៨ រហូតដល់ម៉ោង> ១១:០៩:៣១ សាក្សី មាស សុខា បានឆ្លើយដូចតទៅ សូមដកស្រង់៖ "មន្ទីរ២០៤ គឺជាមន្ទីរឃុំឃាំង អតីតមន្ត្រីទាហានលន់ នល់ ដែលចាប់បានពីអង្គតាសោម ឬកន្លែងផ្សេងៗ។ ឯពួក<អ្នកមាន ឬអ្នក>សក្តិភូមិ ដែលគេចាប់បានក៏ទៅឃុំខ្លួននៅទីនោះដែរ។ <មន្ទីរនោះ>គឺមានទីតាំង នៅៗខាងលិច<ត្រពាំងខាងត្បូង>។" លោកដឹងទេថាមន្ទីរ២០៤ មានទីតាំង ដែលជាគេឃុំខ្លួនមន្ត្រីនាយទាហាន លន់ នល់ទេ លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំបាទជំនាន់នោះ ខ្ញុំបាទអត់ដឹងទេ ឈ្មោះថាមន្ទីរ២០៤ហ្នឹង គ្រាន់តែឮគេថាទេ។ ឮឪពុកខ្ញុំថា "តែ២០៤ កូនអើយកុំចង់ដឹង"។ គាត់គ្រាន់តែប្រាប់ថាប៉ុណ្ណឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារង។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដែលអមគាត់ហ្នឹងមកកាន់កន្លែងផ្តល់សក្ខីកម្មនៅម៉ោងដប់ សាមសិបនាទី។ ដោយពេលចាកចេញនេះ សូមបិទវាំងននជាមុនសិន ហើយដូចគ្នានៅពេលដែលនាំគាត់ទៅចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម សូមធ្វើនៅក្នុងអំឡុងពេលដែលវាំងននបិទ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

សូមអញ្ជើញលោកមេធាវី សួន វិសាល!

**លោក សួន វិសាល៖**

បាទ សូមគោរពលោកប្រធាន។ មុននឹងសហព្រះរាជអាជ្ញាបន្តសំណួរ ខ្ញុំមានការកត់សម្គាល់មួយគឺថា ដូចសាធារណជន និងលោកចៅក្រមឃើញស្រាប់ហើយ គឺថានៅចំពោះមុខយើងនេះ គឺថាសាក្សីមានការការពារ បានន័យថាមានវិធានការការពារពិសេស។ ប៉ុន្តែពីព្រឹកមិញនេះគឺថា ប៉ុន្មាននាទីមុននេះ ឬក៏ប៉ុន្មាននាទីមុននេះ យើងឃើញថាសាក្សីបានឆ្លើយច្បាស់នៅចម្លើយទៅនឹងសំណួរៗរបស់សហព្រះរាជអាជ្ញាថាគាត់មកឆ្លើយពេលនេះ គឺគាត់អត់មានខ្លាចអ្វីទាំងអស់ គាត់មិនព្រួយ មិនភ័យពីរឿងសន្តិសុខអ្វីទាំងអស់។ ដូច្នេះ ខ្ញុំឆ្ងល់ថាតើហេតុអ្វីបានជាតុលាការចាត់វិធានការការពារដល់សាក្សីរូបនេះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ គំនិតរបស់ខ្ញុំ គឺថាវាគ្មានន័យអីទាំងអស់បើសិនណាសាក្សីមិនខ្លាច ឬមិនមានភ័យព្រួយអ្វីពីសន្តិសុខរបស់ខ្លួនសោះ ហេតុអ្វីបានតុលាការចាត់វិធានការបែបនេះ? អ៊ីចឹងគំនិតរបស់ខ្ញុំ គឺថាគួរតែសួរដូចដើមបណ្តឹងរដ្ឋប្បវេណីដូចធម្មតាឡើងវិញ។ ដូច្នេះវិធានការការពារមិនគួរចាត់តាំងទៅលើដើមបណ្តឹងរូបនេះទេ។ បាទសូមអរគុណ នេះជាកំណត់សម្គាល់របស់ខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

ជាការកត់សម្គាល់ឬក៏ជាការស្នើសុំ? ហើយបើស្នើសុំត្រូវមានភស្តុតាង សំអាងហេតុត្រឹមត្រូវ។ បើកត់សម្គាល់ភាគីដទៃទៀតមិនចាំបាច់ធ្វើការឆ្លើយតបលើការកត់សម្គាល់អ្វីទេ។ ការកត់សម្គាល់គឺការកត់សម្គាល់។

[១០:៣៥:០២]

**លោក សួន វិសាល៖**

ខ្ញុំទាក់ទងនឹងកត់សម្គាល់ផង ហើយនិងសំណើសុំផង ថាបើសិនណាគាត់ឆ្លើយច្បាស់ចំពោះមុខ

សវនាការ គាត់មិនមានភ័យខ្លាចអីទេ ដូច្នេះវិធានការការពារមិនគួរមានទេ។ អានេះជាសំណើរបស់ខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធតែម្ដងទៅ ព្រោះសំណើរបស់លោកទី១ គឺអត់ច្បាស់លាស់ទេ។ ជាការកត់សម្គាល់ផង ជាសំណើផង។ ដំបូងជាការកត់សម្គាល់ ក្រោយមកជាសំណើផង ការកត់សម្គាល់ផង។ ទី២ គ្មានសំអាងហេតុអីទេ។ អង្គជំនុំជម្រះបានផ្អែកលើមូលដ្ឋាននៃសំណើសុំជាលាយលក្ខណ៍អក្សររបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ តាមរយៈមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយមានការសិក្សាស្រាវជ្រាវអំពី តាមរយៈប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញយ៉ាងហ្មត់ចត់ បន្ទាប់មកអង្គជំនុំជម្រះបានធ្វើការចេញសេចក្ដីសម្រេចមួយច្បាស់លាស់រួចហើយ។ ប្រសិនបើលោកចង់ប្ដូរត្រូវមានការណ៍ច្បាស់លាស់ ហើយបង្ហាញហេតុឲ្យបានច្បាស់លាស់ មិនមែននិយាយត្រួសៗអ៊ីចឹងបានទេ។ យើងមិនអនុញ្ញាតឲ្យលោកនិយាយបែបនេះទៀតទេ។

អញ្ជើញ!

[១០:៣៦:១៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលមុនឈប់សម្រាក យើងបាននិយាយគ្នាអំពីឪពុករបស់លោក ហើយនិងការជាប់ឃុំឃាំងរបស់គាត់នៅមន្ទីរ២០៤។ សំណួរចុងក្រោយរបស់ខ្ញុំទៅលើប្រធានបទមួយនេះ តើលោកធ្លាប់បានដឹង<នៅពេលក្រោយមកទៀត គឺ>ក្រោយពីការដោះលែង<ឪពុក>របស់លោកមក។ តើលោកបានដឹងទេថាតើអ្នកណាជាមេមន្ទីរ២០៤?

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ខ្ញុំបាទ ជំនាន់នោះខ្ញុំបាទអត់មានដែលដឹងថាពីណាមួយមេ ឬអ្នកណាមួយអ្នកនៅ២០៤ហ្នឹង ខ្ញុំបាទអត់បានដឹងទេបាទ។

[១០:៣៧:២២]

**ស៖** ឥឡូវហ្នឹង ខ្ញុំចូលទៅអំឡុងពេលដែលគេបានបញ្ជូនលោកទៅភ្នំដំរីរមៀល ហើយក្រោយ

មកឲ្យមកធ្វើការនៅ<>ក្រាំងតាចាន់។ នៅក្នុងឯកសារ E319.1.23 ត្រង់ចម្លើយ៥៦ លោកបាននិយាយថា លោកជាផ្នែកមួយនៃក្រុមទាហាន -- កងទ័ពប្រាំមួយនាក់ ក្នុងនោះមាន ស៊ីម, <សឿន> ហើយនិងម្នាក់ទៀតឈ្មោះ សារ៉ាត់ ដែលនៅក្នុងចម្លើយ៦៩ លោកហៅថាគឺជា ឌុចតូច។ មនុស្សពីរនាក់នេះ <សឿន> បាទ <វ៉ាន់ សឿន> ហើយនិង ឌុច តូច ហៅថា ស្រី ថន បានផ្ដល់សក្ខីកម្មនៅក្នុងតុលាការនេះរួចហើយ អ្នកទាំងពីរហ្នឹងបានបញ្ជាក់ថា ពួកគេគឺជាសមាជិកនៃក្រុមកងដែលមានសមាជិកប្រាំមួយនាក់ជាមួយនឹងលោក។ <វ៉ាន់ សឿន> –នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥នេះ គឺឯកសារ <E1/272.1> នៅម៉ោង ១០:៤៤:៤៤ ទៅដល់ម៉ោង ១០:៤៥:៣២– បានឆ្លើយថា លោកនិងគាត់គឺថា<ជាបងប្អូនជីដូនមួយនឹងគ្នា>។ លោកបញ្ជាក់មើល៍ថាតើលោក ហើយនិង <វ៉ាន់ សឿន> ហ្នឹងគឺជាបងប្អូនជីដូនមួយនឹងគ្នា ហើយ<ថាតើលោកនៅក្នុងកងយោធាតែមួយជាមួយនឹង សឿន>, ស៊ីម និង ឌុចតូច <ទាំងនៅ>មុនពេលដែលលោកមកក្រាំងតាចាន់<>ហើយនិងអំឡុងពេលដែលលោកនៅ<ក្នុងគុក> សូមលោកបញ្ជាក់បន្តិចមើល?

**ឆ៖** បាទ ឈ្មោះ វ៉ាន់ ស៊ាន់ នេះ គឺជីដូនមួយខ្ញុំបាទមែន បាទ។ ពីព្រោះ វ៉ាន់ ស៊ាន់ នេះម្ដាយគាត់ហើយនិងឪពុកខ្ញុំបងប្អូនបង្កើត តែទៅនៅកងទ័ពនោះបានជួបគ្នា គេឲ្យមកក្រាំងតាចាន់នេះតែម្ដងមកមិនមែនថាចង់មកទេបាទ។

[១០:៤០:០០]

**ស៖** ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចទាក់ទងឈ្មោះ <វ៉ាន់ សឿន>ក្ដី ឬក៏ស៊ីមក្ដី ឬក៏ឌុចតូចក្ដី តើលោកជាសមាជិកជាមួយនឹងអ្នកទាំងអស់នេះអត់ទេ ជាមួយសមាជិកជាមួយក្រុមអ្នកទាំងអស់នេះ ឬក៏អត់មុនពេលដែលលោកមកក្រាំងតាចាន់?

**ឆ៖** កាលមុននៅក្នុងក្រាំងតាចាន់ មកក្រាំងតាចាន់នេះគឺកងផ្សេងគ្នា។ មិនមែនកង កងវរសេនាធំតែមួយ ប៉ុន្តែកងហាខុសគ្នាទេបាទ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់បន្ថែមទៀតនៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត គឺ E319.1.23 ត្រង់ចម្លើយ១៩ លោករៀបរាប់ថា៖ "នៅមុនបញ្ជូនទៅក្រាំងតាចាន់នោះ ខ្ញុំត្រូវបានចាត់តាំងឲ្យរៀបចំការចាប់ខ្លួនឈ្មោះ ព្រំ សាន់ ដែលត្រូវបានចោទថាក្បត់បដិវត្តន៍ នៅភ្នំដំរីរមៀល នៅក្នុងស្រុកត្រាំកក់"។ បញ្ចប់ការដកស្រង់។ ហើយនៅថ្ងៃនេះលោកបានឆ្លើយថា៖ "កងរបស់លោកហ្នឹងស្ថិតនៅឯភ្នំដំរីរមៀល ដោយគេចាត់តាំងឲ្យទៅចាប់ខ្លួន ព្រំ សាន់ នៅក្នុងឆ្នាំ១៩៧៥"។ នៅក្នុង<សវនាការ

ស្តាប់សក្ខីកម្ម>របស់គាត់នៅថ្ងៃទី០៣ ខែមីនា ២០១៥។ គឺឯកសារE1/270.1 នៅម៉ោង១៤:២៣:២៧ ទៅដល់ ១៤:២៧:១១ បងប្អូនជីដូនរបស់លោកគឺ <វ៉ាន់ សឿន> ក៏បានរៀបរាប់ថា <>គាត់ត្រូវគេបញ្ជូនទៅដំរីរមៀល ដើម្បីឲ្យចាប់ខ្លួន ព្រំ សាន់ នៅពេលដែលកងរបស់គាត់ហ្នឹងត្រូវបានចាត់តាំងឲ្យមកធ្វើការនៅក្រាំងតាចាន់។ គាត់ក៏បាននិយាយអំពីបញ្ហានេះដែរ។ សំណួរខ្ញុំគឺថា តើចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកបានទេដែលថា លោក ហើយនិងបងប្អូនជីដូនមួយរបស់លោកគឺ <វ៉ាន់ សឿន> ហ្នឹងទាំងពីនាក់ហ្នឹងត្រូវបានបញ្ជូនទៅភ្នំដំរីរមៀល ដើម្បីស្វែងរកចាប់ខ្លួនឈ្មោះ ព្រំ សាន់ ហើយក្រោយមក គាត់និងលោកក៏បានត្រូវបញ្ជូនមកក្រាំងតាចាន់។ អ៊ីចឹងមែនទេ?

[១០:៤២:៥២]

**ឆ៖** បាទ ជាការពិតមែន។

**ស៖** បងប្អូនជីដូនមួយលោកគឺ <វ៉ាន់ សឿន> ក៏បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃហ្នឹងដែរគឺថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ គឺឯកសារ <E1/270.1> នៅម៉ោង១៤:៣៣:៣៦ ដែលថា អ្នកទាំងពីរ គឺលោក ហើយ<និង ស៊ឹម> ហើយជាមួយនឹង ឌុចតូច ដែរក៏ត្រូវបញ្ជូនមកក្រាំងតាចាន់ នៅពេលតែមួយ។ តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោក ដែលថាលោក, <សឿន>, ស៊ឹម និង ឌុចតូច គឺបានចាប់ផ្តើមធ្វើការនៅក្រាំងតាចាន់ នៅក្នុងពេលតែមួយ តើអ៊ីចឹងឬក៏អត់?

**ឆ៖** បាទ ពិតមែន។

**ស៖** <វ៉ាន់ សឿន> ក៏បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះគឺនៅម៉ោង ១៤:១០:១៨ ដែលថា គាត់បានចាប់ផ្តើមធ្វើការនៅក្រាំងតាចាន់ នៅចុងឆ្នាំ១៩៧៥។ សមាជិកក្រុមម្នាក់ទៀតឈ្មោះ ស៊ឹម បានឆ្លើយថា -- បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារD40/20 ដែលថាគាត់ក៏ត្រូវបានបញ្ជូនឲ្យមកធ្វើការនៅក្រាំងតាចាន់ នៅរដូវច្រូតកាត់ នៅក្នុងឆ្នាំ១៩៧៦។ ហើយនៅក្នុង<សវនាការស្តាប់សកម្ម>របស់គាត់ នៅថ្ងៃទី១៩ កុម្ភៈ ឆ្នាំនេះ គឺឯកសារ E1/266.1 នៅម៉ោង ១១:០២:៥៤ ឌុចតូច បានទទួលស្គាល់ថាគាត់ត្រូវបានបញ្ជូនឲ្យធ្វើការនៅក្រាំងតាចាន់ នៅចុងឆ្នាំ១៩៧៦។ តើចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកទេ លោកដើមបណ្តឹងរដ្ឋប្បវេណី ដែលលោកថា លោក, <សឿន>, ស៊ឹម, ឌុចតូច ទាំងអស់គ្នាហ្នឹង គឺចាប់ផ្តើមធ្វើការនៅក្រាំងតាចាន់ អាចនៅចុងឆ្នាំ<>៧៥ ឬដើមឆ្នាំ៧៦ និង<មិនមែន>នៅក្នុងឆ្នាំ៧៧ ដូចដែលលោកឆ្លើយនៅថ្ងៃនេះដែរ។ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំបាទគេបញ្ជូនមកឲ្យធ្វើនៅក្នុងហ្នឹង គឺឆ្នាំ៧៦ ប៉ុន្តែមិនដឹងចុងឆ្នាំ ឬមួយដើមឆ្នាំទេ

បាទ។

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់ចំណុចនេះ។ ខ្ញុំសូមសួរទៅចម្លើយរបស់លោកមួយផ្សេងទៀត គឺឯកសារ E319.1.23 គឺត្រង់សំណួរចម្លើយ៤៨ ដល់៤៩។ លោកបានឆ្លើយថា លោក -- "ខ្ញុំមានជីតា<ធម៌>ម្នាក់ឈ្មោះថា <តាជេម> ដែលជា<>មិត្តភក្តិជាមួយនឹងមេគុកក្រាំងតាចាន់ឈ្មោះអាន់ <យូរហើយ>។ លោកឃើញ តា<ជេម> មកមើលគុកក្រាំងតាចាន់ មកជួបគ្នាជាមួយ អាន់។ នៅក្នុងចម្លើយ៥១ លោកឆ្លើយដូចតទៅ៖ "សួរ៖ តើនេះដោយសារតែមិត្តភាពរវាង តាអាន់ និង តា<ជេម> ដែលនាំឲ្យលោកហ្នឹងត្រូវបានឲ្យគេចាត់តាំងធ្វើប្រធានអ្នកយាមនៅគុកក្រាំងតាចាន់មែនទេ? ឆ្លើយ៖ បាទនេះគឺជាមូលហេតុដែលត្រូវបានគេតែងតាំងឲ្យខ្ញុំធ្វើជាប្រធានអ្នកយាម"។ បញ្ចប់ការដកស្រង់។

ទី១ ខ្ញុំចង់ឲ្យលោកប្រាប់បន្តិច អំពីជីតា<ធម៌>របស់លោកឈ្មោះ តា<ជេម> នោះ។ តើ តា<ជេម> មកពីណាដែរ? ហើយគាត់ធ្វើអ្វីដែរ?

[១០:៤៧:៣៤]

**ឆ៖** បាទខាងដើម តាជេម ហ្នឹងខ្ញុំកាលពីសម័យ លន់ នល់ ឪពុកម្ដាយខ្ញុំកាលពីជម្លៀសចេញពីនោះមក មករស់នៅភូមិទទឹងថ្ងៃនេះ គាត់បានរស់នៅជាមួយ ស្គាល់គាត់តាំងពីនុំងមករហូត មិនដែលបានស្គាល់សាច់ឈាមអីទេ គឺសាច់ញាតិដទៃទេដែលកាលជំនាន់លន់ នល់ គេជម្លៀសចេញពីភូមិខាងកើតផ្លូវជាតិលេខ៣មកទាំងអស់ មកនៅខាងលិចផ្លូវជាតិលេខ៣នេះ ដើម្បីខ្លាចទាហានហើយនិងទ័ពរំដោះប្រយុទ្ធគ្នាទៅ វាមានការគ្រោះថ្នាក់បាទ។ ហើយក៏ស្គាល់តាំងពីហ្នឹងមករហូតមក បាទ។

**ស៖** តើ តា<ជេម> គាត់ធ្វើអ្វី គាត់មានតួនាទីអី នៅក្នុងរយៈពេលបដិវត្ត អំឡុងពេលបដិវត្តហ្នឹង ក្នុងអំឡុងខ្មែរក្រហម តើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** តាជេម ហ្នឹង គាត់គ្មានតួនាទីអ្វីទេ គាត់ជាប្រជាជនធម្មតា ប៉ុនកាលពីសម័យគាត់ធ្វើគ្រូជំនាន់លន់ នល់ គឺគាត់ថា គាត់ពួកម៉ាក់ តាអាន់ ដែរកាលនុំងបាទ។

**ស៖** លោកបានឆ្លើយថា លោកហើយនិងគ្រួសាររបស់លោក <បានរស់នៅជាមួយ តាជេម> ក្រោយត្រូវបានជម្លៀសចេញពីភូមិ។ នៅពេលណាដែលគេជម្លៀសលោកចេញពីភូមិស្រុករបស់លោក ហើយលោកទៅរស់នៅជាមួយ តា<ជេម> នុំង?

**ឆ៖** ក្នុងឆ្នាំ១៩៧១ ឬនៅ៧២ បាទ។

**ស៖** សូមអរគុណ។ នៅក្នុងកិច្ចសម្ភាសន៍ដដែល នៅត្រង់ចម្លើយ៦៧ លោកបានឆ្លើយដូចតទៅ គឺឯកសារ E319.1.23 ដដែល៖ “ស៖ តើអ្នកយាមមានកាំភ្លើងកាន់ទេ? ឆ៖ បាទមាន”។ បញ្ចប់ការដកស្រង់។ លោកជម្រាបជូនអង្គជំនុំ តើកាំភ្លើងប្រភេទណាដែលអ្នកយាមនៅក្រាំងតាចាន់កាន់ហ្នឹង ប្រើប្រាស់ហ្នឹង?

**ឆ៖** បាទ អាវុធឲ្យខ្ញុំកាន់កាំភ្លើងនៅក្រាំងតាចាន់ហ្នឹងគឺកាំភ្លើង គេហៅថា អឹមសី ហើយនិង សេកាសេ បាទ។

**ស៖** ខ្ញុំសួរសំណួរលោកមួយចំនួន លោកបានឆ្លើយទៅនឹងសំណួរដែលសួរពីខាងដើម ហើយលោកបានបញ្ជាក់អំពីមេដឹកនាំនៅក្រាំងតាចាន់ក្នុងនោះរួមមាន តាអាន់។ នៅក្នុងឯកសារ E319.1.23 ត្រង់ចម្លើយ៥៣ លោកបានឆ្លើយថា៖ “តើអ្នកណាជាអ្នកគ្រប់គ្រងអ្នកយាម?” ចម្លើយរបស់លោកគឺ តាអាន់ តែម្តង។” នៅក្នុងចម្លើយ១០៤ ដល់ ១០៦ លោកនិយាយអំពីកិច្ចប្រជុំស្វ័យទិតៀន ដែលដឹកនាំដោយតាអាន់។ ដែល តាអាន់ បានព្រមានទៅដល់លោកអំពីការរត់គេចខ្លួន។ <សូមដកស្រង់៖> “គឺបានណែនាំឲ្យយើងទទួលមើលការខុសត្រូវអ្នកទោស កុំឲ្យអ្នកទោសរត់។” សំណួររបស់ខ្ញុំ តើលោកអាចប្រាប់បានទេថា កិច្ចប្រជុំ<ធ្វើជីវទស្សន៍>ស្វ័យទិតៀនហ្នឹងធ្វើឡើងនៅពេលណានៅកន្លែងណា? <>

**ឆ៖** បាទ ក្នុង ធ្វើជីវទស្សន៍ស្វ័យទិតៀនកសាងអ្នកខុសម្នាក់ៗហ្នឹង គឺនៅក្នុងរោងបាយបាទ។

**ស៖** អ្នក<ណាខ្លះ>ចូលរួមនៅក្នុងកិច្ចប្រជុំនេះ?

**ឆ៖** បាទ ក្នុងរោងប្រជុំនេះ គឺមានយុទ្ធជន ពួកមន្ទីរ ពួកប្រធានទាំងបីបាទ។

[១០:៥២:៥៨]

**ស៖** តើនេះគឺជាកិច្ចប្រជុំសម្រាប់យុទ្ធជន <ឬ>កម្មាភិបាលដែលធ្វើការនៅគុកក្រាំងតាចាន់មែនឬអត់ទេ?

**ឆ៖** ក្នុងពួកប្រធានមន្ទីរគេ គេកសាងប្រាប់ថាផ្នែកទ័ព យើងដឹងតែពីទ័ពទេ។ ផ្នែកខាងពួកមន្ទីរ ខាងពួកគេដូចជាយុវកក បក្ខជន ហ្នឹងជារឿងរបស់គេផ្សេងទេបាទ។

**ស៖** តើមេគុកឈ្មោះ អាន់ នេះ ដឹកនាំការប្រជុំធ្វើជីវទស្សន៍ស្វ័យទិតៀនហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ក្នុងនោះមិនជាការញឹកញាប់ពេកទេ មួយខែជួនកាលមានម្តង ជួនកាលក៏គ្មានក៏មាន

ដែរបាទ។

**ស៖** ហើយលោកក៏បាននិយាយអំពីការណែនាំដែលលោកបានទទួលនៅក្នុងកិច្ចប្រជុំនេះ ហើយនិងការប្ដេជ្ញាចិត្តដែលថាលោកធ្វើម៉េចមិនឲ្យអ្នកទោសរត់រួចបានទេ។ តើលោកជម្រាបមើល តើគេមាននិយាយអំពីរឿងអ្វីផ្សេងទៀត ប្រធានបទអីផ្សេងទៀតដែរទេនៅក្នុងកិច្ចប្រជុំដែលដឹកនាំដោយ តាអាន់ហ្នឹង?

**ឆ៖** បាទ ក្នុងនោះ ក្នុងរោងជំនុំនោះ គឺគេនិយាយណែនាំយុទ្ធជនទាំងអស់ តាមមុខសញ្ញារៀងៗខ្លួន។ តែបើសិនជាបងប្អូនអ្នកទោសរត់រួច ជីវិតបងប្អូនក៏វាអស់ក្នុងថ្ងៃហ្នឹងដែរបាទ។

[១០:៥៥:00]

**ស៖** ខ្ញុំដឹងថារយៈពេលវាយូរមកហើយ។ ប៉ុន្តែលោកចាំទេ តើ<តាអាន់>និយាយអ្វីក្រៅពី<ហ្នឹងទៀតដែរទេក្នុងអង្គប្រជុំ>ធ្វើជីវទស្សន៍ស្វ័យទិតៀន<នេះ>?

**ឆ៖** បាទ ក្រៅពីនោះ គឺដូចមិនមាន ដែលមាននិយាយបញ្ហាអ្វីៗទេ មានតែបញ្ហាចុងក្រោយមកបើថាបងប្អូនយុទ្ធជនទាំងអម្បាលម៉ាន មានតែផែនការរកម្ហូបហូបនៅក្នុងក្រុម មន្ទីរហ្នឹងតែប៉ុណ្ណឹងទេបាទ។

**ស៖** នៅព្រឹកមិញនេះ លោកបានឆ្លើយជូនអង្គជំនុំជម្រះថា គឺមានកងពិសេសនៅក្នុងឃុំ ឬក៏នៅក្នុងស្រុកដែលចេញទៅចាប់ខ្លួនអ្នកទោសហ្នឹង ហើយ<នាំពួកគេ>ទាំងអស់មកក្រាំងតាចាន់។ ខ្ញុំចង់សួរសំណួរមួយចំនួន នៅពេលដែលអ្នកទោសទើបនឹងមកដល់ក្រាំងតាចាន់ តើមានអ្វីកើតឡើង? នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកគឺឯកសារ D22/88, ERN ជាភាសាខ្មែរ 00354365, ERN អង់គ្លេស 00379421 និងភាសាបារាំង 01055820។ លោកបានឆ្លើយដូចតទៅនេះនៅក្នុងពាក្យសុំតាំងខ្លួន និងសូមដកស្រង់៖ "នៅពេលដែលខ្ញុំគោះជួងហៅអ្នកនៅមន្ទីរឲ្យមកយកអ្នកទោសទៅដាក់ចូលទៅក្នុងគុក ហើយខ្ញុំក៏ដើរទៅតាមគេ"។ បញ្ចប់ការដកស្រង់។ ហើយនៅក្នុងឯកសារដែលត្រូវបានទទួលយកមកដាក់ក្នុងសំណុំរឿងនេះ E3/2120, ត្រង់ ERN ជាភាសាអង់គ្លេស 00416390 នេះគឺជាសៀវភៅមួយ វាមានសម្រង់តែជាភាសាអង់គ្លេសទេ គឺជាសៀវភៅដែលសរសេរដោយអ្នកសិក្សាស្រាវជ្រាវម្នាក់ឈ្មោះ អ៊ា ម៉េងទ្រី ដែលនិយាយថា គាត់បានសម្ភាសលោក គឺ ស្វាត្រ សាំង នេះនៅក្នុងខែតុលា ឆ្នាំ២០០១។ ហើយគាត់បាន គឺថា សរសេរនៅចម្លើយរបស់លោក<និងអ្នកយាមដទៃទៀត>ដូចតទៅនេះ។ សូមដកស្រង់៖ "អតីតកម្មាភិបាលឈ្មោះ ចន្ថា ហើយនិង សាំង បានរាយការណ៍

ថា នៅពេលហ្នឹងគឺ គេគោះជួងដែលព្យួរនៅដើមស្វាយនៅទិសខាងលិច<នៃមន្ទីរនោះ>។ ក្រោយពីឮសូរស្នូរជួង កម្មាភិបាលបានចេញមក ជួបជាមួយអ្នកទោស ហើយយកអ្នកទោសហ្នឹងចូលដាក់ក្នុងបន្ទប់ឃុំឃាំងនៅខាងក្នុង"។ សំណួរដំបូងរបស់ខ្ញុំ តើ<មាន>ជួង<មួយ> នៅខាងក្រៅបរិវេណគុកក្រាំងតាចាន់ <ដែលគេវាយជួងហ្នឹង នៅពេលដែល>អ្នកទោស<ត្រូវបាននាំមកដល់ខ្លោងទ្វារនៃ> បរិវេណគុកក្រាំងតាចាន់នោះ <ដែរ ឬទេ>?

**ឆ៖** បាទ ជួងគឺនៅបរិវេណរបងខាងក្រៅ។ របងជំនាន់នោះ វាមានទី១ និងទី២។ របងទី១ខាងក្នុង អាខាងណោះអារបងទី១ ខាងក្រៅ ដល់អ៊ីចឹងជួងតែនៅខាងក្រៅអ៊ីចឹងបាទ។

**ស៖** ដើម្បីបំភ្លឺបញ្ហានេះ លោកនិយាយថាជួងនៅខាងក្រៅរបង គឺថានៅរបងខាងក្រៅ។ អ៊ីចឹងគឺមិនមែននៅខាងក្នុងទេ។ គឺអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ នៅខាងក្រៅ។

[១០:៥៩:៤៥]

**ស៖** សម្រង់<ទី២>ដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺជាចម្លើយដែល<ផ្ដល់ដោយអ្នកស្រាវ-ជ្រាវម្នាក់ឈ្មោះ>លោក អ៊ា ម៉េងទ្រី គាត់ថាគាត់បានសម្ភាសជាមួយលោកនៅឆ្នាំ២០០១។ អ៊ីចឹង តើលោកចាំទេថា មានអ្នកស្រាវជ្រាវ ឬក៏អ្នកសរសេរសៀវភៅណាគាត់បានមកសម្ភាសលោក<នៅឆ្នាំ២០០១>ទេ?

**ឆ៖** បាទ គឺសម្ភាសនោះ ខ្ញុំមិនបានចាំអស់ទេ មិនដឹងឆ្នាំណា មិនដឹងថ្ងៃណា ពីព្រោះមានច្រើនបងខាង បងប្អូនគាត់ទៅស្រាវជ្រាវហ្នឹងមិនមែនតែម្នាក់ មិនដឹងបងប្អូនខាងណាខ្លះទេបាទ ប៉ុន្តែខ្ញុំចាំមិនអស់ទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីប្រភេទអ្នកទោសនៅក្រាំងតាចាន់។ តើលោកអាចជម្រាបបានទេថា តើមានអ្នកទោសប្រភេទណាខ្លះដែលគេបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់?

**ឆ៖** ក្នុងនោះមិនមែនជាអ្នកទោសគេប្រកាន់ថាយ៉ាងម៉េចទេ ខ្ញុំមិនដឹងដែររឿងនេះ ស្រេចលើអ្នកខាងដូចជាកង -- នៅតាមកងភូមិ ឃុំ ស្រុក ខេត្តរបស់គេ មានតែឃើញបងប្អូនទៅដល់នោះតែម្ដងបាទ។

[១១:០១:៤០]

**ស៖** ខ្ញុំចង់រំឭកការចងចាំលោកដោយដកស្រង់នៅក្នុងចម្លើយ<ទាំងពីរ>របស់លោក ដែលបាន

ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ <ទី១>គឺកំណត់ហេតុ E319.1.23។ ចម្លើយ៩១លោកថា អ្នកទោសគឺមានលាយឡំគ្នា មានចម្រុះគ្នា ហើយអ្នកទោសខ្លះ<ត្រូវបានចាប់ខ្លួនដោយ>គេចោទប្រកាន់ថាប្រឆាំងបដិវត្តន៍។ នៅកំណត់ហេតុ D40/21, ខ្មែរគឺ 00165342, ជាភាសាអង់គ្លេស 00223551, ជាភាសាបារាំង 00524330។ លោកបានឆ្លើយទៅនឹងសំណួរដែលគេសួរថា តើអ្នកទោសបានប្រព្រឹត្តកំហុសអ្វីខ្លះ? លោកឆ្លើយថាអ្នកខ្លះគឺជាប់ពាក់ព័ន្ធទៅនឹងមន្ត្រីរបបចាស់ ហើយអ្នកខ្លះគឺរត់ចោលជួរ អ្នកខ្លះគឺខុសសីលធម៌។ សំណួរទី១ ពាក់ព័ន្ធទៅនឹងចំណុចនេះ តើលោកចង់មានន័យថាយ៉ាងម៉េចនៅពេលដែលលោកនិយាយថា អ្នកទោសដែលមានជាប់ពាក់ព័ន្ធទៅនឹងអតីតមន្ត្រីរាជការរបបចាស់នោះ?

**ឆ៖** បាទ ក្នុងនោះវាកាលពីជំនាន់សម័យបដិវត្តន៍នោះគេៗ អារឿងរបបចាស់ហ្នឹងគេដាច់ខាតមាំណាស់។ បើអ៊ីចឹងកាលពីមុនហ្នឹងគេ -- ខ្ញុំយល់ឃើញថាករណីនេះ ឲ្យតែក្បត់បដិវត្តន៍គឺគេយកកម្ទេចចោលហើយ។ គេយកទៅអប់រំ គេយកទៅកសាង ប៉ុន្តែមិនដឹងថាកម្ទេចកន្លែងណាខ្លះ ឬកន្លែងតែមួយ ឬកន្លែងដទៃក៏មិនដឹងដែរ។ ហ្នឹងខ្ញុំអត់ដឹងទេបាទ។

[១១:០៣:៥៨]

**ស៖** នៅពេលដែលលោកនិយាយអំពីរបបចាស់។ លោកសំដៅដល់របបលន់នល់ ឬក៏របបណា?

**ឆ៖** បាទ របបលន់នល់។ តាំងពីរបបលន់នល់រហូតមកដល់សម័យធ្វើបដិវត្តន៍ហ្នឹងក៏គេ ឃើញតែបងប្អូនមកអ៊ីចឹង ខ្ញុំមិនដឹងថាកំហុសនៅលើអ្វីខ្លះទេបាទ។

**ស៖** តើអ្នកទោសនៅក្រាំងតាចាន់ហ្នឹងមានមន្ត្រីរដ្ឋការលន់នល់ ឬក៏ទាហានលន់នល់ ឬក៏អាចមានជាបងប្អូនសាច់ញាតិរបស់អ្នកដែលជាប់ពាក់ព័ន្ធនឹងរបបលន់ នល់ទេ?

**ឆ៖** បាទ មានបង។

**ស៖** នៅក្នុងសៀវភៅរបស់ លោក អ៊ា ម៉េងទ្រី ដែលខ្ញុំបានអានឃ្លាមួយអម្បាញ់មិញនេះ គឺជាៗការសម្ភាសដែលធ្វើនៅខែតុលា ឆ្នាំ២០០១ ឯកសារ E3/2120, ERN ជាភាសាអង់គ្លេស 0041 6383 មានជំពូកមួយដែលពាក់ព័ន្ធទៅនឹងមន្ទីរអប់រំកែប្រែ<ស្រុក និងមានព័ត៌មានជាច្រើនទាក់ទងនឹងក្រាំងតាចាន់>។ <>ហើយយើងបានស្នើសុំឲ្យមានការបកប្រែជំពូកនោះ ដោយមានប្រហែលជា៣០ទំព័រ។ គឺ ERN <ជាភាសាអង់គ្លេស>គឺ 00416383 ក្នុងនោះគឺគាត់និយាយថា “លោក សូត្រ សាំង បានយាម បានត្រួតពិនិត្យមើលអ្នកទោសដែលជាទាហានលន់ នល់ ឬក៏ជាប៉ូលិស ហើយដែលបានចាប់ដោយ<គណៈ>ឃុំ ហើយបញ្ជូនទៅមន្ទីរ<អប់រំកែប្រែ>ត្រាំកក់។” ហើយ<គាត់បាន>ពន្យល់ថា “នៅ

ពាក់កណ្ដាលឆ្នាំ៧៥ នោះមានចំនួនអ្នកទោសត្រូវបាននាំចូលមកទាំងថ្ងៃទាំងយប់<ទាំងថ្ងៃ> គឺច្រើនមែនទែន ហើយគឺថាពេលនោះគឺអត់បានដេក អត់បានពួនអីទេ ដោយសារតែមានអ្នកទោសចូលមកច្រើនពេក”។ លោក<ដើមបណ្ដឹងរដ្ឋប្បវេណី នៅសវនាការ>ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ នៅចំពោះមុខតុលាការនេះ សយ សែន គឺនៅក្នុងឯកសារ E1/256.1 នៅម៉ោង១៤:៣៦:៣០ រហូតទៅដល់ម៉ោង<១៤:៤៨:១៧> គាត់និយាយថា៖ “ចំនួនអ្នកទោសបានកើនឡើងបន្ទាប់ពីរំដោះប្រទេសបាន។ គឺបន្ទាប់ពីភ្នំពេញត្រូវបានរំដោះ។ <អតី>ទាហាន<>លន់នល់ ត្រូវបានចាត់ទុកថាជាឈ្លើយសឹក ហើយប្រជាជនទីក្រុងភ្នំពេញ ត្រូវបានចាត់ទុកជាប្រជាជន១៧មេសា ហើយត្រូវបានបញ្ជូនទៅទីនោះ”។ បញ្ចប់ការដកស្រង់។ ខ្ញុំសូមសួរលោកថាតើលោកអាចនិយាយអំពីការចាប់ខ្លួនអតីតទាហាន លន់ នល់ និងអតីតប៉ូលិសលន់នល់ នៅស្រុកត្រាំកក់ <នៅក្នុង>ឆ្នាំ៧៥ បានទេ?

[១១:០៧:៥០]

**ឆ៖** បាទ ជំនាន់នោះខ្ញុំអត់បានដឹងទេបាទ ព្រោះខ្ញុំនៅទ័ពនោះទេបាទ។

**ស៖** តើក្រោយមកនោះលោកមានដឹងទេថា អតីតទាហាន លន់ នល់ ជាច្រើនត្រូវបានចាប់ខ្លួនក្រោយពីរំដោះថ្ងៃទី១៧ មេសា ៧៥ នោះ?

**ឆ៖** បាទ ទាហាន លន់ នល់ គេចាប់ មិនដឹងចាប់យកទៅដាក់កន្លែងណា ពីព្រោះខ្ញុំមិនបានចូលមុនទាន់ បានចូលមកនៅក្នុងក្រាំងតាចាន់ទេបាទ។

**ស៖** តើលោកបានឃើញ ឬបានឮអ្វីខ្លះពាក់ព័ន្ធទៅនឹងការចាប់ខ្លួនអតីតទាហាន លន់ នល់ នេះ?

**ឆ៖** ក្នុងជំនាន់នោះ ខ្ញុំនៅជាយុទ្ធជន នៅទ័ព ខ្ញុំអត់បានដឹងទេ សមរភូមិខាងក្រោយបាទ អត់ដែលបានដឹងទេ សមរភូមិក្រោយនេះ។

**ស៖** ខ្ញុំយល់<ហើយ>ថាលោក មិនចេះអានអក្សរទេ ក៏ប៉ុន្តែខ្ញុំចង់សួរសំណួរលោកពាក់ព័ន្ធនឹងឯកសារមួយ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំនឹងអានឯកសារនេះ ជូនទៅ<លោកដើមបណ្ដឹងរដ្ឋប្បវេណី> គឺឯកសារលេខ E3/4164 គឺជា<បញ្ជីអ្នកទោសនៅក្រាំងតាចាន់ មានចំណងជើងថា> “ប្រវត្តិរូបអ្នកទោសនៅ<> មន្ទីរអប់រំស្រុកត្រាំកក់។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងនេះ<អ្នកទោសទីពីរ និងទីបីនៅក្នុងបញ្ជីនេះ>យើងឃើញថាមានគ្រូពេទ្យស្រីពីរនាក់ដែលជាអ្នកទោសនៅក្រាំងតាចាន់ ដែលឈ្មោះ ហាន –អ៊ុច

ហាន– និងរុន គឺសារុន – <រង> សារុន។ អ៊ុច ហាន និង <រង> សារុន។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកចាំពេទ្យស្រីពីរនាក់ដែលជាប់ទោសនៅក្រាំងតាចាន់ទេ គឺឈ្មោះ ហាន និងឈ្មោះ សារុន ឬក៏ហៅខ្លីថា រុន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ!

**លោក ស្បូត្រ សាំង៖**

**ឆ៖** បាទនៅក្នុងក្រាំងតាចាន់គឺ អ៊ីហាន និង អ៊ីរុន គាត់បានចូលមកក្នុងក្រាំងតាចាន់មែនបាទ។

**ស៖** តើលោកចាំទេថា ហាន និង រុន ហ្នឹងជាប់ទោសនៅក្រាំងតាចាន់ហ្នឹងរយៈប៉ុន្មានដែរ?

**ឆ៖** ក្នុងហ្នឹង ខ្ញុំក៏មិនបានចាំឆ្នាំគាត់ដែរ ប៉ុន្តែដល់ក្រោយពីខ្ញុំទៅទ័ព មិនដឹងគាត់ទៅភូមិករជួបក្រុមគ្រួសារគាត់វិញ ឬមិនដឹងទេបាទ។

[១១:១២:២៥]

**ស៖** នៅក្នុងបញ្ជីអ្នកទោសនេះ គឺយើងឃើញមានដាក់អំពីតួនាទី ឬក៏មុខរបរចាស់ ហើយនិង <ដាក់ថា>ជាអ្នកមូលដ្ឋាន ឬក៏អ្នក១៧មេសា<>។ នៅក្នុងចំណោមអ្នកទោសទាំង២៩នោះ ២១នាក់ត្រូវបានគេចាត់ទុកជាប្រជាជន១៧មេសា ហើយប្រាំមួយនាក់គឺជាប្រជាជនមូលដ្ឋាន, ១១នាក់ត្រូវបានចាត់ទុកថាជាអតីតទាហានលន់ នល់ ហើយក្នុងនោះ យើងឃើញមានដាក់ថា<ម្នាក់ទៀតគឺកូនប្រុស>របស់មេបញ្ជាការ លន់ នល់ ដែលត្រូវបានកម្ទេច។ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចង់ឲ្យលោកជម្រាបពីអំពីអ្វីដែលលោកបាន<សង្កេត>ក្នុងឋានៈលោកជា<អ្នកយាមម្នាក់>នៅក្រាំងតាចាន់។ អ៊ីចឹងថាតើមានអ្នកទោសអ្នក១៧មេសាហ្នឹង ច្រើនជាងអ្នកមូលដ្ឋានដែលជាអ្នកទោសនៅទីនោះ។ តើមែនទេ?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:១៣:៣៦]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំ<មានការ>ជំទាស់<ចំនួនពីរ> ពីព្រោះថានេះជាសំណួរនាំមុខ។ យើងយល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មិនអាចប្រាប់បានទេ ថាតើអ្នកណាជាអ្នក១៧មេសា ឬ<ក៏មិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មែននោះទេ។ ខ្ញុំមានន័យថា មិនមានស្នាមសាក់នៅលើថ្ងាសរបស់ពួកគេនោះទេ។ ដូច្នេះ>គាត់មិន<ចេះអានអក្សរនោះទេ ហើយមធ្យោបាយតែមួយគត់ ដែលលោកអាចកំណត់អត្តសញ្ញាណថានរណាម្នាក់ជា>អ្នក១៧មេសា<នោះ គឺប្រហែលធ្វើទៅតាមរយៈការអានប៉ុណ្ណោះ។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនអាចកំណត់អត្តសញ្ញាណ ថានរណាម្នាក់ជាអ្នក១៧ មេសា ឬក៏អត់នោះទេ ដោយនិយាយថា “បាទ” ឬ “ទេ” នោះឡើយ>។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថាសំណួរនេះមិនមែនជាសំណួរនាំមុខទេ។ <ខ្ញុំគ្រាន់តែសួរអំពីការសង្កេតរបស់គាត់។ ទី២ គឺ>មានរបៀបផ្សេងៗដែល<>អ្នកយាម<នៅក្រាំងតាចាន់អាច>ដឹងអំពីព័ត៌មានរបស់អ្នកទោសដែលថាមកពីណា <ឬក៏មានបញ្ហាអ្វីនោះ>។ ដូច្នេះ ខ្ញុំគិតថាអ្នកដែលធ្វើការនៅក្រាំងតាចាន់ ុុះ<គឺស័ក្តិសមណាស់ក្នុងការឆ្លើយតប>ទៅនឹងសំណួររបស់ខ្ញុំនេះ លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី ហើយអង្គជំនុំជម្រះក៏ត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សី ចំពោះសំណួរដែលសួរលើកដោយសហព្រះរាជអាជ្ញារងអន្តរជាតិចំពោះដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយអម្បាញ់មិញនេះ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីគាត់ជាអ្នកធ្វើការនៅទីនោះ គាត់ប្រាកដជាបានធ្វើការសង្កេត និងអាចបានដឹងពីព័ត៌មាននេះ។

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយសហមេធាវី-- អ៎! សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើលោកចាំសំណួរ។

**លោក ស្វូត្រ សាំង៖**

**ឆ៖** បាទ សូមជម្រាបលោក ក្នុងអ្នកទោសទាំងអម្បាលម៉ានដែលលោកបានលើកឡើង ខ្ញុំក៏មិនដឹងថាមួយណាកូន លន់ នល់, មួយណា១៧, មួយណាមូលដ្ឋាន, មួយណាក៏ទ័ពដែរ ព្រោះខ្ញុំអត់បានដឹងដែរបាទ។

[១១:១៦:៣៨]

**សួរដោយលោក ឌេល លីសាក់៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវនេះខ្ញុំចូលទៅសំណួរផ្សេងទៀតពាក់ព័ន្ធទៅនឹងចំនួនអ្នកទោសនៅក្រាំងតាចាន់។ កាលពីព្រឹកមិញនេះលោកបានឆ្លើយថា អ្នកទោសមកដល់ក្រាំងតាចាន់ ហើយគេសួរលោកថា តើប្រហែលជាអាចមានប៉ុន្មាននាក់មកក្រាំងតាចាន់នុ៎ង ហើយនៅក្នុងឯកសារលេខ D40/21 គឺខ្មែរ 00165340, អង់គ្លេស 00223550, ជាភាសាបារាំង 00524328។ គេសួរថា “តើជាទូទៅអ្នកទោសមកដល់ក្រាំងតាចាន់មានប៉ុន្មាន?” លោកក៏បានឆ្លើយថា៖ “ជួនកាល២០ជួនកាលទៅ៣០នាក់”។ សូមបញ្ចប់ការដកស្រង់។

ឥឡូវនេះ ខ្ញុំចង់អានឃ្លាមួយចំនួនរបស់អ្នកយាមផ្សេងទៀតដែលនៅក្នុងកងជាមួយលោក ដែលមកផ្ដល់សក្ខីកម្មនៅតុលាការនេះ គឺអ្នកយាមឈ្មោះ ស៊ឹម គាត់បាននិយាយនៅក្នុងឯកសារ D40/20, ERN ជាភាសាខ្មែរ 00165333, ជាភាសាអង់គ្លេស 00433572, ជាភាសាបារាំង 00524321។ ខ្ញុំសូមដកស្រង់ “សំណួរ៖ ជាទូទៅតើមានអ្នកទោសប៉ុន្មាននាក់ត្រូវបានបញ្ជូនមកក្នុងពេលតែមួយ ហើយញឹកញាប់ប៉ុនណាដែរ? ចម្លើយ៖ ជួនកាល១០ ជួនកាលប្រាំ ជួនកាលទៅតែម្នាក់។ គឺមានបញ្ជូនមកស្ទើរតែជារៀងរាល់ថ្ងៃ។ ស៊ឹម ក៏បានឆ្លើយនៅទំព័រ ERN ដដែលថា “មានអគារឃុំអ្នកទោសបី ហើយនៅក្នុងអគារនីមួយៗ គឺមានអ្នកទោសពីរជួរ ដែលមានប្រហែលជា២០នាក់ នៅក្នុងមួយជួរៗ”។ ឌុចតួច <ហៅ>ស្រី ថន ក៏បានផ្ដល់សក្ខីកម្មផងដែរ នៅចំពោះមុខតុលាការនេះ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/266.1 នៅម៉ោង ១១:១២:៤៨ ទៅដល់ម៉ោង ១១:១៦:៤៩ គាត់បានឆ្លើយថា “ចំនួនអ្នកទោសដែលនាំចូលមកក្រាំងតាចាន់ អាចមានពីបីទៅបួននាក់ ឬក៏អាចមានរហូតទៅដល់<២០>នាក់ក្នុងមួយថ្ងៃ ហើយមានអគារឃុំអ្នកទោសពីរដែលនៅក្នុងអគារនីមួយៗនុ៎ងមានអ្នកទោសប្រហែលជា៥០ទៅ៦០នាក់”។ ចំពោះបងប្អូនជីដូនមួយរបស់លោក គឺ <វ៉ាន់ សឿន> គាត់បានឆ្លើយនៅចំពោះមុខតុលាការនេះ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ គឺឯកសារ E1/271.1 នៅម៉ោង ០៩:២៥:១០ រហូតទៅដល់ ០៩:២៧:២២។ ខ្ញុំសូមដកស្រង់៖ “អ្នកទោសត្រូវបានបញ្ជូនមកស្ទើរតែជារៀងរាល់ថ្ងៃ”។ សូមបញ្ចប់ការដកស្រង់។ ហើយគាត់ក៏បានឆ្លើយបន្ថែមទៀតថា អគារអ្នកទោសនីមួយៗហ្នឹង ប្រហែលជាអាចដាក់អ្នកទោសបានយ៉ាងតិច<> ៥០នាក់<>។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា ពិបាកក្នុងការកំណត់ចំនួនអ្នកទោសណាស់ព្រោះថាលោកមិនដែលរាប់ទេ<>។ អ៊ីចឹងតើ<វាអាចទេ ដែលថាការប៉ាន់ប្រមាណរបស់លោកហ្នឹងគឺ>អ្នកទោសនៅក្រាំងតាចាន់ហ្នឹងមានចំនួនតិចតួចមែនទេ? <ហើយចំនួនអ្នកទោសដែលថាមានច្រើន

ហើយវាស៊ីសង្វាក់គ្នាទៅនឹងភស្តុតាង ដែលយើងបានស្តាប់សក្ខីកម្មពី>អ្នកយាម<បីនាក់>ផ្សេងទៀតហ្នឹង គាត់ឆ្លើយថា អ្នកទោសហ្នឹងគឺមានចំនួនច្រើន។ អ៊ីចឹងតើលោកឆ្លើយតបយ៉ាងម៉េចដែរលោកថាមានតិច ក៏ប៉ុន្តែអ្នកផ្សេងគេថាមានច្រើននោះ?

[១១:២១:២៣]

**ឆ៖** បាទក្នុងនេះ ខ្ញុំក៏មិនទាន់ថា តិចក៏មិនទាន់ថា ច្រើនក៏ខ្ញុំមិនទាន់ថា ពីព្រោះអ្នកទោស ខ្ញុំមិនបានស៊ើបអង្កេតជាប់លាប់រាល់ថ្ងៃនេះ។ ពីព្រោះរាល់ថ្ងៃ ជួនកាលខ្ញុំបានស៊ើបអង្កេតខ្លះ ជួនកាលមិនបានស៊ើបអង្កេត ដោយសារខ្ញុំគេឲ្យទៅរកម្ហូបភាគច្រើន បាទទៅបង់សំណាញ់តាមមូលដ្ឋាន តាមសហករណ៍អ៊ីចឹង តាមទំនប់វាលឆ្ងាយពីទីកន្លែងបាទ។

**ស៖** តើលោកអាចជម្រាបបានទេថា តើមានអគារឃុំអ្នកទោសមានប៉ុន្មានដែរ? ហើយក្នុងមួយអគារៗហ្នឹងមានដាក់អ្នកទោសប៉ុន្មាននាក់ដែរ?

**ឆ៖** បាទក្នុងនោះអគារក្នុងមន្ទីរក្រាំតាចាន់ សូមជម្រាបគឺថា នៅក្នុងនោះមានអគារបីពិតប្រាកដ មែន។ អាមួយពីខាងកើត អាមួយនៅខាងលិចមួយបាទ។ តែចំពោះអ្នកទោស មិនប្រាកដថាឲ្យពេញតែរហូតទេក្នុងនោះបាទ។

**ស៖** អ៊ីចឹងនៅពេលដែលដាក់អ្នកទោសពេញក្នុងមួយអគារនោះ ខ្ញុំចង់ដឹងថាតើមួយអគារអាចដាក់អ្នកទោសបានប៉ុន្មាន?

**ឆ៖** ក្នុងនោះ ខ្ញុំមិនប្រាកដទេ ថាប៉ុន្មាន ចំនួនប៉ុន្មាន ខ្ញុំអត់បានដឹងដែរ ប៉ុន្តែគ្រាន់ក្នុងអគារមួយៗអាហ្នឹងដាក់បានអ្នកទោសពីរជួរ មួយជួរផ្លូវដើរកណ្តាល សងខាងសម្រាន្ត សងខាងអ្នកទោសបាទ។

[១១:២៣:៣៣]

**ស៖** ឥឡូវនេះ ខ្ញុំចង់អានឃ្លាមួយនៃឯកសារមួយផ្សេងទៀត ដែលមាននៅក្នុងសំណុំរឿង គឺឯកសារ E3/2109, ERN ជាភាសាខ្មែរ 00068014, ជាភាសាអង់គ្លេស 00276555, ជាភាសាបារាំង 00290272។ លោកដើមបណ្តឹងរដ្ឋប្បវេណី ឯកសារនេះគឺជារបាយការណ៍<ពី>ក្រាំងតាចាន់ ចុះខែវិច្ឆិកា ឆ្នាំ១៩៧៧។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះនៅលើអេក្រង់។

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន តើការធ្វើបែបនេះដើម្បីអ្វីដែរ? សាក្សីមិនចេះអានអក្សរ។>

**លោក ឌេល លីសាក់៖**

<នេះគឺជានីតិវិធីសាធារណៈដែលជាផលប្រយោជន៍សម្រាប់តុលាការ និងសាធារណជនទាំងអស់។>

[១១:២៤:៥៦]

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែទេលោកមន្ត្រីរដ្ឋបាលតុលាការ។

សហព្រះរាជអាជ្ញារង និយាយម្តងទៀត ព្រោះអំមិញ អត់មានការបកប្រែភាសាទេ។

**លោក ឌេល លីសាក់៖**

តើអម្បាញ់មិញនេះ លេខERNមានបកប្រែទេ លោកប្រធាន? ខ្ញុំត្រូវសួរសំណួរឡើងវិញ ឬក៏យ៉ាងម៉េច?

ខ្ញុំគិតថាចម្លើយរបស់ខ្ញុំទៅលោក កូប៉េ គឺ<មិន>ត្រូវបានបកប្រែ<>ទេអម្បាញ់មិញ។ ខ្ញុំសូមឆ្លើយថា ខ្ញុំសូមឱ្យបញ្ចាំងឯកសារនេះ គឺដើម្បីឱ្យភាគី<ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី> ដើម្បីឱ្យអង្គជំនុំជម្រះ និងសាធារណជន បានមកមើលឃើញ។ អ៊ីចឹងហើយ បានជាខ្ញុំស្នើសុំឱ្យមានការបញ្ចាំងឯកសារនេះ នៅលើអេក្រង់កុំព្យូទ័រនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១១:២៦:៥៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងឯកសារនេះគឺមាននិយាយថានៅខែវិច្ឆិកា ឆ្នាំ១៩៧៧ “គឺមានអ្នកទោសថ្មី៧៥នាក់មកដល់ ហើយ៩២នាក់ត្រូវបានបោសសម្អាត អ្នកទោសប្រាំមួយនាក់ស្លាប់ដោយជំងឺ។ អ្នកទោសម្នាក់ដែលជាវរសេនីយ៍ទោនោះ ត្រូវបានដកទៅតំបន់ដោយអង្គការ។ អ៊ីចឹងសរុបទៅ គឺអ្នកទោស៨៥នាក់ នៅចុងខែវិច្ឆិកា”។ បន្ទាប់មក របាយការណ៍នេះមាននិយាយថា “មានអ្នកទោស១០៩នាក់ នៅក្រាំងតាចាន់ នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧៧។ ហើយនៅក្នុងខែដដែលនោះ គឺ៧៥នាក់ មកដល់ថ្មី ហើយ៩៩នាក់ត្រូវបានបោសសម្អាត ឬក៏ស្លាប់ ឬក៏បញ្ជូនចេញ។ អ៊ីចឹងសរុបទៅ គឺអ្នក

ទោសមាន៨៥នាក់ នៅចុងខែ"។ តើខ្ញុំអានបែបនេះ ធ្វើឲ្យលោកចងចាំឡើងវិញទេ ថានៅចុងឆ្នាំ ១៩៧៧ គឺមានអ្នកទោសប្រហែលជា១០០នាក់ នៅក្រាំងតាចាន់។ មានអ៊ីចឹងទេ?

**លោក សូត្រ សាំង៖**

**ឆ៖** បាទខ្ញុំសូមជម្រាបនៅក្នុងនោះ គឺខ្ញុំមិនបានចាំទេ ពីព្រោះបើថាមិនបានចាំឆ្នាំខែយូរ កាលពេលវេលាវាឆ្ងាយណាស់។ ក្នុងមកបច្ចុប្បន្ននេះ បើគិតទៅវាចូល៣០ឆ្នាំជាងហើយ បាទ។

[១១:២៨:៤៦]

**ស៖** នៅក្នុងរបាយការណ៍នេះ មានការបញ្ជាក់ផងដែរថា មានវរសេនីយ៍ទោ ត្រូវបានអង្គការដកយកទៅថ្នាក់តំបន់។ តើលោកធ្លាប់ឮមានគេនិយាយថា អ្នកទោសត្រូវបានគេបញ្ជូនទៅតំបន់ទេ?

**ឆ៖** ក្នុងនោះ សូមជម្រាប អត់ដែលមានដឹងដែរបាទ មិនដឹងទៅតំបន់កន្លែងណា ខ្ញុំក៏អត់បានដឹងដែរបាទ។

**ស៖** កាលពីព្រឹកមិញនេះ លោកឆ្លើយថាគេមិនផ្តល់ថ្នាំទៅឲ្យអ្នកទោសទេ ហើយអ្នកទោសមិនអាចងូតទឹក ឬក៏លុបលាងខ្លួនបានទេ។ ខ្ញុំចង់អានឃ្លាមួយនៃសក្ខីកម្មមួយផ្សេងទៀត គឺនៅក្នុងសៀវភៅរបស់ អ៊ា ម៉េងទ្រី។ <គឺឯកសារ E3/2120 ភាសាអង់គ្លេស 00416390 ខ្ញុំសូមបញ្ជាក់ម្តងទៀត E3/2120 ហើយមានតែភាសាអង់គ្លេសទេ គឺ 00416390>។

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាតផ្តល់ឲ្យសហព្រះរាជអាជ្ញាបង្ហាញម្តងទៀត អ្នកបកប្រែស្តាប់មិនទាន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់លេខ ERN ឯកសារម្តងទៀតព្រោះអត់មានការបកប្រែភាសា។ អ្នកបកប្រែបកមិនទាន់។

[១១:៣០:៤២]

**សួរដោយលោក ឌេល លីសាក់៖**

ខ្ញុំសុំផ្តល់លេខឯកសារម្តងទៀតគឺឯកសារ E3/2120, ERN ជាភាសាអង់គ្លេស 00416390, ខ្ញុំសុំដកស្រង់៖ "សាំង ជាកម្មាភិបាលត្រាំកក់បានពន្យល់អំពីមូលហេតុនៃការស្លាប់ដោយសារជំងឺពីព្រោះថាអ្នកទោសទាំងអស់ហ្នឹងខ្សោយ ហើយអត់មានចំណីអាហារ និងមិនមានថ្នាំ ហើយនៅពេល

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលអ្នកទោសស្លាប់នៅក្នុងពេលយប់ កម្មាភិបាលខ្មែរក្រហមមិនបានយកសពចេញទៅភ្លាមៗទេ គឺគេទុកសាកសពរហូតទៅដល់ព្រលឹមឡើង ឬក៏ពេលរសៀលថ្ងៃស្អែក ទើបបានគេនាំយកចេញទៅដើម្បីយកទៅកប់ គឺនៅពេលដែលអ្នកទោសស្រាលហ្នឹងគាត់មកពីត្រឡប់មកធ្វើការវិញ”។ <លោកដើមបណ្ដឹងរដ្ឋប្បវេណី ថាតើនៅក្រាំងតាចាន់> អ្នកទោសឈឺ<ញឹកញាប់ដែរ ឬទេ?> តើ<ពួកគេធ្លាប់ទទួលបានការព្យាបាលដែរ ឬទេ?>

**ឆ៖** បាទ ក្នុងនោះគឺ បងប្អូនអ្នកទោសដែលជាប់នៅក្នុងនោះ គឺដូចមិនដែលមានឃើញផ្ដល់ថ្នាំពេទ្យឲ្យទេបាទ។

**ស៖** តើលោកដឹងអំពីចំនួនអ្នកទោសដែលស្លាប់ដោយសារជំងឺនៅក្រាំងតាចាន់ទេ?

**ឆ៖** ក្នុងបងប្អូនអ្នកទោសស្លាប់ហ្នឹង ខ្ញុំអត់បានដឹងទេបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចូលទៅប្រធានបទថ្មី។ អ៊ីចឹង តើលោកប្រធានសម្រាកសិន ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារង។

ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងលោក ញ៉ែម សំណាង ដែលជាបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញមកកាន់កន្លែងផ្ដល់សក្ខីកម្មរបស់សាក្សីនេះ នៅវេលាម៉ោងមួយនិងសាមសិបនាទីរសៀល ដោយពេលដែលគាត់ចាកចេញ មុនពេលដែលគាត់ចាកចេញឲ្យបិទវាំងននជាមុនសិន ហើយពេលចូលដូចគ្នា។ បានន័យថា បិទ -- នៅក្នុងអំឡុងពេលដែលវាំងននបិទ ឲ្យគាត់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្ម ហើយការអនុវត្តដូចគ្នានៅថ្ងៃនេះ និងថ្ងៃស្អែក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និង បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ជម្រាបសួរជាថ្មីម្តងទៀត។ មុនពេលចូលទៅប្រធានបទថ្មី ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្វីដែលលោកបានឆ្លើយកាលពីព្រឹកមិញនេះ។ លោកបានរៀបរាប់អំពីរបៀបគ្រួសាររបស់លោកត្រូវបានគេជម្លៀស ហើយទៅនៅ<ភូមិទទឹងថ្ងៃ>ជាមួយនឹង តា<ជេម> ដែលលោកនិយាយថាគាត់ហ្នឹង ជាមិត្តជាយូរមកហើយរបស់ តាអាន់ <ដែលជាមេគុកក្រាំងតាចាន់>។ លោកនិយាយអំពីភូមិទទឹងថ្ងៃ អ៊ីចឹងតើភូមិហ្នឹងជាភូមិតែមួយ ដែល<ជួនកាលគេ>ហៅថា ក្បាលអូរហ្នឹងមែនទេ? ហើយតើលោកដឹងទេថា <>តាអាន់ ដែលជាប្រធានគុកហ្នឹង <មកពីភូមិហ្នឹង>មែនទេ?

**លោក សួត្រ សាំង៖**

**ឆ៖** បាទ នៅក្នុងនោះគឺភូមិក្បាលអូរ ដោយឡែកភូមិទទឹងថ្ងៃដោយឡែក ប៉ុន្តែនៅឃុំជាងទងតែមួយទេបាទ។

**ស៖** អ៊ីចឹងតើលោកដឹងទេថាមេគុកក្រាំងតាចាន់ តាអាន់ ហ្នឹងគាត់<មកពីភូមិ>ណាដែរ?

**ឆ៖** ខ្ញុំគ្រាន់តែឮថាទេ ប៉ុន្តែខ្ញុំមិនដែលបានដឹងគាត់នៅភូមិក្បាលអូរ ហ្នឹងមិនដឹងភូមិក្បាលអូរហ្នឹងស្រុកកំណើតគាត់ ឬមួយផ្ទះប្រពន្ធគាត់ ឬមួយផ្ទះឪពុកម្តាយគាត់ពីមុនមកខ្ញុំមិនដឹងទេបាទ។

**ស៖** បាទ មិនអីទេ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីប្រធានបទផ្សេង។ ខ្ញុំនិយាយអំពីការសួរចម្លើយអ្នកទោស។ កាលពីព្រឹកមិញនេះ លោកឆ្លើយថាអ្នកទោសនៅក្រាំងតាចាន់ត្រូវបានគេសួរចម្លើយ

និងធ្វើទារុណកម្ម ជាពិសេសលោកនិយាយថាគេវាយ ហើយគេយកស្បោងផ្លាស្ទិកមកគ្របក្បាល។ តើលោកបញ្ជាក់បានទេថា បន្ទប់សួរចម្លើយហ្នឹងនៅកន្លែងណាដែរ បើធៀបទៅនឹងបរិវេណគុកនោះ?

[១៣:៣៤:០០]

**ឆ៖** ក្នុងនោះគឺកន្លែងសួរចម្លើយវានៅខាងត្បូងគុក វាពីខាងត្បូងគុក វាមានចម្ការដំឡូងមួយ។ ហួសពីចម្ការដំឡូងមកវាមានដំបូកមួយ ដំបូកនោះគេហៅដំបូកដើមពង្រ។ ដំបូកដើមពង្រហ្នឹង គឺរោងសួរចម្លើយហ្នឹងតែម្តងបាទ។

**ស៖** លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបង្ហាញជូនដើមបណ្តឹងរដ្ឋប្បវេណីនូវឯកសារមួយ គឺឯកសារ E3/5830 ឯកសារនេះគឺជាផែនទី ឬក៏ជាដ្យាក្រាមដែលបង្ហាញអំពី<បរិវេណគុក>ក្រាំងតាចាន់<ដែលរៀបចំដោយការិយាល័យសហចៅក្រមស៊ើបអង្កេត>។ ដូច្នេះ សូមការអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់លោកប្រធាន។ ហើយទោះបីជាគាត់មិនអាចអានបានក៏ដោយ ក៏ខ្ញុំគិតថាគាត់ប្រហែលជាអាចមើលរូបហ្នឹងយល់<ហើយអាចផ្តល់សក្ខីកម្មមួយចំនួន> លោកប្រធាន ព្រោះជារូបគំនូរទេ។ ដូច្នេះ សូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ពេលដែលលោកមើលផែនទីនេះ ខ្ញុំសូមអានចម្លើយរបស់លោក <វ៉ាន់ សឿន> ដែលជាអ្នកឃាមជាមួយលោក និងជាបងប្អូនជីដូនមួយរបស់លោក។ នេះជាអ្វីដែលគាត់បានឆ្លើយនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ គឺឯកសារ E1/271.1 នៅម៉ោង១០:៤០:០៦វិនាទី។ ខ្ញុំសូមដកស្រង់ “សំណួរ៖ តើមានចង្ក្រានបាយនៅជិតកន្លែងសួរចម្លើយអ្នកទោសទេ? ឆ្លើយ៖ បាទ ចង្ក្រានបាយហ្នឹងគឺនៅខាង<កើតកន្លែង>សួរចម្លើយ។ សំណួរ៖ តើអ្នកទោសហ្នឹងត្រូវបានគេសួរចម្លើយនៅទីកន្លែងបិទជិត ឬក៏មានកន្លែងច្រើន ហើយយើងអាចមើលឃើញទៅកន្លែងសួរចម្លើយហ្នឹង? ចម្លើយ៖ ថាជញ្ជាំងហ្នឹងមិនបិទជិតទេ មានប្រហោងយើងអាចមើលឃើញទៅដល់ខាងក្នុងបាន”។

ឥឡូវនេះ ខ្ញុំត្រឡប់មកផែនទី ឬក៏ដ្យាក្រាម<នៃបរិវេណមន្ទីរក្រាំងតាចាន់>នេះវិញ លោកដើមបណ្តឹងរដ្ឋប្បវេណី។ គឺយើងមើលឃើញឯកសារហ្នឹងហើយគឺលេខ E3/5830 នៅខាងក្រោមរូបភាពហ្នឹង <គឺគូសនៅកណ្តាលហ្នឹង> យើងឃើញមានផ្ទះមួយ។ ផ្ទះហ្នឹងគឺជារោងសួរចម្លើយហ្នឹងហើយ

ហើយនៅខាងស្ដាំមានអគារមួយដែលយើងកំណត់ថា ជាកន្លែងហូបបាយរបស់អ្នកយាម។ ដូច្នេះ ខ្ញុំចង់ដឹងថា តើរូបហ្នឹងត្រឹមត្រូវតាមអ្វីដែលលោកបានឃើញពាក់ព័ន្ធទៅនឹងកន្លែងសួរចម្លើយ ឬក៏ចង្ក្រានបាយដែលនៅជិតហ្នឹងទេ? វាដូចទៅនឹងអ្វីដែលលោកបានឃើញនៅពេលនោះទេ?

**លោក ស្វត្រ សាំង៖**

**ឆ៖** បាទ ដូចពិតមែន។

[១៣:៣៨:០៦]

**ស៖** ឥឡូវនេះ ខ្ញុំនឹងអាន<សម្រង់បន្ថែមមួយចំនួន>ជាថ្មីម្តងទៀតនូវសក្ខីកម្មរបស់អ្នកយាមម្នាក់ផ្សេងទៀត។ គឺលេខ D40/20, ជាភាសាខ្មែរគឺ 00165324, <ជាភាសាអង់គ្លេស> <0043 3573> ជាភាសាបារាំង <00524322> ស៊ីម គាត់បានឆ្លើយពាក់ព័ន្ធទៅនឹង<ការសួរចម្លើយ>អ្នកទោស។ នេះជាចម្លើយរបស់គាត់ "បើតាមអ្វីដែលខ្ញុំបានឃើញនោះគឺថា ខ្ញុំលួចមើលនោះគឺថា ឃើញគេសួរសំណួរ គេសួរចម្លើយ ហើយគេវ៉ៃអ្នកទោស ជួនកាលគេយកស្បោងមកគ្របក្បាល ហើយអ្នកខ្លះត្រូវគេវ៉ៃរហូតដល់ស្លាប់នៅកន្លែងសួរចម្លើយតែម្តង"។ សូមបញ្ចប់ការដកស្រង់។

ហើយបងប្អូនជីដូនមួយរបស់លោក លោក <វ៉ាន់ សឿន> នៅថ្ងៃទី០៤ ខែមីនា ឆ្នាំនេះគឺឯកសារ E1/271.1 នៅម៉ោង១០:៤២:<១៣>វិនាទី គេសួរគាត់ថា "តើគាត់ឯកភាពជាមួយ<ចម្លើយរបស់> ស៊ីម <ដែរ ឬទេ?> តើគាត់<ក៏>បាន<សង្កេតឃើញគេប្រើប្រាស់>ថង់ប្លាស្ទិក<នៅពេលសួរចម្លើយផងដែរ?>។ គាត់ឆ្លើយថា៖ បាទ គឺខ្ញុំដើរទៅចង្ក្រានបាយបីបួនដង ហើយខ្ញុំបានឃើញដូចដែរ ស៊ីម បានឃើញអ៊ីចឹងដែរ"។ បន្ទាប់មកទៀតគឺនៅថ្ងៃដដែលគឺនៅម៉ោង ១១:១៣:៤០វិនាទី គាត់ឆ្លើយថា "នៅក្នុងពេលសួរចម្លើយគេធ្វើទារុណកម្មអ្នកទោស មានដំបង មានរំពាត់ ហើយមានគល់ឫស្សី។ អ្នកទោសទាំងអស់នោះត្រូវគេយកស្បោងមកគ្របក្បាលឲ្យថប់<ដង្ហើម>នៅពេលគេសួរចម្លើយ<>"។ លោកខ្លួនឯងផ្ទាល់កាលពីព្រឹកមិញនេះ លោកនិយាយថា "នៅក្នុងពេលសួរចម្លើយ អ្នកទោសត្រូវបានគេវាយ ហើយគេយកថង់ ស្បោងយកមកគ្របក្បាល"។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកបានឃើញផ្ទាល់ភ្នែកទេ អំពីចំណុចទាំងអស់ហ្នឹង លោកពិតជាបានឃើញទេ នៅពេលដែលថាលោកធ្វើជាអ្នកយាម ហើយលោកនៅជិតចង្ក្រានបាយហ្នឹង លោកបានឃើញសកម្មភាពហ្នឹងផ្ទាល់ភ្នែកទេ?

[១៣:៤០:៤២]

**ឆ៖** បាទ ក្នុងហ្នឹងឃើញពិតមែន គេយកដំបងវាយសួរចម្លើយ និងយកថង់ប្លាស្ទិកមកដើម្បីឲ្យ

ថប់ដង្ហើម ឲ្យអ្នកទោសចេញជាចម្លើយឲ្យគេបាទ។

**ស៖** <វ៉ាន់ សឿន> បានផ្តល់សក្ខីកម្មនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ យើងនេះ គឺឯកសារ E1/271.1 នៅម៉ោង ១០:៣៨:៣១វិនាទី គាត់និយាយថា "ដំបងនិងរំពាត់ហ្នឹងត្រូវបានគេរក្សាទុកនៅកន្លែងសួរចម្លើយ"។ ហើយនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ គឺឯកសារ E1/257.1 នៅម៉ោង ១០:១១:០៧វិនាទី សយ សែន បានឆ្លើយទៅនឹងសំណួរមួយពាក់ព័ន្ធទៅនឹងការវាយអ្នកទោស។ គាត់ ឆ្លើយថា "គេប្រើគល់ឬស្សី ប្រវែង៦០ ទៅ ៧០ សង់ទីម៉ែត្រដើម្បីវាយអ្នកទោស។ ហើយមានគល់ឬស្សីប្រហែលជាបីបួនក្នុងបន្ទប់សួរចម្លើយ"។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកមានឃើញដំបងឬស្សី ឬក៏មានឃើញមានរំពាត់នៅកន្លែងសួរចម្លើយទេ?

**ឆ៖** បាទ ក្នុងនោះរំពាត់ គល់ឬស្សី ខ្ញុំបាទឃើញតែរំពាត់តូចទេ មិនមែនដល់គល់ឬស្សីទេ គឺគ្មានទាន់មានទេបាទ។ បាទ ឃើញត្រឹមរំពាត់យើងត្រឹមប៉ុនមេដៃ ឬប៉ុនមេជើងហ្នឹងទេ។ បើគល់ឬស្សីសម្រាប់វែងៗតែម្តងខ្ញុំអត់ដែលទាន់បានឃើញទេ បាទ។

**ស៖** លោកអាចជម្រាបបានទេថាអ្នកណាជាអ្នកដឹកនាំការសួរចម្លើយអ្នកទោសនៅក្រាំងតាចាន់នៅក្នុងពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** អ្នកសួរចម្លើយដាក់ទោសនៅក្រាំងតាចាន់ពេលនោះ គឺមានបីរូបជាប្រចាំនៅក្នុងហ្នឹងគឺមានតាអាន់មួយ តាពេញមួយ និងតាចេងមួយបាទ។

[១៣:៤៣:១៥]

**ស៖** អ្នកទាំងបីហ្នឹង គាត់មានរក្សាកំណត់ត្រាពាក់ព័ន្ធទៅនឹងព័ត៌មានដែលពួកគាត់ទទួលបានពីអ្នកទោសដែលៗពួកគាត់សួរចម្លើយហ្នឹងទេ?

**ឆ៖** ក្នុងកត់ត្រា មិនកត់ត្រា ខ្ញុំអត់ដឹងដែរពីព្រោះការសួរចម្លើយ ខ្ញុំមិនៗច្បាស់ពីព្រោះត្រង់ថាខ្ញុំអត់បានកត់ត្រាទុកជាមួយគាត់ទេ បាទ។

**ស៖** ឥឡូវនេះខ្ញុំនឹងអានឃ្លាមួយឲ្យលោកស្តាប់ គឺជាចម្លើយរបស់លោក ដែលលោកបានឆ្លើយនៅក្នុងឯកសារ E319.1.23 នៅចម្លើយ១០៨ "សំណួរ៖ តើអ្នកខាងមន្ទីរ ឬក្រុមទាហានហ្នឹង មានដែលសរសេរចម្លើយសារភាពអ្នកទោសដែលឬទេ? ចម្លើយ៖ អ្នកសួរចម្លើយគឺជាអ្នកសរសេរចម្លើយសារភាព"។ សូមបញ្ចប់ការដកស្រង់។ បន្ទាប់មកទៀត នៅក្នុងសៀវភៅដែលខ្ញុំបាននិយាយច្រើនដងមកហើយនៅព្រឹកមិញនេះ ដែលនិពន្ធដោយ អ៊ា ម៉េងទ្រី គឺឯកសារ E3/2120, នៅ ERN ជាភាសា

អង់គ្លេស 00416391។ នៅក្នុងសៀវភៅនេះគេមានលើកឈ្មោះរបស់លោក។ អ្នកនិពន្ធថា លោកជាអ្នកផ្តល់ព័ត៌មានដូចតទៅ ខ្ញុំសូមដកស្រង់ "ខ្មាំងដែលបក្សចាប់ ត្រូវបានដាក់ឃុំឃាំង បង្អត់អាហារ សួរសំណួរយ៉ាងគំហុក ហើយនិងធ្វើទារុណកម្មដើម្បីទទួលបានចម្លើយសារភាព។ ហើយជួនកាលគេជេរប្រមាថទៀត"។ <>អ៊ីចឹងតើលោកអាចបញ្ជាក់<អំពីភាពត្រឹមត្រូវ នៃចម្លើយទាំងពីរ ដែល>ខ្ញុំអានអម្បាញ់មិញនេះ <បានដែរ ឬ>ទេ?

**ឆ៖** សូមអត់ទោស ខ្ញុំស្តាប់ចម្លើយអត់ទាន់ច្បាស់ទេបាទ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំបានអានឃ្លាមួយដែលលោកបានសម្ភាសជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមជាតិស៊ើបអង្កេត លោកថាអ្នកសួរចម្លើយហ្នឹងកត់ត្រាចម្លើយសារភាព។ អ៊ីចឹងលោកបញ្ជាក់បានទេថាពិតជាមានអ៊ីចឹងទេអ្នកសួរចម្លើយហ្នឹងពេលដែលសួរហ្នឹងគឺគាត់កត់ត្រានូវចម្លើយសារភាពរបស់អ្នកទោស?

**ឆ៖** បាទ ពីព្រោះគេអ្នកសួរចម្លើយ ដូចប្រធានទាំងបី គាត់អ្នកកត់ អ្នកសួរខ្លួនគាត់ ខ្ញុំអត់ដែលបានទៅជិត ទៅបៀតទេបាទ។

[១៣:៤៦:២៤]

**ស៖** បាទលោកដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវខ្ញុំចូលទៅប្រធានបទផ្សេង។ ខ្ញុំនិយាយពីឯកសារ E3/289 – គឺE3/289, ERNជាភាសាខ្មែរ 01064303 ទៅដល់ 307, ជាភាសាអង់គ្លេស 00168509 ទៅដល់11, ជាភាសាបារាំង <01066907> ទៅដល់ 10។ ឯកសារនេះគឺជារបាយការណ៍នៃការផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យនៅខែកក្កដា ឆ្នាំ៧៧។ សេចក្តីប្រកាសនេះបានប្រកាសថា "មេដឹកនាំបានៗផ្តល់កិត្តិយសដល់ស្រុកត្រាំកក់ថាជាស្រុកគំរូ<មួយក្នុងចំណោមស្រុកគំរូទាំងបីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។>" អ៊ីចឹងខ្ញុំចង់សួរលោកថាលោកចាំទេថានៅឆ្នាំ១៩៧៧ តើលោកធ្លាប់ស្តាប់ឮថាស្រុកត្រាំកក់ត្រូវបានទទួលស្គាល់ថាជាស្រុកគំរូដែរឬទេ?

**ឆ៖** ក្នុងនោះខ្ញុំក៏អត់ដែលទាន់បានមានព័ត៌មានដឹងថាស្រុកត្រាំកក់គំរូ ស្រុកត្រាំកក់ហ្នឹងធ្វើជាឈានមុខគេយ៉ាងម៉េច ប៉ុន្តែគ្រាន់តែថាក្នុងនោះឃើញថារស់នៅអត់មានព័ត៌មានចូលដល់ផ្សព្វផ្សាយឲ្យខ្ញុំទេបាទ។

**ស៖** នៅក្នុងឯកសារE319.1.23 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក ចម្លើយ១១១ ដល់ ១១២ លោកបានឆ្លើយ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឃើញនីរសារកាន់សំបុត្រពី តាអាន់ ផ្ញើជូនទៅមន្ទីរ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រុក" ចុះមកក្រោមបន្តិចមក "ខ្ញុំគ្រាន់តែឃើញអក្សរនៅលើខ្នងសំបុត្រជូនចំពោះមន្ទីរស្រុក ខ្ញុំមិនបានដឹងពីខ្លឹមសារទេ" ខ្ញុំចង់ដឹងថាតើនីរសារ<នាំយក>សំបុត្រ<ពីក្រាំងតាចាន់> ទៅឲ្យមន្ទីរស្រុក<>ហ្នឹងញឹកញាប់ប៉ុនណាដែរ?

[១៣:៤៩:០៧]

**ឆ៖** នេះខ្ញុំក៏មិនបានពិតប្រាកដ គ្រាន់តែថាញឹកញាប់ មិនញឹកញាប់ ពីព្រោះខ្ញុំមិនសូវដែលបាននៅកន្លែងផងបាទ។

**ស៖** តើលោកចាំទេ អ្នកណាជានីរសារ? អ្នកណាដែរដែលលោកឃើញផ្ទាល់ភ្នែកថាបានកាន់សំបុត្រ<ក្រាំងតាចាន់>យកទៅប្រគល់ទៅឲ្យថ្នាក់ស្រុកនោះ?

**ឆ៖** បាទអ្នកដែលនីរសារមានតែមួយទេ មានកាលពីមុន មានៗមន្ទីរគេមួយ ប៉ុន្តែក្រោយមកពេលកងទ័ពចូលទៅហ្នឹងគេឲ្យទ័ពម្នាក់បញ្ចូលទៅជានីរសារមួយទៀត។ គឺ វ៉ាន់ ស៊ាន់ ហ្នឹងតែម្តងបាទរត់សំបុត្រ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំនឹងទៅពិភាក្សាប្រធានបទចុងក្រោយជាមួយលោក គឺនិយាយអំពីការសម្លាប់អ្នកទោសនៅក្រាំងតាចាន់។ នៅក្នុងឯកសារ E319.1.23 ជាកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ សំណួរ-ចម្លើយ៧៣ ទៅដល់៧៤ "សំណួរ៖ "<>តើលោកដឹងថានៅគុកហ្នឹងមានអ្នកទោសត្រូវបានគេសម្លាប់ទេ? បាទ មាន។ តើអ្នកណាជាអ្នកសម្លាប់ តើលោកអាចរៀបរាប់ឈ្មោះបានទេ? ឆ្លើយ៖ អ្នកដែលទទួលខុសត្រូវសម្លាប់គឺមនុស្សនៅក្នុងមន្ទីរ និងអ្នកមកពីស្រុក"។ នៅក្នុងឯកសារដដែល គឺចម្លើយទី៧៦ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "មុនពេលមានការសម្លាប់ខ្ញុំត្រូវបានចាត់តាំងឲ្យទៅយាមនៅជុំវិញកន្លែងហ្នឹង ចម្ងាយ៣០០ទៅ៤០០ម៉ែត្រ ពីកន្លែងសម្លាប់មនុស្ស"។ សំណួរទី១ របស់ខ្ញុំ ខ្ញុំចង់ដឹងថា តើគេឲ្យកម្មាភិបាលទៅយាមនៅពេលដែលសម្លាប់មនុស្សនោះ យាមនៅកន្លែងណា?

[១៣:៥១:៤០]

**ឆ៖** បាទ ដល់ពេលគេសម្លាប់មនុស្សហ្នឹង គេមុននឹងសម្លាប់ គេប្រាប់យើងឲ្យចេញទៅយាមខាងក្រៅ ពួកទ័ព ឲ្យខ្ញុំចេញទៅយាមខាងក្រៅ ប៉ែងខាង គេចែកទុកជាទិសដៅជាមុន កន្លែងគេយាមនីមួយៗ គឺមានមុខសញ្ញារៀងៗខ្លួន។ បើអ៊ីចឹងបរិវេណខាងក្រៅហ្នឹង គេឲ្យយាមខាងក្រៅពីកើត ពីជើង ពីត្បូង ពីលិច។ អ៊ីចឹងក្នុងហ្នឹង គេឲ្យខ្ញុំយាមខាងក្រៅហ្នឹង អ្នកមន្ទីរហ្នឹង គេអ្នកសម្លាប់បាទ។

**ស៖** នៅក្នុងឯកសារ D40/20, ERN ជាភាសាខ្មែរ 00165330, ជាភាសាអង់គ្លេស <00433569 ដល់70>, ជាភាសាបារាំង <00524318>។ ស៊ីម ជាមិត្តភក្តិរបស់លោក ដែលជាអ្នកយាមដែរនោះ គាត់បាននិយាយដូចតទៅ៖ “នៅពេលដែលអ្នកទោសត្រូវបានសម្លាប់នោះ គេបានឱ្យខ្ញុំយាមនៅខាងក្រៅរបងមន្ទីរក្រាំងតាចាន់ ដើម្បីកុំឱ្យមានអ្នកណាទៅជិតកន្លែងនោះ”។ គាត់ក៏បានឆ្លើយផងដែរថា គេមានរៀបចំកិច្ចប្រជុំដែលនៅក្នុងនោះ<ថ្នាក់ដឹកនាំ>គុក អាន់, ឌុច, ចេង និង ពេញ បានផ្តល់ព័ត៌មានទៅដល់កងរបស់លោក <>គាត់បានប្រាប់ថា៖ “ថ្ងៃនេះ យើងត្រូវនាំអ្នកទោសយកទៅសម្លាប់ចោល” ហើយបន្ទាប់មកគេចាត់តាំងឱ្យយើងទៅយាមខាងក្រៅ”។ ហើយម្យ៉ាងវិញទៀត បងប្អូនជីដូនមួយរបស់លោក <វ៉ាន់ សឿន> បានផ្តល់សក្ខីកម្មនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ E1/271.1 នៅម៉ោង ១០:៤៦:៥៥វិនាទី គាត់បានឆ្លើយថា -- គេសួរថា “អ្នកណាជាអ្នកកោះប្រជុំ ហើយនិងអ្នកជាប្រធានអង្គប្រជុំ នៅពេលមានការសម្លាប់មនុស្សនោះ? ចម្លើយថា តាអាន់”។ សូមបញ្ចប់ការដកស្រង់។

តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេថា តើកិច្ចប្រជុំទាំងអស់នោះត្រូវបានធ្វើឡើងនៅកន្លែងណា <នៃបរិវេណមន្ទីរក្រាំងតាចាន់ ដែលប្រធានគុករៀបចំកិច្ចប្រជុំទាំងអស់នោះ ដើម្បីប្រាប់អំពីកិច្ចការពាក់ព័ន្ធនឹងការសម្លាប់> គេប្រជុំនុ៎ង គេប្រជុំនៅកន្លែងណាដែរ?

[១៣:៥៤:១៨]

**ឆ៖** បាទ ក្នុងនោះ គេប្រជុំ លើកទិសដៅប្រជុំមានតែនៅកន្លែងចង្ក្រានបាយមួយទេ បាទ។

**ស៖** ដើម្បីឱ្យបានច្បាស់នោះ លោកនិយាយអំពីចង្ក្រានបាយរបស់អ្នកទោស ឬក៏ចង្ក្រានបាយរបស់អ្នកយាម?

**ឆ៖** ហ្នឹងចង្ក្រានបាយរបស់អ្នកយាមបាទ។

**ស៖** លោក សួត្រ សាំង តើលោកនិងអ្នកយាមផ្សេងទៀត ត្រូវបានតម្រូវឱ្យគោរពតាមបញ្ជាពីមេគុក អាន់ ដែរឬទេ?

**ឆ៖** បាទគឺទិសដៅតែ ឱ្យយាមខាងក្រៅ គឺគោរពតាមបទបញ្ជាបាទ។

**ស៖** ស៊ីម ដែលជាមិត្តភក្តិរបស់លោក នៅក្នុងឯកសារ D40/20, ជាភាសាខ្មែរ <00165 334> ដល់ <335>, ជាភាសាអង់គ្លេស 00433573, ជាភាសាបារាំង 00524323។ ស៊ីម បាននិយាយថា “នៅពេលការសម្លាប់មនុស្សនោះ ខ្ញុំឮគេចាក់មីក្រូ ឬក៏ចាក់ធុងបាស ហើយគេតែងតែប្រើ

អ្នកទោសឈ្មោះ សែន ឲ្យទៅចាក់ធុងបាស និងជីករណ្ដៅដើម្បីកប់សាកសពអ្នកទោសដែលត្រូវបានសម្លាប់ចោល គឺមានន័យថា សាកសពរបស់អ្នកទោស។ ហើយ<វ៉ាន់ សឿន បានផ្ដល់សក្ខីកម្ម>នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ E1/271.1 នៅម៉ោង ១១:៣៨:៤២វិនាទី គាត់បានឆ្លើយថា "គេចាក់មីក្រូ នៅពេលដែលគេសម្លាប់អ្នកទោស"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើគេ<>ពិតជាមានចាក់មីក្រូមែនទេ នៅពេលដែលមានការសម្លាប់អ្នកទោសនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:៥៧:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានៗ ប្រហែលជា<នឹង>បដិសេធជំទាស់របស់ខ្ញុំហើយ ក៏ប៉ុន្តែខ្ញុំគិតថាសំណួរហ្នឹងជាសំណួរនាំមុខ <>គេផ្ដល់ព័ត៌មានដូចជាយកព័ត៌មានទៅបញ្ចុកមាត់សាក្សីអ៊ីចឹង។ ហើយយករបស់ចម្លើយរបស់សាក្សីផ្សេងមកឲ្យគាត់ឆ្លើយថាអ៊ីចឹងៗមែន។ ហើយ<សហព្រះរាជាអាជ្ញា>គាត់ធ្វើអ៊ីចឹងតាំងពីព្រឹកមកហើយ ហើយឥឡូវរសៀលនេះ គាត់នៅតែបន្តធ្វើអ៊ីចឹងទៀត។ នេះមិនមែនជាវិធីសាស្ត្រត្រឹមត្រូវក្នុងការសួរសំណួរទេ។ ឥឡូវនេះ យើងកំពុងតែនិយាយអំពីការសម្លាប់អ្នកទោស។ អ៊ីចឹងយើងផ្ដល់<>នាទីឲ្យគាត់ ឆ្លើយ<>ទៅនឹងសំណួរ<បើក>ទៅ មិនត្រូវផ្ដល់ព័ត៌មានឲ្យគាត់ឆ្លើយតាមអ្វីដែលលោកប្រាប់នោះទេ។ នេះជាការមិនត្រឹមត្រូវទេ លោកប្រធាន។

[១៣:៥៨:១៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ នៅទីនេះយើងមានសិទ្ធិទាំងអស់គ្នាក្នុងការបង្ហាញភស្តុតាងជូនទៅសាក្សី <ហើយសួរអំពីប្រតិកម្មតបរបស់ពួកគាត់។> នេះជាវិធីសាស្ត្ររបស់មេធាវីការពារក្ដីផងដែរ គាត់ក៏ធ្វើអ៊ីចឹងដែរ។ <ហើយយើងបានចោទសួរជិតចប់ផ្នែកនៃសំណុំរឿងនេះហើយ។> យើងបានឮចម្លើយរបស់ អ្នកយាម និង<អ្នកទោស>មួយចំនួនមកហើយពាក់ព័ន្ធនឹងចំណុចនេះ។ ដូច្នេះ <យើង>ព្យាយាម<សរុបសក្ខីកម្មទាំងអស់ ហើយសុំមតិយោបល់ពីសាក្សីនៅសេសសល់។> ដូច្នេះ ខ្ញុំធ្វើនេះ<គឺមិនមានខុសអ្វីពីការចោទសួររបស់មេធាវីដទៃទៀតនៅក្នុងបន្ទប់សវនាការនេះទេ> គឺព្យាយាមទទួលបាននូវចម្លើយរបស់គាត់ ពាក់ព័ន្ធទៅនឹងការឆ្លើយរបស់សាក្សីផ្សេងទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតប<ដោយសង្ខេប លោកប្រធាន>។ តើអង្គជំនុំជម្រះមានបានចាំអំពីសេចក្តីសម្រេចរបស់ខ្លួនដែល គឺថាបានិយាយពីចំណុចនេះរួចម្តងហើយ និយាយអំពី<ទីតាំងឧក្រិដ្ឋកម្ម>ទួលពោធិ៍ជ្រៃ។ នៅពេលដែលយើង<កំពុងតែចូលមកដល់ផ្នែកមួយ ដែលយើង>និយាយអំពី<ការឃើញ>ឧក្រិដ្ឋកម្មនោះ<ពិតប្រាកដមែន> យើងត្រូវចាប់ផ្តើមសួរសំណួរបើកទូលាយ។ ហើយប្រសិនបើសាក្សី<ឬដើមបណ្តឹងរដ្ឋប្បវេណី> គាត់មិនចាំទេ នៅពេលចុងក្រោយនោះ <គឺគាត់អាចត្រូវសួរដេញដោលផ្ទួញ ប៉ុន្តែនេះ វាកំពុងតែធ្វើរឿងផ្ទុយហើយ។> មិនត្រូវធ្វើបង្ហាញភស្តុតាងមុនហើយ បានសួរឲ្យសាក្សីឆ្លើយទេ។ ធ្វើអ៊ីចឹងគឺបញ្ច្រាសលំដាប់លំដោយហើយ។

[១៣:៥៩:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០០:៣០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តី គឺលើកឡើងមានមូលហេតុសមស្រប ដែលសំណួរគប្បីតាំងសំណួរបើក សំណួរទូទៅជាមុនសិន ហើយសំណួរបែបនេះគឺនឹងអាចទៅសួរនៅពេលចុងក្រោយ នៅពេលណាមួយដែលសមស្រប ដែលចុងក្រោយបាន។ ដូច្នេះ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ ហើយសូមតំណាងសហព្រះរាជអាជ្ញាអន្តរជាតិរៀបចំនូវសំណួរបន្ថែមថ្មីទៀត ហើយសុំមានលក្ខណៈជាសំណួរបើក។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងអនុវត្តតាម សុំចាប់ផ្តើមសួរបន្ត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំ លោកដើមបណ្តឹងរដ្ឋប្បវេណី តើមានមីក្រូហ្វូននៅគុកក្រាំងតាចាន់ទេ? ហើយបើមានហ្នឹងតើគេប្រើប្រាស់មីក្រូហ្នឹង គឺគេប្រើប្រាស់មីក្រូដើម្បីធ្វើអ្វីដែរ?

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ក្នុងទីនោះ តាំងពីខ្ញុំចូលទៅដល់គឺមិនដែលឃើញមានមីក្រូហ្វូន មីក្រូចាក់ទេបាទ។

**ស៖** លោកមានបានដឹងអ្នកទោសមួយចំនួនដូចជា សយ សែន ត្រូវបានគេបញ្ជាឲ្យជីករណ្តៅ

និងកប់សាកសពអ្នកទោសដែរទេ?

**ឆ៖** បាទ សយ សែន ជារឿងរបស់គាត់ មិនមែនទាក់ទាមជាមួយខ្ញុំទេ បាទ។

[១៤:០២:២៥]

**ស៖** លោកបានផ្តល់សក្ខីកម្មឆ្លើយនៅក្នុងចម្លើយលេខ៨០ នៅក្នុង <E319.1.23។ លោកបាននិយាយថា៖ “សាកសពត្រូវបានគេកប់នៅក្នុងកន្លែងសម្លាប់។” បញ្ចប់ការដកស្រង់។> តើទីតាំងសម្លាប់មនុស្សហ្នឹងស្ថិតនៅកន្លែងណាដែរ? <តើនរណាជាអ្នកកប់សាកសពនៅទីនោះ>ដែរ?

**ឆ៖** បាទ ពីព្រោះទីតាំងសម្លាប់មនុស្ស គឺនៅខាងត្បូងកន្លែងសួរចម្លើយ បាទ។

**ស៖** តើអ្នកណាជាអ្នកចាត់តាំងឲ្យជីករណ្ដៅ និងកប់សាកសពអ្នកទោសដែលគេបានសម្លាប់ហើយហ្នឹង?

**ឆ៖** ក្នុងនោះមានតែអ្នកមន្ទីរគេទេបាទ។

**ស៖** កាលណាលោកនិយាយពីបុគ្គលិកមន្ទីរហ្នឹង តើលោកចង់និយាយសំដៅទៅលើអ្នកណាហ្នឹង?

**ឆ៖** នៅមន្ទីរគេវាមានមន្ទីរគេ វាមានប្រធានវាបី ហើយនិងអ្នកមន្ទីរៗៗដូចគេខាងពួកយុវកកបក្ខជន ខាងក្រុមឈ្លប ហ្នឹងគឺពួកមន្ទីរគេ បាទ។

**ស៖** ដើម្បីបញ្ជាក់អំពីចំណុចនេះ ខ្ញុំសុំដកស្រង់ពីចម្លើយរបស់អ្នកយាមម្នាក់ឈ្មោះ ស៊ឹម។ គាត់បានផ្តល់សក្ខីកម្មជាច្រើនលើកសាថា អង្គភាពរបស់គាត់ហ្នឹងគឺត្រូវបានចាត់តាំងនេះ ឲ្យទៅកប់រណ្តៅ<សាកសពដែលត្រូវបានគេសម្លាប់> គឺឯកសារ D40/20, ERN ខ្មែរគឺ 00165334, អង់គ្លេស 00433573 និងបារាំង 00524323។ <គេសួរ>គាត់<>ថា<តើ>អង្គភាពរបស់គាត់គឺត្រូវបាន<ចាត់តាំង>ឲ្យកប់<សាកសពញឹកញាប់ទេ ហើយគាត់ឆ្លើយថា> “នៅក្នុងរយ:ពេលជាច្រើនខែ ជួនកាលគឺគេឲ្យយើងកប់១ខែម្តង ជួនកាល<ពីរ>ដង <ហើយខែខ្លះអត់មានទេ>”។ បញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបានទេ ថាតើ<>អង្គភាពរបស់ស៊ឹម គឺអង្គភាពមួយដែលត្រូវបានចាត់តាំងឲ្យទៅកាយដីកប់រណ្តៅដែលគេកប់សាកសពដែលគេបានសម្លាប់ហើយនោះ?

**ឆ៖** បាទ កាលនោះខ្ញុំអត់បានទៅកប់សាកសពនៅកន្លែង ទីកន្លែងនោះបាន ដោយសារខ្ញុំមិនបាននៅខាងក្នុងទេបាទ។

**ស៖** តើ ស៊ឹម ស្ថិតនៅក្នុងអង្គភាពរបស់អ្នកណាដែរ?

**ឆ៖** ស៊ីម ស្ថិតនៅក្នុងកងទ័ពដូចពួកខ្ញុំដែរ ក៏ប៉ុន្តែកងទ័ពនោះវាមានគេនៅក្នុងច្រើនជាងខ្ញុំ។ ខ្ញុំនៅខាងក្រៅច្រើនជាងគេនៅខាងក្នុងដែរ។

**ស៖** សំណួរបន្ទាប់របស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងថាតើ អ្នកទោសត្រូវបានគេសម្លាប់ដោយរបៀបណាដែរនៅឯក្រាំងតាចាន់។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើអ្នកទោសត្រូវបានគេសម្លាប់ដោយរបៀបណាដែរនៅឯកន្លែងទីតាំងសម្លាប់មនុស្សហ្នឹង?

**ឆ៖** បាទ នៅក្នុងក្រាំងតាចាន់ សម្លាប់មនុស្ស គេសម្លាប់ដោយនឹងត្បូងចប ឬនឹងគល់ឫស្សីបាទ។

[១៤:០៧:០៥]

**ស៖** តើលោកបានដឹងថា អ្នកទោសត្រូវបានគេសម្លាប់របៀបអ៊ីចឹង លោកដឹងមកពីណា?

**ឆ៖** ពីព្រោះខ្ញុំបានដឹង ពីព្រោះខ្ញុំបានឃើញខ្លះ មិនមែនបានឃើញរាល់ថ្ងៃទេ។ ថ្ងៃណាដែលខ្ញុំទៅឃើញ គឺខ្ញុំលួចមើលទៅ អាហ្នឹងឃើញបាន។ បើថ្ងៃណាគេវិន័យគេតឹងតែង ខ្ញុំក៏បាននៅឆ្ងាយបាទ។

**ស៖** នៅពេលដែលលោកធ្វើជាអ្នកយាម គឺ<ដែលលោកថាឃើញ>គេសម្លាប់នោះ ពេលដែលលោកធ្វើជាអ្នកយាមនៅហ្នឹង ឬក៏អត់ទេ?

**ឆ៖** បាទ នៅទីកន្លែងនោះ ជួនកាលខ្ញុំបាទយាមខ្លះ ជួនកាលខ្ញុំបាទទៅរកត្រីខ្លះបាទ។

**ស៖** ប្រធានបទចុងក្រោយដែលខ្ញុំចង់សួរលោកនៅថ្ងៃនេះ គឺពាក់ព័ន្ធទៅនឹងការសម្លាប់ក្មេងៗ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកគឺ E319.1.23 នៅត្រង់ចម្លើយ៩០ គឺថាលោកត្រូវបានសួរដូចតទៅ សូមដកស្រង់៖ “តើលោកបានដឹងអំពីការសម្លាប់កុមារ និងទារកនៅមន្ទីរក្រាំងតាចាន់ដែរឬទេ? ឆ្លើយ៖ មានកុមារត្រូវបានគេសម្លាប់”។ បញ្ចប់ការដកស្រង់។ ហើយព្រឹកមិញនោះ លោកបានឆ្លើយនិងជម្រាបជូនអង្គជំនុំជម្រះថា កុមារនិងកូនង៉ែតហ្នឹងគឺគេយកទៅដាក់ គេយកទៅជាមួយម្ដាយ<ឪពុក>ៗនៅគុកនោះដែរ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ឆ្មាំគុកបីនាក់នៅក្រាំងតាចាន់ហ្នឹងក៏បានបញ្ជាក់ថា អ្នកទោសត្រូវបានគេសម្លាប់នៅទីតាំងនោះរួមមានកុមារ។ ស៊ីម <>និងឈ្មោះ ស្រី ថន ហៅ ឌុចតូចហ្នឹង ហើយនិងជីដូនមួយរបស់លោក <វ៉ាន់ សឿន>។ តើលោកដឹងថា ក្មេង កុមារៗ និងក្មេងតូចៗហ្នឹងគេសម្លាប់នៅក្រាំងតាចាន់ លោកបានដឹងដោយរបៀបណាដែរ?

**ឆ៖** បាទ សម្លាប់នៅក្នុងក្រាំងតាចាន់ កុមារ ក្មេងតូចនេះ គឺខ្ញុំដឹងតាមរយៈ ធម្មតាតែបាត់ម្ដាយបាត់កូន បើបាត់កូនពិតជាសម្លាប់ហើយ។ បាទ ខ្ញុំដឹងតាមរយៈប៉ុណ្ណឹងទេបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១០:១២]

**ស៖** ឯកសារមួយក្នុងចំណោមឯកសារ<ជាច្រើន>ដែលយកមកប្រើប្រាស់ ជាភស្តុតាងក្នុងសំណុំរឿងនេះ គឺ E3/4093 ដែល ERN ជាភាសាខ្មែរ 00270786 ដល់ 87, អង់គ្លេស 00831486, និង ERN ជាភាសាបារាំង 00729674។ នេះគឺជាសំបុត្រមួយ -- លិខិតមួយច្បាប់មកពីលេខាស្រុកត្រាំកក់ឈ្មោះ តាសាន ដែលណែនាំថាក្មេងៗដែលក្មេងពេកមិនអាចបំបែកចេញពីម្តាយរបស់គេ នៅពេលម្តាយ ឪពុក ម្តាយរបស់គេត្រូវបានចាប់ខ្លួន។ សូមដកស្រង់៖ "យកគេចូលមកសួរចម្លើយ ហើយក្រោយពីអ្វីៗបានរួចរាល់ហើយ គឺគេបោសសម្អាតទាំងអស់តែម្តងទៅ"។ បញ្ចប់ការដកស្រង់។ នៅពេលដែលគាត់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះនៅថ្ងៃទី១០ ខែមីនា ២០១៥ គឺឯកសារ E1/274.1 តាសាន បានទទួលស្គាល់ថា គាត់បានសរសេរលិខិតហ្នឹង ហើយនិងបានផ្តល់សក្ខីកម្មថា គាត់បានធ្វើនេះគឺអនុវត្តទៅតាមសេចក្តីណែនាំរបស់លេខាតំបន់<>។ លោកបានឆ្លើយថាក្មេងៗត្រូវបានគេសម្លាប់<>។ សំណួររបស់ខ្ញុំថាតើ គេមាន -- តើមេគុក អាន់ នេះបានបញ្ជាឆ្មាំគុកឱ្យសម្លាប់កុមារៗក្មេងៗ ឬក៏អត់? ហើយថាតើគាត់<ធ្លាប់និយាយ ថាគាត់>ទទួលបញ្ជានេះមកពីលេខាស្រុកត្រាំកក់នោះដែរឬក៏អត់ទេ?

[១៤:១១:៥៧]

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានជាថ្មីម្តងទៀតហើយ <សហព្រះរាជអាជ្ញាបានប្រាប់ចម្លើយទៅឱ្យសាក្សីហើយចង់ឱ្យសាក្សីឆ្លើយដូចចម្លើយនោះ> មិនមានសញ្ញាណណាមួយ<ដែលថា>សាក្សីនេះ<បានដឹងពីឯកសារ ឬសក្ខីកម្មនេះទេ។> ការដែល<ទទួល>បានចម្លើយ<និងយោបល់>ពីសាក្សីដោយសួររបៀបនេះគឺ<វាឥតប្រយោជន៍នោះ>ទេ។ ខ្ញុំថាការប្រើ<វិធីសាស្ត្រ>ដើម្បីសួរសំណួរនេះគឺមិនត្រឹមត្រូវទេ។ ដូច្នេះ ខ្ញុំសូមបដិសេធជាដាច់អហង្ការតែម្តង។ <វាគឺជាសំណួរនាំមុខខ្លាំងណាស់។>

**លោក ឌេល លីសាក់៖**

ខ្ញុំ<មិនយល់ស្របនោះទេ។ នៅក្នុងសាលសវនាការនេះ> យើង<ត្រូវបាន>អនុញ្ញាតឱ្យបង្ហាញភស្តុតាងទៅដល់ភាគី <-- គឺទៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនេះ>។ នេះគឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាចំណែកមួយនៃភស្តុតាងដែលបានទទួលស្គាល់។ ដើម្បីបណ្ដឹងរដ្ឋប្បវេណីនេះបានរៀបរាប់ថា គាត់បានដឹងអំពីការសម្លាប់ក្មេងៗ និងកុមារ។ ដូច្នេះ ខ្ញុំ<មានសិទ្ធិក្នុងការប្រើប្រាស់ភស្តុតាងនេះ ដើម្បី>សួរសំណួរនេះនៅចំពោះមុខអង្គជំនុំជម្រះដើម្បីបញ្ជាក់អំពីភស្តុតាងមួយនេះ។ គឺការសួរនេះ គឺដោយសំអាងទៅលើលិខិតមួយច្បាប់នេះឯង។ គឺថាតើសាក្សីនេះដឹងថា <>ការណែនាំ<នៅក្នុងលិខិតហ្នឹង ត្រូវបានដាក់ឲ្យប្រើនៅក្នុងគុកហ្នឹង>ដែរឬទេ តាមរយៈលិខិតមួយនេះ។ គោលបំណងនៃ<>រៀបរាប់អំពីលិខិត<ហ្នឹង ហើយនិងការតាំងសំណួរនេះ>។

[១៤:១៣:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៤:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះចាត់លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើសេចក្ដីជំទាស់របស់មេធាវីការពារក្ដីចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ក្នុងករណីនេះ គឺការជំទាស់គឺត្រូវបានបដិសេធ។ <មូលដ្ឋានគ្រឹះមួយត្រូវបានផ្អែក>។ ដោយ-សារ<>ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ហើយថាគាត់បានដឹងអំពីការសម្លាប់កុមារនិងក្មេងៗ។ ក្នុងករណីនេះគឺយើងសួរតទល់<>គាត់<ជាមួយនឹងចម្លើយហ្នឹង>។ ការសួរតទល់បែបនេះគឺថាអនុញ្ញាតឲ្យសួរបាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមសួរឡើងវិញ។ សំណួររបស់ខ្ញុំថា តើឆ្មាំគុកក្រាំងតាចាន់ ត្រូវបានបញ្ជាដោយមេគុកឈ្មោះ អាន់ ដែលថាក្មេងៗក៏ត្រូវសម្លាប់ជាមួយនឹងឪពុកម្ដាយរបស់គេ ហើយថាតើ អាន់ នេះដែលប្រាប់ទៅឆ្មាំគុកក្រាំងតាចាន់ថាគាត់បានទទួលការណែនាំបែបនេះមកពីលេខា<>ស្រុកត្រាំកក់ហ្នឹងដែរឬទេ?

**លោក ស្វូត្រ សាំង៖**

**ឆ៖** បាទ ក្នុងនោះខ្ញុំក៏អត់បានដឹងដែរ រឿងទទួលផែនការពីលេខាស្រុក ឬមួយផែនការសម្លាប់

យ៉ាងហ្នឹង ខ្ញុំអត់ដែលទទួលបានដឹងទេ ពីព្រោះអាហ្នឹងអ្នកធំហើយអ្នកធំ គេអ្នកទាក់ទងគ្នាទេបាទ។

[១៤:១៦:២៣]

**ស៖** ផ្នែកចុងក្រោយដែលខ្ញុំចង់សួរទៅលោក គឺខ្ញុំសូមអានឲ្យលោកស្ដាប់នូវចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានឆ្លើយពាក់ព័ន្ធទៅនឹងលោក។ ហើយខ្ញុំសូមផ្ដល់ឱកាសឲ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់ សយ សែន។ នៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំនេះគឺឯកសារ E1/256.1, នៅម៉ោង<១៣:៣៧:៣៣>, សយ សែន បានរៀបរាប់ថាបានឃើញការសម្លាប់ក្មេងៗតូចៗពីរនាក់នៅឯក្រាំងតាចាន់។ សូមដកស្រង់៖ "មានរណ្ដៅតូចមួយនៅខាងត្បូងដើមត្នោត គេសម្លាប់ក្មេងតូចមួយមុន ដោយបោកផ្ទប់ទៅនឹងគល់ត្នោត ហើយបន្ទាប់មកគេ<យកក្មេងធំដែលជាបងប្អូនបង្កើត ដោយ>ប្រើចបវាយបំបាក់កក្មេងនោះតែម្ដង"។ បញ្ចប់ការដកស្រង់។ ហើយនៅថ្ងៃទី០៥ កុម្ភៈ គឺឯកសារ E1/257.1 នៅម៉ោង ១០:៤០:៤៦ និងនៅម៉ោង ១១:២១:៥៥, សយ សែន បាននិយាយថាលោកគឺជាអ្នកយាមម្នាក់ក្នុងចំណោមអ្នកយាមដែលបានពាក់ព័ន្ធ ឬក៏មានវត្តមានក្នុងពេលសម្លាប់ក្មេងៗទាំងពីរនាក់នេះ"។ សំណួររបស់ខ្ញុំគឺសួរថា តើលោកអាចឆ្លើយជម្រាបជូនអង្គជំនុំជម្រះថា<តើ>អ្នកយាម<ណាដែលបានចូលរួមក្នុងការ>សម្លាប់ក្មេងៗនៅឯក្រាំងតាចាន់ហ្នឹងបានដែរឬទេ?

[១៤:១៨:០៣]

**ឆ៖** បាទ ក្នុងនោះខ្ញុំសូមចម្លើយ គឺខ្ញុំថា ក្នុងសម្លាប់ក្មេងៗ ពីព្រោះទីតាំងនៅកន្លែងក្រាំងតាចាន់នេះគឺគ្មានដើមត្នោតទេបាទ ត្រង់សម្លាប់ទីកន្លែងណា ឬ សយ សែន គាត់ឃើញនៅកន្លែងណាគឺជារឿងរបស់គាត់បាទ។

**ស៖** ខ្ញុំសួរវិញថា តើមានដើមត្នោតនៅខាងក្រៅបរិវេណគុកហ្នឹងដែរទេ?

**ឆ៖** ក្នុងគុកហ្នឹងគឺគ្មានដើមត្នោតទេបាទ មានៗតែឆ្ងាយពីហ្នឹងបាទ។

**ស៖** ចុះលោកមានដឹងថា គេមានធ្វើទឹកត្នោតដើម្បីយកទៅឲ្យមេគុកហ្នឹងផឹក ហើយនិងទៅឲ្យុះ<កម្មាភិបាលផ្សេងទៀត ដែលនៅគុក>ហ្នឹងផឹកដែរទេ?

**ឆ៖** បាទ ទឹកត្នោតមានធ្វើៗ មានភូមិខាងជើងហ្នឹង និងភូមិខាងលិច ឆ្ងាយបាទ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ លោកដើមបណ្ដឹងរដ្ឋប្បវេណីអំពីការសម្លាប់ក្មេងៗគឺជាបទពិសោធន៍មួយគួរឲ្យតក់ស្លុតរន្ធត់បំផុតនៅក្រាំងតាចាន់។ លោកមានចាំថាមានក្មេងៗណាខ្លះត្រូវបានគេយកចេញទៅហើយសម្លាប់ចោលដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ក្នុងនោះ ខ្ញុំសូមជម្រាបដូចជម្រាបតុលាការជ្រាបថា គឺកន្លែងនោះសម្លាប់ឪពុកបាត់ក្មេង សម្លាប់ ម្ដាយទៅជាមួយក្មេងបាទ។

[១៤:២០:២៣]

**លោក ឌេល លីសាក់៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី អរគុណណាស់ដែលបានឆ្លើយទៅនឹងសំណួរទាំងឡាយរបស់ខ្ញុំ។ ខ្ញុំអស់សំណួរហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្ដទៅនេះ អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីដែលចង់សួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ!

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរតិចតួចទេ។ ទី១ គឺអំពីមីក្រូនៅឯគុកក្រាំងតាចាន់។ លោកបាននិយាយថា លោកអត់មានបានឃើញថាមានមីក្រូទេនៅទីនោះ។ តើលោកធ្លាប់ឮសូរគេចាក់ភ្លេងឮៗ ឬក៏គេប្រកាសឮៗនៅក្នុងបរិវេណក្រាំងតាចាន់ហ្នឹងដែរទេ?

**លោក ស៊ូត្រ សាំង៖**

**ឆ៖** បាទ នៅក្នុងនោះ ខ្ញុំតាំងពី -- ក្រៃងពីមុនមកខ្ញុំមិនបានដឹងទេ។ តែត្រឹមតែខ្ញុំចូលមកក្នុងថ្ងៃខ្ញុំចូលមកដល់ គឺអត់ដែលមានក្បាលមីក្រូ ឬមីក្រូចាក់បំពងនៅក្នុងនោះទេបាទ។

**ស៖** សូមសួរបញ្ជាក់ ដើម្បីបញ្ជាក់ថាមិនមែនជាការបកប្រែខុសឬក៏អត់។ សំណួរសួរថាមានមីក្រូឬក៏អត់? ហើយថាតើធ្លាប់ឮគេចាក់មីក្រូនៅបរិវេណហ្នឹងដែរឬក៏អត់ <មិនថាឮចេញពីណាក៏ដោយ>?

**ឆ៖** បាទ ក្នុងនោះ ខ្ញុំអត់បានដែលមានមីក្រូចាក់ក្នុងទីកន្លែងនោះទេបាទ។

[១៤:២២:០៤]

**ស៖** ជាថ្មីម្ដងទៀត។ តើលោកធ្លាប់ឮសូរគេចាក់ភ្លេង ឬក៏ថាចាក់ចម្រៀងឮៗអីទេនៅឯក្រាំងតាចាន់? ឥឡូវថាមិនមានមីក្រូក៏ថាទៅចុះ ប៉ុន្តែធ្លាប់ឮគេចាក់ភ្លេងឬក៏ចម្រៀងឮៗទេ?

**ឆ៖** បាទ ក្នុងនោះដែលខ្ញុំធ្លាប់ឃើញ អាហ្នឹងផ្ទាល់ភ្នែករបស់ខ្ញុំ មានអាម៉ាញ៉ៀគេដាក់ -- អាម៉ា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ញ៉ូមួយដែលគេហៅអាម៉ាញ៉ូចាក់កាសែតយើងធម្មតាចាក់ចម្រៀងៗ គេថាចម្រៀងកសិករជំនាន់នោះខ្ញុំក៏ដូចភ្លេចដែរចម្រៀងហ្នឹង គេហៅថាចម្រៀងកសិករជីកប្រឡាយលើកទំនប់ហ្នឹង។ បាទ ចម្រៀងហ្នឹង ម៉ាញ៉ូហ្នឹងវាម៉ាញ៉ូគេហៅវាអីទេ អារអូសកាសែតមួយ របស់ជប៉ុនម៉ាញ៉ូហ្នឹង បាទប៉ុន្តែឈ្មោះវាខ្ញុំបាទអត់បានស្គាល់ហ្នឹងមានចាក់មែនបាទ។ បាទ តែចំពោះមីក្រូគ្មានទេបាទ។

**ស៖** តើ<ម៉ាញ៉ូចាក់>កាសែត<>ហ្នឹង <>នៅឯណា?

**ឆ៖** បាទ កាសែតហ្នឹងគេចាក់ត្រង់កន្លែងៗគេចាក់ស្តាប់ធម្មតា ដូចចាក់នៅក្នុងអាកន្លែងផ្ទះមេគេសម្រាន្ត នៅក្នុងកន្លែងផ្ទះមេគេសម្រាន្តនៅក្នុងអាបន្ទប់គេធ្វើខ្ទមួយនៅក្រោមដើមពង្រហ្នឹងបាទ។

**ស៖** តើ<>ម៉ាញ៉ូ<ចាក់កាសែត>ហ្នឹង មានម៉ាញ៉ូតែមួយទេ ឬក៏មានម៉ាញ៉ូច្រើន?

**ឆ៖** បាទ ម៉ាញ៉ូនោះមានតែមួយទេបាទ ក្នុងកន្លែងនោះមានតែមួយទេបាទ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា ម៉ាញ៉ូហ្នឹងពីលោកស្តាប់ឮហ្នឹង ពីកន្លែងគេចាក់ម៉ាញ៉ូមកកន្លែងលោកស្តាប់ហ្នឹងចម្ងាយប៉ុន្មាន? ១ម៉ែត្រ ២ម៉ែត្រ ១០ម៉ែត្រ ៣០ម៉ែត្រ ចម្ងាយប៉ុនណាដែរពីកន្លែងចាក់ម៉ាញ៉ូមកកន្លែងលោកស្តាប់ហ្នឹង?

**ឆ៖** ដែលចម្ងាយពីកន្លែងចាក់ម៉ាញ៉ូហ្នឹង បើគិតជាមន្ទីរគុកហ្នឹងអាកន្លែងដាក់អ្នកទោសហើយនិងចង្ក្រានបាយ វាមិនឆ្ងាយប៉ុន្មានទេ ដីប្រហែលជា ៣០-៤០ម៉ែត្រតែប៉ុណ្ណោះទេបាទ។

[១៤:២៤:៣៨]

**ស៖** <បើ>ខ្ញុំយល់<>លោកមិនច្រឡំទេ លោកអាចឮភ្លេងគេចាក់ម៉ាញ៉ូពី៣០ទៅ៤០ម៉ែត្រ គឺថាលោកឮបាន។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ឮបាន។

**ស៖** ឥឡូវខ្ញុំឈប់សួរអំពី -- ឈប់ៗសួរអំពីម៉ាញ៉ូនេះហើយ។ ខ្ញុំសួរអំពីការរំលោភ ព្រោះខ្ញុំយល់មិនទាន់បានច្បាស់ទេ តាមរយៈចម្លើយរបស់លោក វាអាចដោយសារការបកប្រែទៀតហើយ។ ឥឡូវនេះ គឺថាសួរឲ្យងាយយល់ទៅចុះ។ សំណួរទី១របស់ខ្ញុំ លោកដឹងទេ នៅពេលដែលលោកធ្វើការនៅក្រាំងតាចាន់ តើមានមនុស្សណាម្នាក់ដែលនៅឯក្រាំងតាចាន់ហ្នឹង ត្រូវបានគេរំលោភដែរទេ មានស្ត្រីណាម្នាក់នៅក្រាំងតាចាន់ត្រូវបានគេរំលោភទេ?

**ឆ៖** បាទ ក្នុងនោះខ្ញុំអត់ដែលបានឃើញទេបាទ។

**ស៖** អ៊ីចឹង ប្រហែលជាមានន័យថាលោកមិនដែលបានឃើញ ប៉ុន្តែលោកធ្លាប់ឮទេ? ធ្លាប់ឮអំពី

រឿងរ៉ាវចាប់រំលោភ ឬក៏ការប៉ះពាល់ផ្លូវភេទណាមួយ ដោយរបៀបណាមួយទេ? ធ្លាប់ឮទេ?

**ឆ៖** អានេះធ្លាប់ឮហើយ ធ្លាប់ឃើញ សាកសួរគាត់បណ្ដើរធ្វើការជាមួយគាត់បណ្ដើរ ដូចជាខ្ញុំរាយការណ៍ជូនខាងដំបូងអ៊ីចឹង គឺមកពីកងខាងក្រៅ ដូចជាកងយុវជន កងនារី វាខូចសីលធម៌ពីមុនមក គេចាប់យកមកហ្នឹង អាហ្នឹងអាចមានបាទ។

[១៤:២៦:៣៩]

**ស៖** ខ្ញុំមិនចង់ឲ្យមានភាពច្របូកច្របល់ទេ ឥឡូវសួរមួយដំណាក់កាលម្ដងៗ។ តើមានអ្នកណាម្នាក់ប្រាប់លោកអំពីការប៉ះពាល់ដល់ផ្លូវភេទទេ? បើមានតើអ្នកណាជាអ្នកដែលបានប្រាប់លោកហ្នឹង?

**ឆ៖** បាទ ក្នុងនោះគឺអត់មានទេបាទ។ មិនដែលមានពីណាប្រាប់ខ្ញុំថាអ្នក -- ប្រាប់ខ្ញុំថាខូចសីលធម៌ ពួកមន្ទីរហ្នឹងខូចសីលធម៌ជាមួយអ្នកទោស គឺអត់ដែលមានទេ។ មានដូចខ្ញុំជម្រាបប្រាប់ជូនៗអស់លោកកាល ថាមានឃើញកងយុវជន កងនារីពីខាងក្រៅ។ បានន័យថា ពីខាងក្រៅមន្ទីរហ្នឹងវាខូចនៅខូចសីលធម៌ពីខាងក្រៅចូលមក គេយកមកអប់រំខាងក្នុងហ្នឹង អាហ្នឹងគេចាត់ទុកជាអ្នកទោសហើយបាទ។

**ស៖** សំណួរពាក់ព័ន្ធទៅនឹងបញ្ហានេះគឺ <ជាទូទៅ> នៅក្នុងករណីដែលថាមានមនុស្សណាម្នាក់រុកកួនផ្លូវភេទ ឬក៏ថាប្រទូសផ្លូវភេទ<មនុស្សម្នាក់ទៀត>នោះ។ តើ<>បុគ្គលតែម្នាក់ដែលប្រព្រឹត្តអំពើប្រទូសផ្លូវភេទហ្នឹង<ត្រូវជាប់ចោទពីការប្រព្រឹត្តិខុសសីលធម៌>? ឬក៏គេ<រាប់បញ្ចូលទាំង>ជនរងគ្រោះ<ដែរ>?

[១៤:២៨:០៧]

**ឆ៖** បាទនេះខ្ញុំចែកចេញជាពីរ។ ទី១ ពួកមន្ទីរដែលខូច -- អស់លោកសួរខ្ញុំពីពួកមន្ទីរខូចសីលធម៌នៅក្នុងជាមួយអ្នកទោស តែខ្ញុំអត់បានឃើញទេ ក្នុងអ្នកទោសជាមួយអ្នកមន្ទីរហ្នឹងបាទ។

**ស៖** ហើយចំណុចបន្ទាប់ -- គឺលោកនិយាយចំណុចពីរខុសៗគ្នា។ ចុះចំណុចបន្ទាប់មកទៀត?

**ឆ៖** បាទ ចំណុចបន្ទាប់មកទៀត ខ្ញុំចង់ជម្រាបអស់លោកថា ពួកកងយុវជន កងនារី ពីខាងក្រៅដែលខូចសីលធម៌ ដែលមកកងខាងក្រៅមន្ទីរហ្នឹង មិនដឹងនៅកងណាខ្លះទេ កងនៅស្រុក កងនៅតំបន់ កងឃុំគេហ្នឹង មិនដឹងកងណាជាកងណា វាមានខូចសីលធម៌ហ្នឹង គេយកមកដាក់ទោសនៅក្នុងហ្នឹង។ អាហ្នឹងកងផ្នែកយុវជន កងនារី។ តែចំពោះកង ពួកកងការពារ ឬមួយពួកនៅក្នុងហ្នឹង គឺខ្ញុំអត់ដែលមានបានឮដំណឹងថាខូចសីលធម៌ទេ។

**ស៖** តើវាមានការបញ្ជា ឬក៏សេចក្តីណែនាំណាមួយ<នៅ>ក្រាំងតាចាន់ <ដើម្បីដោះស្រាយ> ការប្រព្រឹត្តខុសសីលធម៌ដោយឆ្មាំគុក ឬដោយអ្នកធ្វើការនៅគុកហ្នឹងដែរទេ?

**ឆ៖** បាទ ចំពោះខូចសីលធម៌នៅក្នុងឆ្មាំគុក ឬក៏បញ្ជាពីអង្គការថ្នាក់លើមក គឺអត់ដែលមានទេ គឺតែខូចសីលធម៌ពិតជាខ្លួនបាត់ហើយ អត់គោរពវិន័យហ្នឹង ថាមិនដាច់ខាតជាមួយបក្ស។ បើអ៊ីចឹង បញ្ជាក់ឲ្យច្បាស់ថាក្នុងនោះ កងយុវជន កងទ័ពក៏ដោយ កងនារីក៏ដោយ គឺដាច់ខាតចំពោះបក្សអត់ឲ្យទៅខូចសីលធម៌ទេបាទ។

[១៤:៣០:១០]

**ស៖** សូមបញ្ជាក់បន្តិច គឺថា ប៉ុន្តែលោកមិនដែលឃើញករណីនេះកើតមាននៅក្រាំងតាចាន់ទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗៗ។

**ស៖** ប្រធានបទបន្ទាប់ គឺលោកបាននិយាយអំពីការសួរចម្លើយ ការប្រព្រឹត្តមកលើអ្នកទោសក្នុងពេលសួរចម្លើយ។ លោកបានឆ្លើយថាលោកពិតជាបានឃើញការធ្វើទារុណកម្មសួរចម្លើយហ្នឹង។ តើការសួរចម្លើយហ្នឹង គេសួរញឹកញាប់ប៉ុនណា ១ថ្ងៃម្តង ១អាទិត្យម្តង ឬក៏១ខែម្តង?

**ឆ៖** បាទ ក្នុងនោះ គឺក្នុងលក្ខណៈសួរចម្លើយមិនទៀតទាត់ទេ មិនថាជួនកាលព្រឹកទៅ ជួនកាលល្ងាចទៅ ជួនកាលខានទៅ នេះរកជា បានថា រកជាអចិន្ត្រៃយ៍សព្វថ្ងៃតែម្តង រាប់តែរាល់ថ្ងៃតែម្តង គឺមិនមានទេ។

**ស៖** <លោកថាមិន>សួររាល់ថ្ងៃទេ លោកឆ្លើយអ៊ីចឹង។ តែ ពេលដែលមិនមានការសួរចម្លើយនោះ តើគម្លាតនៃពេលអត់សួរចម្លើយ តើវាយូរប៉ុនណាដែរលោកធ្លាប់ចាំទេ?

**ឆ៖** បាទ ក្នុងសួរចម្លើយគម្លាតពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំអត់បានចាំទេបាទ។

**ស៖** ចន្លោះពីឆ្នាំ៧៥ ទៅដល់ដើមឆ្នាំ១៩៧៩ លោកធ្លាប់ដែលឃើញ នួន ជា ឬក៏ ខៀវ សំផន ដែរទេ?

**ឆ៖** បាទ ក្នុងនោះខ្ញុំបាទអត់ ឮតែឈ្មោះ តែរូបភាពអត់ដែលស្គាល់ទេបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ អរគុណលោកស្រីចៅក្រម។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរបន្តិចបន្តួចតែប៉ុណ្ណោះដើម្បីសួរលោកៗដើមបណ្តឹងរដ្ឋប្បវេណី។ កាលពីព្រឹកមិញ លោកបាននិយាយថានៅពេលដែលលោកបានចូលធ្វើកងទ័ព។ គេបានបញ្ជូនឲ្យលោកទៅធ្វើការនៅទំនប់មួយ<>ពេលដំបូងនោះ គឺទំនប់ខ្ពបត្របែក <បើខ្ញុំយល់មិនច្រឡំទេ>។ តើលោកធ្វើការនៅទីនោះរយៈពេលប៉ុន្មាន? ហើយមានមនុស្សប៉ុន្មាននាក់ដែរធ្វើការនៅការដ្ឋាននោះ? ហើយនៅពេលណាដែរបាទ?

[១៤:៣៣:០៦]

**លោក សូត្រ សាំង៖**

**ឆ៖** បាទ នៅធ្វើការក្នុងទំនប់ខ្ពបត្របែកនោះគឺខ្ញុំបាទអត់បានចាំឆ្នាំទេ តែបើសិនជាពលរដ្ឋប្រជាជនទូទាំងខេត្តតំបន់មួយៗ គឺខ្ពបត្របែកហ្នឹង មនុស្សរាប់ម៉ឺននាក់បាទ។

**ស៖** ខ្ញុំឮអម្បាញ់មិញនេះប្រហែលជារាប់<ម៉ឺន>នាក់ ចង់និយាយថា រាប់សិបនាក់<> ខ្ញុំស្តាប់វាមិនច្បាស់? តើលក្ខខណ្ឌការងារនៅការដ្ឋាននេះយ៉ាងម៉េចដែរ?

**ឆ៖** បាទ មនុស្សធ្វើការនៅខ្ពបត្របែក កាលខ្ញុំចាំនៅខ្ពបត្របែកនេះខ្ញុំចាំអត់បានទេឆ្នាំ តែបើសិនជាប្រជាជន ទាំងយុវជន កងនារី គឺមូលនៅក្នុងទំនប់ខ្ពបត្របែកហ្នឹងរាប់ម៉ឺននាក់ មិនមែនរាប់ពាន់ទេ រាប់ម៉ឺននាក់បាទ។

**ស៖** លោកចាំដែរឬទេ នៅពេលដែលសង់ទំនប់នោះ មានការទម្លាក់គ្រាប់បែកកាលនោះ ជាពិសេសហ្នឹងការទម្លាក់គ្រាប់បែកអាមេរិកាំងតែម្តង លោកនៅចាំថាមានការទម្លាក់គ្រាប់បែកទេកាលនោះ?

**ឆ៖** បាទ កាលនោះ ខ្ញុំទម្លាក់គ្រាប់បែកគ្រាន់តែឮទេ ខ្ញុំអត់ទាន់បានមកទេបាទ ពីព្រោះទំនប់ដែលមានលើក មិនមែនទំនប់តែមួយទេ វាមាន កាលហ្នឹងវាមានប្តូរគ្នាយុវជន។ កាលខ្ញុំនៅយុវជនហ្នឹងមានប្តូរគ្នាបាទ ប្តូរអ្នកនេះទៅ១ខែ អ្នកនោះទៅ១ខែម្នាក់ៗ មនុស្សទៅ១ខែម្នាក់អ៊ីចឹងទៅ។ បើអ៊ីចឹងប្រជាជនមួយឃុំហ្នឹងវាអាចទៅប្តូរខែគ្នាបាទ។ មួយឃុំហ្នឹងទៅលើកហ្នឹង វាមានតាមផែនការរបស់គេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដាក់មកហ្នឹង គេថាកងយុវជនគេត្រូវ១ខែម្នាក់ កងកសិករ កងនារី អ៊ីចឹង។ អាហ្នឹងគេមានតាមកងរបស់គេបាទ។

**សៈ** តើលោកមានចាំដែរឬទេថា តើមានថ្នាក់ដឹកនាំមកសម្ពោធសមិទ្ធិផល ឬក៏ការធ្វើទំនប់ហ្នឹងហើយ គេធ្វើទំនប់ហើយមានថ្នាក់ដឹកនាំចុះមកសម្ពោធដែរឬទេ?

**ឆៈ** ពីព្រោះខ្ញុំធ្វើទំនប់នេះ ខ្ញុំមិនបានធ្វើចប់បង្ហើយទេ ពីព្រោះដល់ពេល យុវជននៅទីនោះ គឺយុវជនត្រៀមចូលសមរភូមិ។ ដល់ពេលសមរភូមិ អស់យុវជនសមរភូមិមុខ គេបញ្ជូនសមរភូមិក្រោយហ្នឹង ទៅមុខហើយអត់បាននៅក្នុងហ្នឹងទៀតទេបាទ។

[១៤:៣៦:២៣]

**សៈ** តើលោកដឹងថា គេលើកទំនប់ហ្នឹងអស់រយៈពេលប៉ុន្មានដែរ ជាច្រើនអាទិត្យ ឬក៏ច្រើនខែ លោកអាចប្រាប់តុលាការបានទេ?

**ឆៈ** បាទ ក្នុងនោះឆ្នាំខែថ្ងៃ ខ្ញុំអត់ដែលបានចាំទេ។ ពីព្រោះខ្ញុំ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹងថា ខែហ្នឹងឆ្នាំខ្ញុំអត់បានចាំទេ ព្រោះគម្រោងទំនប់ហ្នឹងមិនដឹងពីឆ្នាំណា ថ្ងៃណា ខែណា ខ្ញុំអត់បានចាំទេ។ ប៉ុន្តែខ្ញុំចូលរួមលើកទំនប់ហ្នឹង ក្រោយពីលើកទំនប់ហ្នឹង ខ្ញុំបានគេបញ្ជូនទៅកងទ័ពទៅ។

**សៈ** ហើយលក្ខខណ្ឌការងារនៅការដ្ឋានហ្នឹងយ៉ាងម៉េចដែរ ការដ្ឋានហ្នឹងនៅក្នុងស្រុកត្រាំកក់ ឬក៏យ៉ាងណា? នៅក្បែរសហករណ៍ណាមួយ ឬក៏កន្លែងណាទៅឱ្យច្បាស់លាស់?

**ឆៈ** បាទ នៅក្នុង គឺទំនប់ហ្នឹងនៅសព្វថ្ងៃ ប្រើប្រាស់នៅសព្វថ្ងៃទេបាទ។ គឺនៅក្នុងទំនប់ខ្ទបត្របែកហ្នឹង គេហៅឃុំអូរសារាយ បាទ នៅក្នុងឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ បាទ។

**សៈ** ហើយលក្ខខណ្ឌការងារនៅនឹងការដ្ឋានហ្នឹងយ៉ាងម៉េចដែរ? អ្នកធ្វើការនោះ គាត់មានលំនៅដ្ឋានទេ? គាត់មានអាហារគ្រប់គ្រាន់ទេ? មានវិន័យនុំងតឹងរ៉ឹងកម្រិតណាដែរ <តើនៅការដ្ឋានហ្នឹង គេរៀបចំរបៀបម៉េច?> លោកអាចជម្រាបជូនតុលាការបានទេ?

**ឆៈ** ក្នុង ខ្ញុំបាទចូលប្រឡូកក្នុងទំនប់នោះ គឺក្នុងមួយក្រុម គេនិយាយតាមក្រុម មិនមែននិយាយតាមកងទេ ក្នុងនោះគេនិយាយតាមក្រុមវិញ។ ក្នុងមួយក្រុមហ្នឹង គឺឧទាហរណ៍ថា វាកាលជំនាន់ខ្ញុំធ្វើហ្នឹងគេឱ្យកាប់គ្រឹះស្ពាន អាគ្រឹះស្ពាន ចាក់គ្រឹះស្ពានធំៗហ្នឹង។ អាហ្នឹងគេកំណត់ថ្ងៃឱ្យរួចក្នុងមួយរណ្ដៅហ្នឹង គេឱ្យ៣ថ្ងៃឱ្យហើយ។ បាទ៣ថ្ងៃឱ្យហើយ ៣ថ្ងៃមិនហើយអាហ្នឹងគេយកអប់រំកសាង។ ទាំងយប់ទាំងថ្ងៃអត់បានសម្រាកទេ។ ជីវភាពៗក៏មិនដិតដល់ ទី១ ទៀតបើឮស្វរសញ្ញាជួងកប៉ាល់ហោះ គឺត្រូវ

ក្រាបធ្វើម៉េចកុំដើរនៅឲ្យស្ងៀម ឬមួយព្រៃជិតរត់ចូលព្រៃ បាទ។

[១៤:៣៩:១២]

**ស៖** បើតាមការយល់ដឹងរបស់លោកហ្នឹង ថាមានមនុស្សស្លាប់ច្រើនលើការដ្ឋាននោះ ឬយ៉ាងណា? គាត់ស្លាប់ដោយសារខ្វះអាហារ ឬក៏ដោយសារធ្វើការហួសកម្លាំង?

**ឆ៖** បាទ នៅក្នុងទំនប់ខ្ពបត្របែកនេះ គឺការស្លាប់ ការអត់អាហារមិន -- ខ្ញុំមិនបានដឹងដែរ ពីព្រោះខ្ញុំមិនបាននៅចប់ចុងចប់ដើមទេ។ ប៉ុន្តែនៅក្នុងក្រុមខ្ញុំ មួយកងយុវជនដែលខ្ញុំរស់នៅជាមួយហ្នឹង គឺអត់មានឃើញស្អីទេបាទ។ ដល់ពេលគេបញ្ជូនខ្ញុំចេញមក ខ្ញុំលែងដឹងខាងក្រោយហើយបាទ។ ខ្ញុំទៅសមរភូមិ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធានខ្ញុំនៅសល់សំណួរពីរបីទៀត ហើយអ៊ីចឹង ខ្ញុំចង់សួរលោកប្រធានថា តើខ្ញុំត្រូវបន្តសួរទៀត ឬក៏សម្រាកសិន? ព្រោះខ្ញុំត្រូវការពេលប្រហែលជា១០នាទីទៀតលោកប្រធាន ដើម្បីបញ្ចប់ការសួរសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តឲ្យចប់ទៅ!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ លោកដើមបណ្ដឹងរដ្ឋប្បវេណី កាលនោះលោកអាយុប៉ុន្មានដែរនៅពេលដែលគេបញ្ជូនឲ្យលោកទៅធ្វើការនៅទំនប់ខ្ពបត្របែកនោះ។ លោកអាយុប៉ុន្មានដែរកាលនោះ?

**លោក ស្សុត្រ សាំង៖**

**ឆ៖** ខ្ញុំបាទក្នុងឆ្នាំហ្នឹង ខ្ញុំមិនបានចាំឆ្នាំខ្ញុំទេពីព្រោះខ្ញុំដឹងថាកាលពីឆ្នាំ៧០ មុនបាតុកម្មមុន៧០ហ្នឹងខ្ញុំបានទៅបួសដឹងថាអាយុខ្ញុំវា១៥ឆ្នាំ ហើយមកឥឡូវវាឆ្នាំហុក-- ៥៩ហើយ តែឆ្នាំនោះខ្ញុំចែកអត់បានទេ មិនដឹងឆ្នាំប៉ុន្មានទេ ប៉ុន្តែកាលនោះ១០ឆ្នាំជាងហើយ ១០ឆ្នាំ ប្រហែលជាដប់ឆ្នាំក្រាស់ដែរហើយបាទ។

**ស៖** បាទ ឥឡូវនេះយើងចូលមកពេលវេលាកន្លងមកទៀត យើងនិយាយពីការអប់រំកសាង។ ហើយ<ព្រឹកមិញនេះ>លោកនិយាយថាកាលលោកនៅភ្នំ ពេលដែលតាមរក ព្រំ សាន់ លោកត្រូវបាន

គេដាក់ទណ្ឌកម្ម គឺគេបញ្ជូនលោកឱ្យទៅទទួលការអប់រំកសាង។ អ៊ីចឹង ខ្ញុំសុំសួរលោកថា តើពាក្យថាអប់រំកសាងនេះ មានន័យថាយ៉ាងម្ដេច? ការអប់រំកសាងហ្នឹងអស់តែរយៈពេលតែមួយរសៀលទេ ឬក៏លើសហ្នឹងទៅទៀតបាទ?

**ឆ៖** បាទ កាលពីគេយកខ្ញុំទៅកសាងកាលពីគេលួចអាវុធបាត់នៅក្នុងកងទ័ព៧៥ហ្នឹង អាហ្នឹងគេកសាងតែរយៈពេលថ្ងៃរសៀលទេ ដោយសារគេឱ្យនៅកសាងខ្លួននៅក្នុងកងទ័ព -- នៅក្នុងកងដដែលទេបាទ។ ប៉ុន្តែគេយកមកការកសាង កន្លែងកងយុវជនខាងក្រៅ បាទកងយុវជនស្រុកគេខាងក្រៅនេះមិនមែននៅក្នុងជួរកងទ័ពទេ គេចោទប្រកាន់ហ្នឹងដែលថា ខ្ញុំនេះយកកាំភ្លើងប្រគល់ឱ្យ ព្រំ សាន់ ហើយខ្ញុំកាលនោះ ដូចខ្ញុំជម្រាបជូនអស់លោកថា ខ្ញុំកាលនោះខ្ញុំជំងឺគ្រុនចាញ់នៅតំបន់ភ្នំ ដល់ហើយទៅក៏វាគេដាក់ដើរធ្វើការហ្នឹង គេលួចកាំភ្លើងបាត់។ ដល់លួចកាំភ្លើងបាត់ គេមិនចោទប្រកាន់ពីរនាក់ដាក់នៅយាមគេចោទប្រកាន់កាំភ្លើងនេះ កាំភ្លើងរបស់ខ្ញុំ។ បាទ តែប៉ុណ្ណឹងទេ។

[១៤:៤៣:១៩]

**ស៖** បាទ ខ្ញុំយល់ច្បាស់ហើយរឿងហ្នឹង ក៏ប៉ុន្តែខ្ញុំចង់សួរលោកថាតើការអប់រំកសាងហ្នឹងមានន័យយ៉ាងម៉េច? ហើយខ្ញុំសួរថាគេមានដាក់ទណ្ឌកម្មលោកទេ? គេវាយដំលោកទេ? គេសួរចម្លើយលោកទេ? ខ្ញុំចង់សួរថាពេលមួយរសៀលដែលគេយកលោកទៅអប់រំកសាងហ្នឹងគេធ្វើអីលោកខ្លះ?

**ឆ៖** បាទ គេអត់បានដាក់ទណ្ឌកម្មខ្ញុំទេ។ គេគ្រាន់តែថា គេសួរបញ្ជាក់សាចុះសាឡើងពីព្រោះគេចោទខ្ញុំនេះថាក្បត់មនុស្សបដិវត្ត។ ដោយសារអ្នកឯងក្បត់បដិវត្ត ឥឡូវចាប់ពីថ្ងៃហ្នឹងទៅ អ្នកត្រូវកសាងខ្លួនឱ្យស្មោះត្រង់នឹងបក្ស បើសិនជាមិនស្មោះត្រង់នឹងបក្សទេ ប្រយ័ត្នគេបាញ់ចោលណា៎។ បាទ ហើយខ្ញុំចេះរស់នៅជាមួយកងទ័ពហ្នឹងរហូតទល់គេបញ្ជូនមកក្រាំងតាចាន់នេះដែរ។

**ស៖** បាទ ខ្ញុំយល់ថាពេលក្រោយមកហ្នឹង លោកត្រូវបានគេបញ្ជូនឱ្យធ្វើការដាំដុះផងដែរ គឺថាស្លងហើយនិងច្រូតស្រូវជាដើម។ កាលពីព្រឹកមិញលោកបាននិយាយថា លោកបានជួបនឹងមេទាហានម្នាក់មុននឹងទៅក្រាំងតាចាន់។ តើខ្ញុំយល់អ៊ីចឹងត្រូវដែរឬទេ? គឺថាលោកបានជួបមេទាហានម្នាក់មុននឹងទៅក្រាំងតាចាន់?

**ឆ៖** បាទ មុននឹងខ្ញុំចូលនៅក្រាំងតាចាន់នេះ ខ្ញុំសុំជម្រាបជូន មុននឹងមកក្រាំងតាចាន់នេះ គឺពួកប្រាំមួយនាក់ហ្នឹង គឺមានអ្នកមកមុន និងមកក្រោយ។ បើអ៊ីចឹងពួកខ្ញុំ ខ្ញុំនេះមកក្រោយគេៗ គេយកទៅអប់រំកន្លែងយុវជនកងស្រុកនៅខាងវត្តចាក់ជ្រុំ។ បាទ នៅធ្វើការនៅវត្តចាក់ជ្រុំហ្នឹង។ ដល់ពេលខែហ្នឹង

យើងទៅខែដើមឆ្នាំ ស្ទូងហើយ មិនមែនថាមិនស្ទូងទេ កាលជំនាន់នោះ កាលជំនាន់ប៉ុលពតហ្នឹង គឺគេហៅស្រូវក្រមួនស។ ស្រូវក្រមួនស គឺស្រូវលេខមួយ ទូទាំងប្រទេសតែម្តងស្រូវក្រមួនស មិនដឹងនាំ ចូលមកពីខាងណា គ្រាន់គេថាស្រូវក្រមួនសនេះ គឺស្រូវរបស់អង្គការ។ ស្រូវលេខមួយទូទាំងប្រទេស ស្រូវហ្នឹងស្រូវក្រមួនស។ ខ្ញុំដល់ពេលនេះ គេឲ្យមកស្ទូងនៅក្នុងក្រាំងតាចាន់ហ្នឹង រហូតនៅក្នុងហ្នឹងតែម្តង។

[១៤:៤៦:០៥]

**ស៖** មុននឹងទៅដល់ក្រាំងតាចាន់នោះ តើលោកបានជួបមេលោកដែលបានចេញបញ្ជាឲ្យលោកច្បាស់លាស់ណាមួយ ព្រឹកមិញលោកបាននិយាយថាលោកបានជួបកម្មាភិបាលយោធាម្នាក់ដែលថាចាប់ពីពេលនេះទៅលោកត្រូវស្មោះត្រង់ ហើយត្រូវបូជាដើម្បីបដិវត្តន៍។ តើពាក្យទាំងអស់នេះ សុទ្ធតែជាពាក្យដែលគាត់និយាយប្រាប់លោក ឬក៏យ៉ាងម៉េច? <បើដូច្នេះមែន តើវាមានន័យយ៉ាងម៉េចដែរ?>

**ឆ៖** បាទ ខ្ញុំមកពីវត្តចាក់ជ្រុំមកមានស្នាក់ការមួយ គេហៅ--មិនមែនស្នាក់ការទេ គេថា ដូចជាកន្លែង អាហ្នឹង ដូចជាជួបគាត់នៅកន្លែងស្នាក់ការមួយនៅគេហៅថា ភូមិថានទាប ឬភូមិអីទេកាលហ្នឹងភូមិថានទាបអីចឹងហើយ មេបញ្ជាការកន្លែង -- ឲ្យចាប់ ព្រំ សាន់ ហ្នឹងក៏គាត់ណែនាំ គាត់ថា "ឯងត្រូវស្មោះត្រង់ជាមួយបដិវត្តន៍ ហើយឈប់ ត្រូវប្រុងប្រយ័ត្នកុំក្បត់នឹងបដិវត្តន៍ ធ្វើអ្វីក៏ដោយស្មោះត្រង់ជូននឹងអង្គការ។ បើអីចឹងឯងចាប់ពីថ្ងៃហ្នឹងទៅ ទៅនៅជាមួយ នៅមន្ទីរនៅក្រាំងតាចាន់ហើយ"។ ដល់ហើយក៏ខ្ញុំមកជាមួយពួកខាងមន្ទីរហ្នឹងមករហូតមកនៅក្រាំងតាចាន់ហ្នឹងមក។

**ស៖** តើនៅពេលដែលលោកស្តាប់ការណែនាំគាត់ហើយនោះ លោកមានយល់ថា ចំពោះលោកនោះ លោកមិនអាចមិនគោរពបទបញ្ជាដែលនឹងគេផ្តល់មកលោកនៅពេលដែលលោកទៅធ្វើការនៅមន្ទីរក្រាំងតាចាន់ទេ។ តើអីចឹងមែនទេ លោកមានយល់អីចឹងទេ?

[១៤:៤៨:០៥]

**ឆ៖** បាទ ទៅដល់នោះ ខ្ញុំមានវិធានការមួយ ខ្ញុំនឹកឃើញថាមិនដឹងគិតធ្វើយ៉ាងម៉េចឲ្យចេញផុតពីមន្ទីរក្រាំងតាចាន់ហ្នឹង វារកគន្លឹះមិនឃើញចេះតែទ្រាំរស់នៅ – ទ្រាំរស់នៅរហូតដល់ឆ្នាំ៧៧ បាទឆ្នាំ៧៧ ក៏មានតាមួយគាត់រាប់អានជាមួយឪពុកខ្ញុំរស់នៅតាំងពីឆ្នាំ៧១នោះ គាត់ធ្វើគ្រូជាមួយ តាអាន់កាលពីជំនាន់សង្គមរាស្ត្រនិយមហ្នឹង ជាមួយ តាអាន់ ហ្នឹងក៏គាត់បាន គាត់ប្រាប់ខ្ញុំមកខ្ញុំថា ឥឡូវឯងទៅធ្វើតាមខ្ញុំ បើមិនធ្វើតាមខ្ញុំ អាហ្នឹងយើងពិតជាស្លាប់ហើយ មិនរស់ទេ។ ហើយដល់ខ្ញុំ ខ្ញុំសួរថា ធ្វើយ៉ាងម៉េចតា? ឥឡូវឯងដាក់ពាក្យរៀបចំគ្រួសារដើម្បីជម្លៀសខ្លួនចេញទៅនៅសហករណ៍ អាហ្នឹងបានបាន។

ដល់ពេលនោះ ខ្ញុំក៏សុំដាក់ពាក្យស្នើសុំទៅរៀបក្រុមគ្រួសារហ្នឹងបានចប់សព្វគ្រប់ហើយ ក៏មិនទាន់បានចាកចេញពីក្រាំងតាចាន់នៅឡើយទេ។ ទាល់តែពេលយួនបុកមកនេះ បានគេបញ្ជូនខ្ញុំចេញពីកន្លែងក្រាំងតាចាន់នេះទៅទ័ពតែម្តង។ ទៅដល់ទ័ពរួចចប់សព្វគ្រប់ហើយ ខ្ញុំនឹងក៏នឹកឃើញថា ខ្ញុំអត់មានសមត្ថភាពតតាំងជាមួយទ័ពវៀតណាមទៀតទេ ខ្ញុំសុខចិត្ត ខ្ញុំរត់ចោលជួរតែម្តង។ រត់រហូតទៅដល់៧៤ បែកទីក្រុងទៅដល់ព្រំដែនថៃ នៅគេហៅ ស្រែអង្គរដំណាក់ស្តេចនោះ អាហ្នឹងបានយួនទាន់ហ្នឹងបានវិលចូលមកស្រុកវិញបាទ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ លោកកំពុងតែនិយាយថា ដោយមានការទូន្មានពី តាចេង លោកត្រូវតែគោរពបទបញ្ជាដែលមេបញ្ជាមកទាំងអស់។ អ៊ីចឹងមែនទេ? ខ្ញុំត្រូវយល់អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ទៅគ្រប់មេបញ្ជានៅក្នុងពីពួកគេទាំងអស់ អត់មានផលិតបង្កើតដោយខ្លួនឯងទេបាទ។

[១៤:៥០:៣៧]

**ស៖** តើនៅពេលណាមួយលោកបានទទួលបញ្ជាឲ្យសម្លាប់អ្នកទោស? តើលោកធ្លាប់បញ្ជាឲ្យសម្លាប់អ្នកទោសទេ?

**ឆ៖** បាទ ក្នុងទទួលបញ្ជាសម្លាប់អ្នកទោស គឺខ្ញុំអត់បានទទួលទេ ខ្ញុំទទួលគ្រាន់បានត្រឹមតែការពារតំបន់ខាងក្រៅកុំឲ្យប្រជាជន ឬមួយបងប្អូនប្រជាជនដើរជិត ដើរបៀតតែប៉ុណ្ណឹងទេបាទ។

**ស៖** នៅពេលដែលលោកធ្វើការនៅក្រាំងតាចាន់ តើលោកធ្លាប់ឮសម្រែកអ្នកទោសដែរឬទេ បើសិនជាធ្លាប់ឮ ហេតុអ្វីក៏អ្នកទោសស្រែកយ៉ាងដូច្នេះ?

**ឆ៖** ក្នុងសម្រែកបងប្អូនអ្នកទោស មិនមែន ខ្ញុំរស់នៅទីហ្នឹងពិតជាឮហើយ។ ឮដោយសារទី១ គេវ៉ៃសួរចម្លើយនេះក៏ឮ។ អាហ្នឹងឮជាក់ស្តែងតែម្តងបាទ។

[១៤:៥២:០២]

**ស៖** មានចំណុចមួយដែលខ្ញុំយល់មិនសូវច្បាស់ តើលោកត្រូវបានតែងតាំងជាប្រធានអ្នកយាមនៅអង្គភាពអ្នកយាមហ្នឹង? តើលោកត្រូវបានតែងតាំង ឬក៏មិនត្រូវបានតែងតាំង?

**ឆ៖** បាទ គឺខ្ញុំអត់មានទៅជាប្រធានអ្នកយាមទេ គឺអ្នកយាមខាងមន្ទីរគេអ្នកចាត់ចែងទេបាទខាងពួកបក្ខជន យុវកក ឬមួយក្រុមស្នូលរបស់គេបាទ។ អាហ្នឹងគេគ្រប់គ្រងពីលើកងទ័ព។

**ស៖** អ៊ីចឹងៗលោក<មិនមានតួនាទីជាន់ខ្ពស់ គឺ>មិនមែនជាមេអ្នកយាមនៅមន្ទីរក្រាំងតាចាន់

ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗគឺមិនមែនមេប្រធានអ្នកយាមក្រាំងតាចាន់ទេ គឺខ្ញុំជាកងទ័ពបម្រើការងារក្នុងខាងក្រៅទេបាទ។

**ស៖** តើអ្នកណាជាប្រធានអ្នកយាម ដែលយាមនៅខាងក្រៅមន្ទីរក្រាំងតាចាន់?

**ឆ៖** គឺទាំងប្រាំមួយនាក់នេះបាទ គឺអត់មានប្រធានទេ។ មានតែមន្ទីរគេចាត់តាំងឲ្យយាមតែប៉ុណ្ណោះ។

**ស៖** តើលោកមានធ្លាប់ឃើញសមាជិកគណៈស្រុកមកធ្វើទស្សនកិច្ចនៅមន្ទីរក្រាំងតាចាន់ដែរទេ? បើធ្លាប់ឃើញ អ្នកណាគេខ្លះធ្លាប់មក?

**ឆ៖** បាទ ក្នុងចំពោះអ្នកធំគេមកទស្សនកិច្ចក្នុងនោះ ខ្ញុំបាទមិនបានចាំច្បាស់ទេ គឺគ្រាន់តែថាដូចជាអ្នកបម្រើការខាងក្រៅ ដូចជា តារស់ នេះមួយ, តាឃន។ នេះអាហ្នឹងដែលឃើញគាត់ចេញចូល។ តែក្រៅពីហ្នឹង ខ្ញុំបាទអត់ដែលបានឃើញទេបាទ។

[១៤:៥៤:៣៧]

**ស៖** តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ឮគេនិយាយពីមនុស្សម្នាក់ដែលឈ្មោះ ភី ដែលគាត់ហ្នឹងបុំងពៀច?

**ឆ៖** បាទ ឈ្មោះ តាភី បុំងពៀច ហ្នឹងខ្ញុំបាទឃើញតាំងពីយូរយារណាស់មកហើយ មិនមែនឃើញនៅក្នុងក្រាំងតាចាន់ទេ។ តែដល់ខ្ញុំចូលមកដល់ក្រាំងតាចាន់ហ្នឹង ខ្ញុំដូចអត់ដែលឃើញគាត់ទេបាទ។

**ស៖** តើលោកធ្លាប់ឃើញ និងធ្លាប់ឮគេនិយាយអំពីមនុស្សម្នាក់ដែលឈ្មោះ ដាំ ដែលគាត់ហ្នឹងត្រូវបានគេយកមកដាក់មន្ទីរក្រាំងតាចាន់ ដោយសារគាត់ហ្នឹងខុសសីលធម៌?

**ឆ៖** បាទ បើនិយាយពីចំពោះ តាដាំ ហ្នឹង កាលពីមុនដើមឡើយ គាត់នៅមន្ទីរហ្នឹងយូរយារណាស់មកហើយ មិនមែនទើបនឹងនៅបច្ចុប្បន្ននេះទេ តាំងពីមន្ទីរហ្នឹងកកើតមកតាំងពីឆ្នាំប៉ុន្មានៗ ខ្ញុំក៏មិនដឹងដែរ។ តែគាត់មានវិបត្តិចេញទៅមួយសា គេលែងទៅបាត់មួយសាហើយ បានក្រោយមកគាត់ខូចសីលធម៌ខាងក្រៅហ្នឹងគេយកមកដាក់មកវិញបាទ។

[១៤:៥៦:០៨]

**ស៖** អ៊ីចឹងនៅពេលដែលគាត់ត្រឡប់មកមន្ទីរក្រាំងតាចាន់វិញ គឺគាត់ក្លាយជាអ្នកទោស ហើយ

គាត់លែងជា<អ្នកធ្វើការនៅមន្ទីរក្រាំងតាចាន់>ទៀតហើយ។ ហើយចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ កាលមុនគាត់បម្រើការនៅក្នុងមន្ទីរ ដល់ក្រោយមកហ្នឹងមិនដឹងមន្ទីរហ្នឹង ខ្ញុំក្តាប់មិនជុំដែរ មិនដឹងមានរឿងហេតុអីក៏ឲ្យគាត់ចេញពីមន្ទីរ។ ដល់ក្រោយមកទៀត គាត់ខូចសីលធម៌ខាងក្រៅហ្នឹង មិនដឹងថាខូចឯណាទេ ក៏គេយកមកដាក់ក្នុងមន្ទីរហ្នឹងជាអ្នកទោសវិញ។ បាទ តែប៉ុណ្ណឹង។

**ស៖** បើតាមលោក នៅពេលដែលលោកនៅមន្ទីរក្រាំងតាចាន់នោះ តើមានរណ្តៅប៉ុន្មានដែលគេកប់សាកសព។ ហើយបើតាម<ការ>ដឹង<>របស់លោក តាមដែលអាចដឹងនោះ តើមានសាកសពប៉ុន្មាននាក់ដែរ ដែលត្រូវបានកប់នៅក្នុងរណ្តៅទាំងអស់នោះ? <ខ្ញុំមិនដឹងថាតើលោកស្តាប់ឮសំណួរខ្ញុំ ឬអត់។>

**ឆ៖** បាទ បងប្អូនជនរងគ្រោះដែលស្លាប់នៅក្នុងក្រាំងតាចាន់ហ្នឹង នឹងមិនបានជាប្រាកដថាប៉ុន្មាននាក់ ឬប៉ុន្មាននាក់ ខ្ញុំអត់ដឹងទេបាទ ប៉ុន្តែពិតជាស្លាប់នៅក្នុងទីហ្នឹងមែន។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ។ តាមបទពិសោធន៍របស់លោកនៅក្រាំងតាចាន់ ជាបទពិសោធន៍ដែលធ្វើឲ្យលោកបានបាក់ស្បាត។ តើអ្វីដែលធ្វើឲ្យលោកបាក់ស្បាតជាងគេនៅមន្ទីរក្រាំងតាចាន់នេះ ក្នុងឋានៈលោកជាអ្នកយាមនៅទីនោះ? តើមានអ្វីដែលធ្វើឲ្យលោកបាក់ស្បាតដែរឬទេ?

[១៤:៥៨:១៨]

**ឆ៖** បាទ ធ្វើឲ្យខ្ញុំបាក់ស្បាតនៅក្នុងមន្ទីរក្រាំងតាចាន់នេះ វារន្ធត់ចិត្តខ្លាំងក្លាណាស់។ ដោយ-សារវាមិនខុសពី ដូចជាឪពុកខ្ញុំ ដូចជាបងប្អូនខ្ញុំរស់នៅសុខៗត្រូវគេយកទៅវ៉ៃចោលនេះ វាអស់ៗសេចក្តីទុកចិត្តលើការរស់នៅជាមួយជនជាតិ ឬមួយជាតិសាសន៍ឯង ហើយទៅសម្លាប់ខ្លួនឯងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅក្នុងបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កម្មនេះវិញ រួមទាំងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ គឺលោក សំណាង នៅវេលាម៉ោងបី និងម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៩ នាទី ដល់ម៉ោង ១៥:២០ នាទី)*

[១៥:២០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះ គឺក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោកថ្ងៃនេះ។ សំណួរទី១របស់ខ្ញុំ គឺសួរថានៅពេលដែលលោកធ្វើការនៅក្រាំងតាចាន់ តើលោកចាំឈ្មោះស្ត្រីម្នាក់ប្រហែលម្នាក់ អ្នកទោសស្រីម្នាក់គេហៅថា យាយញ៉ៃ។ ស្គាល់ទេ?

**លោក សួត្រ សាំង៖**

**ឆ៖** បាទ គឺយាយញ៉ៃ ខ្ញុំបាទស្គាល់។

**ស៖** តើលោកអាចរៀបរាប់ឱ្យបានច្រើនបន្តិចបានទេ អំពីយាយញ៉ៃ។ តើគាត់ធ្វើអ្វីនៅឯក្រាំងតាចាន់ហ្នឹង?

[១៥:២២:១៦]

**ឆ៖** បាទ យាយញ៉ៃ នៅក្នុងក្រាំងតាចាន់ហ្នឹង គឺដំបូងឡើយ គាត់មិនមែនជាអ្នកទោសទេ។ គឺប្តីគាត់ជាអ្នកទោស។ បើអ៊ីចឹង ប្តីគាត់ហ្នឹងក៏គេចោទគាត់ថា កាលជំនាន់នោះ ខ្ញុំក៏បានសួរគាត់លេងដែរថា តើប្តីគាត់និយាយអំពីរឿងផ្គរ ហើយអត់ភ្លៀង។ ផ្គរអត់ភ្លៀងនោះបានន័យថាគេថាផ្គរអត់ភ្លៀងហ្នឹងគេ

ថា ចោទគាត់ទៅជាក្បត់បដិវត្តន៍កាលនោះ។ ដល់ពេលហើយទៅ បានក្រោយមក បានយាយញ៉ូហ្នឹងក៏គាត់យក គេដឹកនាំកូនគាត់ទាំងអស់មកនៅក្នុងក្រាំងតាចាន់នោះបាទ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោក -- ពេលហ្នឹង លោកគេឲ្យទៅធ្វើការនៅក្រាំងតាចាន់ហើយឬនៅ នៅពេលយាយញ៉ូនៅទីនុំង? ឬក៏លោកមកហ្នឹងក្រោយទេ? និយាយម៉្យាងទៀតថាតើយាយញ៉ូ ទៅនៅហ្នឹងមុនលោក ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ យាយញ៉ូ គឺគាត់នៅឆ្នាំតែមួយដូចខ្ញុំដែរ គាត់នៅ ខ្ញុំទៅមុនគាត់ បាទ។

**ស៖** ខ្ញុំយល់ហើយ។ សំណួរសួរអ៊ីចេះ អ្នកណាទៅដល់ក្រាំងតាចាន់មុនរវាងយាយញ៉ូ ហើយនិងលោក?

**ឆ៖** បាទ យាយញ៉ូ ហើយនិងខ្ញុំ ខ្ញុំបាទទៅមុនគាត់បាទ។

**ស៖** លោកមានចាំធ្លាប់បានឃើញគេសួរចម្លើយ យាយញ៉ូ ទេ?

**ឆ៖** បាទ យាយញ៉ូ ខ្ញុំបាទអត់បានឃើញគេសួរចម្លើយគាត់ទេពីព្រោះគាត់ -- ក្រោយមកខ្ញុំទៅធ្វើការនៅវាល គេសួរយ៉ាងម៉េចខ្ញុំអត់ដឹងទេ សួរចម្លើយយាយញ៉ូនោះ ពីព្រោះឃើញមកដល់ គាត់ដាំបាយធ្វើបាយនៅកន្លែងមន្ទីរក្រាំងតាចាន់អ្នកទោសនោះបាទ។

[១៥:២៤:៥៧]

**ស៖** តើនៅឯក្រាំងតាចាន់ យាយញ៉ូ ធ្វើការៗអ្វីខ្លះដែរ មានដាំស្ល ឲ្យអ្នកទោស ហើយនិងឲ្យអ្នកធ្វើការនៅគុកដែរទេ?

**ឆ៖** បាទ ចំពោះ យាយញ៉ូ គាត់ដាំបាយឲ្យអ្នកទោស តែអ្នកក្នុងមន្ទីរហ្នឹងគេប្រើគាត់លាងចានម្ដងម្កាលដែរបាទ។

**ស៖** តើលោកចាំថាតើ យាយញ៉ូ មានកូន<ៗ> នៅជាប់នៅឯក្រាំងតាចាន់ហ្នឹងដែរទេ?

**ឆ៖** បាទ យាយញ៉ូ កូនគាត់ តាមខ្ញុំដឹងកូនគាត់មានពីរមកជាមួយ បីនាក់ និងទាំងកូនគាត់ កូនស្រីច្បងបង្អស់នោះ អាហ្នឹងក៏មកដែរ។ បីនាក់ទាំងកូនមានគ្រួសារហើយ បើប្រុសៗពីរនាក់ ហ្នឹងក៏មកជាមួយ បាទ។

**ស៖** តើលោកចាំ អ្វីខ្លះដែរ និយាយអំពីកូន<ម្នាក់ដែល>រៀបការហើយនោះ តើជាកូនស្រីឬក៏យ៉ាងណា?

**ឆ៖** បាទ កូនគាត់ការហើយនោះ កូនស្រី ឈ្មោះគាត់ អ៊ីវ៉ាត់។

**ស៖** ប្រហែលអាចបញ្ហាបកប្រែ។ លោកនិយាយថាម៉េចហ្នឹង និយាយពី បានរៀបការហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ នេះ ខ្ញុំនិយាយតែកូនគាត់រៀបការមួយទេ គឺអ៊ីវ៉ាត់ ហ្នឹងគាត់មានប្ដីហើយ ចូលមកក្នុងហ្នឹងដែរបាទ។

**ស៖** លោកចាំទេ លោកដែលនិយាយទៅកាន់ឈ្មោះ វ៉ាត់ ដែរទេ ឬធ្លាប់និយាយលេងអំពីបញ្ហាអ្វីមួយជាមួយឈ្មោះ វ៉ាត់ នេះដែរទេពេលនៅក្រាំងតាចាន់នោះ?

**ឆ៖** បាទខ្ញុំបាននិយាយលេងជាមួយគាត់ លេងសើចជាមួយគាត់ ជាសឹងតែរាល់ថ្ងៃហ្នឹង ពីព្រោះធ្វើការជាមួយគាត់ ខ្ញុំធ្វើការជាមួយ គាត់ក៏ធ្វើការជាមួយខ្ញុំនៅទីនោះ ដូចជារែកដីដំបូក រែកដី រែកដាក់ដំបូកស្រែក្នុងបាតត្រពាំង បាតអី យកមកដាក់ស្រែហ្នឹង គឺខ្ញុំធ្វើជាមួយគាត់ហ្នឹងតែម្ដងបាទ។

[១៥:២៧:៤៤]

**ស៖** ពេលលោកនិយាយលេងជាមួយឈ្មោះ វ៉ាត់ លោកចាំថាលោកនិយាយអំពីអ្វីខ្លះទេ?

**ឆ៖** ក្នុងនោះខ្ញុំក៏មិនមែនថានិយាយពីបញ្ហាក្រោយពីលេងសើចអ្នកមានគ្រួសារទេ ដល់ពេលអត់គ្រួសារទៅវាយ៉ាងម៉េចៗ លេងសើចជាធម្មតាទេ អត់មានលេងសើចទៅជាស៊ីជម្រៅ ខាងរុករានគោលនយោបាយអ្វីៗគឺគ្មានទេបាទ។

**ស៖** តើត្រឹមត្រូវទេបើខ្ញុំនិយាយថា វ៉ាត់ នៅឯក្រាំងតាចាន់ ពីរឆ្នាំ ឬក៏ពីរឆ្នាំកន្លះ បើសិនជាខ្ញុំនិយាយថាអ៊ីចឹងតើត្រឹមត្រូវឬក៏អត់ទេ?

**ឆ៖** បាទ ក្នុងនោះគឺគាត់នៅ ខ្ញុំមិនចាំទេ។ ឆ្នាំ ខែ គាត់ចូលមកនៅក៏ខ្ញុំមិនដែរ ពីព្រោះវា ខ្ញុំមិនបានកត់ត្រាទុកទេបាទ។

**ស៖** សូមប៉ាន់ប្រមាណតាមដែលអាចលោកចាំបានមើល តើប៉ុន្មានឆ្នាំ ២ឆ្នាំ ឬក៏ប៉ុន្មាន?

**ឆ៖** បាទ ក្នុងនោះខ្ញុំ ឆ្នាំ ខ្ញុំមិនបានចាំទេ ប៉ុន្តែ បើគាត់ចូលមកនៅប្រហាក់ប្រហែលជាមិនក្រៅពីឆ្នាំ៧៧ ឬដើមឆ្នាំ៧៧ មិនដឹងថាឆ្នាំណាទេ ព្រោះខ្ញុំប្រហាក់ប្រហែលជិតប៉ុណ្ណឹង ពីព្រោះលក្ខណៈខ្ញុំធ្វើដី ធ្វើជី ដំបូកម្ដុំនោះវារលាយអស់ហើយ។ មិនដឹងឆ្នាំណាទេ ពីដំបូកកន្លែងហ្នឹងវាធំៗណាស់ ស្រះកន្លែងហ្នឹង ត្រពាំងអស់ហ្នឹងធំៗណាស់ បាទ រែកជីយកដកស្រែហ្នឹង ពីព្រោះតំបន់នោះគេហៅតំបន់គេឲ្យយើងធ្វើជី ឲ្យជីដាក់ស្រែគេធ្វើជីធម្មជាតិហ្នឹងគេមិនឲ្យយើងទំនេរទេ ទោះបីទំពក់គេអត់ឲ្យទំនេរដែរបាទ។

[១៥:៣០:០០]

**ស៖** ពេលលោកនិយាយលេងជាមួយ វ៉ាត់ តើលោកចាត់ទុកគាត់ជាអ្នកធ្វើការជាមួយ ឬក៏ជាមិត្តភក្តិ ឬក៏គ្រាន់តែចាត់ទុកថាដោយសារថាជាអ្នកដែលជាប់នៅក្រាំងតាចាន់ លោកកំណត់មើលថាតើលក្ខណៈនៃទំនាក់ទំនងជាមួយនឹងលោកហ្នឹង មានលក្ខណៈជារបៀបម៉េចដែរ?

**ឆ៖** បាទ លក្ខណៈគាត់រាប់អានខ្ញុំជាមិន -- ពីព្រោះគាត់វាដាច់ស្រឡះពីខ្ញុំ ខ្ញុំដាច់ស្រឡះពីគាត់ ពីព្រោះបទបញ្ញាវាខុសនឹងការលេងសើចរស់នៅក្នុងមន្ទីរបាទ លេងសើចក៏មិនមែនជាលេងសើចជាចំហទេ លេងសើចដោយសារលួចលាក់ខុសពីមន្ទីរគេ ក៏វាយើងលេងសើចវាខុសលក្ខន្តិកៈនៅក្នុងមន្ទីរគេកន្លែងដែលយើងប្តេជ្ញាជាមួយបក្ស អង្គការ ព្រោះក្រៅពីលេងសើចរបស់បក្ស ការរីកចម្រើន គេអត់ឲ្យលេងទេ។ បើអ៊ីចឹងក្នុងខ្ញុំលេងនោះជា លេងជាមិត្តភាពធម្មតាៗធ្វើមិនដឹងមិនឮអ៊ីចឹងទៅ គាត់ដល់ពេលម៉ោងគាត់ចូលទៅកន្លែងគាត់វិញ ខ្ញុំមកនៅកន្លែងខ្ញុំវិញជាការធម្មតាទេ អត់មានជាមានបញ្ហា មានគំនិតផ្សេងយ៉ាងម៉េចទេបាទ។

**ស៖** តើលោកអាចរំឭកឡើងវិញមើល តើទំនាក់ទំនងរបស់ វ៉ាត់ ជាមួយនឹងអ្នកយាមដទៃទៀត <នៅក្នុងកងរបស់លោកហ្នឹង>យ៉ាងដូចម្តេចដែរ? តើទំនាក់ទំនងរបស់ វ៉ាត់ ជាមួយអ្នកយាមដទៃទៀតវាដូចគ្នានឹងទំនាក់ទំនងជាមួយនឹងលោកដែរឬក៏អត់?

**ឆ៖** បាទ ដូចខ្ញុំជម្រាបប្រាប់អស់លោកអ៊ីចឹង ជាការធម្មតាទេ បើសិនជាកន្លែង បើសិនជាពួកមន្ទីរគេទៅជាមួយ អាហ្នឹងក៏យើងចេះតែខំធ្វើការទៅយើងកុំនិយាយអី បើសិនជាគេអត់ទៅទេ យើងនិយាយជាការធម្មតាៗអត់មានប្រកាន់ទោសអ្វូសដំណើរអីជាមួយគាត់ទេ ប៉ុន្តែគ្រាន់ថាដូចខ្ញុំជម្រាបអ៊ីចឹងពេលណាដល់ម៉ោងគេហៅទៅកន្លែងដល់ម៉ោងគេឲ្យទៅវិញ យើងយកបងប្អូនទាំងអម្បាលម៉ានហ្នឹងយកជូនពួកកន្លែងគេ បញ្ចូលក្នុងគុកគេវិញទៅ។ បាទតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ ចម្លើយរបស់លោកច្បាស់ហើយ ក៏ប៉ុន្តែសំណួររបស់ខ្ញុំហ្នឹងសួរថាតើលោកមានចាំអ្វីខ្លះដែរទេ អំពីទំនាក់ទំនងរបស់ វ៉ាត់ ជាមួយនឹងអ្នកយាមដូចជា ឌុចតូច ជីដូនមួយរបស់លោក <វ៉ាន់ សឿន> ឬក៏អ្នកយាមដទៃទៀត លោកមានចាំខ្លះដែរទេ?

[១៥:៣២:៥៨]

**ឆ៖** បាទចំពោះអ៊ីវ៉ាតនេះ ចំពោះយាយញ៉េនេះ គាត់ជាធម្មតាទេ ដូចខ្ញុំជម្រាបអស់លោកអ៊ីចឹង។ ជាការធម្មតាយ៉ាងម៉េច? បាទ មិនមែនថាខ្ញុំទៅនិយាយអំពីបញ្ហាអ្នកទោសគាត់អីចេះៗៗមួយគឺអត់ទេ

គាត់រស់នៅជាការធម្មតា ពេលណាដែលគាត់ធ្វើការអស់កម្លាំងដល់ពួកមន្ទីរគេអត់មកដូចជាមានដូងទុំ ដូចជាមានអីទៅ យើងវៃពុះឲ្យគាត់ហូបអ៊ីចឹងទៅ បើពួកមន្ទីរគេមកអាហ្នឹងជាការលួចលាក់ ជាការធម្មតាទេ ធ្វើម៉េចបើគេឃើញអាហ្នឹងជារឿងរបស់យើងដោះស្រាយជាមួយគេអ្នកមន្ទីរទៅ ថាយើងយកមកហូបជាបក្សពួកយើងទៅ បើអ៊ីចឹងគាត់ហូបជាមួយយើងដែរ វាអត់មានការថ្នាំងថ្នាក់ជាមួយគាត់ថាហេ! គាត់នេះជាយ៉ាងម៉េចមួយៗជារឿងរបស់គាត់ៗ ខ្ញុំជារឿងរបស់ខ្ញុំបាទ។

**ស៖** តើលោកធ្លាប់បានឃើញ ឬក៏ធ្លាប់បាននិយាយជាមួយ វ៉ាត់ ឬក៏ម្ដាយរបស់ វ៉ាត់ ដែរទេក្រោយឆ្នាំ១៩៧៩?

**ឆ៖** ខ្ញុំបាននិយាយលេងដូចខ្ញុំជម្រាបអស់លោកជាស្រេច ក្នុងការនិយាយលេងក្នុងទីនោះ មិនមែនចេះតែនិយាយក្រៅពីគោលការណ៍របស់បដិវត្តន៍ទេជំនាន់នោះ។ បើអ៊ីចឹងលេចឮឡើងមួយចំនួនណាក៏បដិវត្តន៍ដែរ ចំណុចលេចឮមួយណាក៏អង្គការដែរ បើអ៊ីចឹងយើងមិនអាចនិយាយអំពីបញ្ហាជំនាន់ណាមកដាក់ជាមួយបដិវត្តន៍ គឺអត់បានទេបាទ។

[១៥:៣៤:៤០]

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រហែលជាសំណួរនេះមិនច្បាស់ទេមើលទៅ សំណួរខ្ញុំសួរ ថាតើក្រោយឆ្នាំ១៩៧៩ លោកមានបាននិយាយលេងជាមួយ យាយញ៉ ឬក៏កូន<ស្រី> របស់គាត់ដែរទេ? ខ្ញុំមិនសួររឿងនៅឯក្រាំងតាចាន់ទេ សួរក្រោយឆ្នាំ១៩៧៩?

**ឆ៖** ក្រោយឆ្នាំ១៩៧៩ គឺយាយញ៉ ទាំងចែវ៉ាត់ ទាំងកូនគាត់ គឺខ្ញុំអត់ដែលបានជួបមុខគាត់ទៀតទេបាទ។

**ស៖** លោកដឹងថា យាយញ៉ ហើយនិងកូន<ស្រី>របស់គាត់ឈ្មោះ វ៉ាត់ ហ្នឹងរស់នៅឯណាទេសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំដឹងគ្រាន់តែថាគាត់រស់នៅភូមិកំណើតកើតរបស់គាត់ នៅគេហៅអី ស្រែគ្រូ។ គាត់នៅស្រែគ្រូ ប៉ុន្តែស្រែគ្រូហ្នឹងមិនដឹងនៅត្រង់ណាទេ ខ្ញុំអត់ដឹងផ្ទះគាត់ទេ ប៉ុន្តែឮដំណឹងថានៅស្រែគ្រូ។ ពីព្រោះម្ដងកូនគាត់ស្អី សុខា មិនដឹងទេ បានមកលេងផ្ទះខ្ញុំ ខ្ញុំក៏សាកសួរតាមដំណឹងសុខាហ្នឹង សុខា ក៏វាមកលេងផ្ទះខ្ញុំហ្នឹង ក៏ខ្ញុំសួរយាយយ៉ាងម៉េច ចែវ៉ាត់ហ្នឹងយ៉ាងម៉េច។ ហើយគាត់ក៏ សុខាហ្នឹងក៏ប្រាប់ថាអត់អីទេ ម៉ែគាត់សុខសប្បាយ ប៉ុន្តែគាត់ចាស់ហើយ។ ជាការធម្មតាទេ តែក្រោយមកក្នុងបច្ចុប្បន្នសព្វថ្ងៃនេះ ក៏មិនដឹងយ៉ាងម៉េចដែរបាទ។

**ស៖** សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំចង់សូមសួរឡើងវិញទៅលើប្រធានបទនេះ ប្រហែលជា១០នាទីមុនម៉ោងបួន។ ខ្ញុំដឹងថាខ្ញុំត្រូវសួរសំណួរបែបណាហើយ ក៏ប៉ុន្តែខ្ញុំសូមសួរជាអសាធារណៈលោកប្រធាន។ តើអនុញ្ញាតឬក៏អត់? <ខ្ញុំគិតថា អង្គជំនុំជម្រះដឹងថា ខ្ញុំនឹងសួរលើប្រធានបទអ្វីហើយ ថាតើខ្ញុំសួរបន្ត ឬក៏យ៉ាងណាអាស្រ័យលើការសម្រេចរបស់តុលាការ ប៉ុន្តែត្រូវសួរជាអសាធារណៈ លោកប្រធាន។>

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៧:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកមាននៅចាំ លោកមានធ្វើសកម្មភាព<ប្រាស្រ័យទាក់ទងស្រដៀងគ្នាណាមួយជាមួយនឹង>អ្នកទោសស្រី<ពីរនាក់ផ្សេង>ទៀត <>ដែលជាពេទ្យនារីនោះឈ្មោះវន, ឈ្មោះ ហាន នោះ។ តើលោកដែលមានធ្លាប់ធ្វើសកម្មភាពអីជាមួយអ្នកទាំងនេះទេ?

**លោក ស្វូត្រ សាំង៖**

**ឆ៖** បាទ នៅក្នុងអ្នកទោសដូចជា យាយហាន ហើយនិងបងអីអំមិញ បងវន ខ្ញុំអត់ស្គាល់ទេ។ ព្រោះយាយហានហ្នឹង ខ្ញុំដឹងថាគាត់មកពីពេទ្យ តែខ្ញុំមិនដែលឃើញថា ធ្វើទារុណកម្ម ធ្វើបាប ធ្វើទុក្ខទោសជាមួយគាត់ទេ ពីព្រោះ យាយហាន, យាយរ៉ាត់ ហ្នឹងធ្វើការជាមួយតែខ្ញុំទេ។ បាទ រែកដី រែកត្រពាំងរែកដីដំបូក រែកបាតត្រពាំងអីជាមួយតែខ្ញុំទេ បាទ។

**ស៖** ខ្ញុំមិនសួរឲ្យលោកជាប់ពាក់ព័ន្ធអ្វីខុសជាមួយនឹងអ្នកទោសស្រីនោះទេ។ សំណួរខ្ញុំសួរ តើលោកមាននិយាយលេងសើចដូចគ្នា <ដូច>ដែលលោកនិយាយជាមួយ យាយញ៉ៀ ហើយនិងជាមួយ រ៉ាត់ដែរទេ?

**ឆ៖** បាទ ក្នុងនោះនិយាយជាការធម្មតាដូច យាយញ៉ៀ ដូចយាយរ៉ាត់អីចឹង។ យាយហាន និង

អ៊ីរុន ហ្នឹងក៏គាត់ធម្មតាៗអ៊ីចឹង ខ្ញុំអត់មានប្រកាន់គាត់ថាយ៉ាងម៉េចទេ បាទ។

[១៥:៣៩:៤២]

**ស៖** តើទំនាក់ទំនងរវាងអ្នកយាមដទៃទៀត ជាមួយនឹង ហាន <យ៉ាងដូចម្តេចដែរ?> ហើយ <តើទំនាក់ទំនងហ្នឹងវាដូចគ្នា>ជាមួយនឹង វ៉ាត់ និងជាមួយម្តាយរបស់ វ៉ាត់ <ដែរ ឬទេ>?

**ឆ៖** បាទ ក្នុងហ្នឹងអត់មានទំនាស់ទាស់ទែងអីជាមួយនឹងខ្ញុំទេ ពីព្រោះរឿងគាត់ខុសយ៉ាងម៉េចៗ ហ្នឹងនៅលើអង្គការគេដាក់ៗបន្ទុកឱ្យគាត់ តែចំពោះខ្ញុំនិងគាត់អត់មានខុសទាស់ជាមួយខ្ញុំទេ រឿងគាត់ បាទ ប៉ុន្តែអង្វរកគាត់ថា បើរស់នៅកុំតែរត់បានហើយ ធ្វើម៉េចឱ្យរស់ទាំងអស់គ្នា។ និយាយតែប៉ុណ្ណឹងទេ អត់ដែលមាននិយាយអីក្រៅពីហ្នឹងទេ បាទ។

**ស៖** តើវាត្រឹមត្រូវទេ បើខ្ញុំនិយាយថារវាងលោក ហើយនិងអ្នកយាមដទៃទៀត ហើយនិយាយម៉្យាងទៀតគឺថា លោក និងអ្នកនិយាមដទៃទៀតជាមួយ ហាន គឺមិនមានការលំបាកអីទេ ក្នុងទំនាក់ទំនង ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ការទំនាក់ទំនងអត់មានការលំបាកអីធ្ងន់ធ្ងរទេ ពីព្រោះ ដូចខ្ញុំជម្រាបអស់លោកថា ខាងដើមហើយថា ពីព្រោះអស់ -- ដែលអ្នកជាប់ទោសទាំងអម្បាលម៉ានគេចេញឱ្យមកខាងក្រៅធ្វើការជាមួយខ្ញុំហ្នឹងគឺខ្ញុំទទួលខុសត្រូវ។ បាត់ម៉ោងណាគឺជីវិតខ្ញុំប្រគល់ជូនបដិវត្តន៍ម៉ោងហ្នឹង។ បើអ៊ីចឹង មុននឹងចូលទៅវិញ បើថាប្រាំនាក់ យកឱ្យគេទៅប្រាំនាក់ គេយកទៅកន្លែងសម្រាកសម្រាន្តគេវិញទៅ ខ្ញុំចប់រឿងហើយខ្ញុំអត់មានបញ្ហាអីជាមួយកន្លែងទៀតទេ បាទ។

**ស៖** សូមអរគុណលោកដើមបណ្តឹង។ លោកចាំអ្នកទោសស្រីម្នាក់ទៀតឈ្មោះ សិត<យ៉ែម>?

**ឆ៖** សុំៗសំណួរម្តងទៀត ខ្ញុំស្តាប់អត់បានទេ បាទ។

**លោក សុន អរុណ៖**

ឈ្មោះ សែត យ៉ែម។

**លោក ស្ទូត្រ សាំង៖**

**ឆ៖** ឈ្មោះនេះ ខ្ញុំបាទអត់បានស្គាល់ផងបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកចាំអ្នកទោសនៅក្រាំងតាចាន់ដែលនៅមុនឆ្នាំ១៩៧៥ ជាតារាភាពយន្តទេ? លោកធ្លាប់ចាំទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ជាតារាភាពយន្ត ខ្ញុំអត់បានចាំទេ ពីមុនមក មុន៧៥។ ៧៥-៧៦ ក៏ខ្ញុំអត់បានដឹងដែរ បាទ។

[១៥:៤៣:២៣]

**ស៖** បើសិនជានិយាយឈ្មោះតួកុនឈ្មោះ គីម ណូវ៉ា និងឈ្មោះ ណុប ណែម។ តើលោកនឹកឃើញទេ?

**ឆ៖** បាទ បើនិយាយពីតួកុន ណុប ណែម, គីម ណូវ៉ា ហ្នឹង ឃើញតែក្នុងរូបកុន តែគ្រាន់តែរូបភាពគាត់ខាងក្រៅ ក្រោយមកខ្ញុំអត់ដែលស្គាល់ទេ។ ឃើញតែក្នុងកុន បាទ ខ្ញុំបានមើលកុនដែរតើ ឃើញរូបភាពគាត់ ប៉ុន្តែរឿងយកមកជាប់គុកក្នុងក្រាំតាចាន់ហ្នឹង ខ្ញុំអត់បានដឹងទេបាទ។

**ស៖** ដូច្នេះ លោកមិនដែលឃើញតារាភាពយន្តទាំងពីរនេះទេ ហើយលោកក៏មិនដែលឮថា អ្នក -- តួកុនទាំងពីរនេះ អាចត្រូវបានគេឃុំឃាំងនៅក្រាំងតាចាន់។ លោកមិនធ្លាប់ដែលឮទេហ្អី?

**ឆ៖** បាទ អត់បានធ្លាប់ដឹងឮទេបាទ។

**ស៖** ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងម៉ាញ៉េ។ ប្រសិនជាអាចនោះ ខ្ញុំនឹងសុំការអនុញ្ញាតពីតុលាការ។ លោក១បង្ហាញជាដៃមើលថា តើម៉ាញ៉េហ្នឹងវាប៉ុនណាដែរ? ធំប៉ុនណា តូចប៉ុនណាដែរ? គឺម៉ាញ៉េដែលលោកបានឆ្លើយមុននេះ?

**ឆ៖** បាទម៉ាញ៉េនោះ គឺកាលជំនាន់នោះមិនមានថ្មឯណាប្រើទេ គេប្រើអាគុយ៦វ៉ុលយើង ហ្នឹង បាទ អាគុយ៦វ៉ុល មិនមែនអាគុយចេញដូចឥឡូវទេ។ អាគុយ៦វ៉ុលជំនាន់នោះ គឺអាគុយវាបចាក់តែតួក្បាលពីលើបាទ។ ដល់ពេលហើយ ម៉ាញ៉េនោះវាប្រើតែតែតមួយ តែតែតចម្រៀងមិនជា -- ម៉ាញ៉េហ្នឹង ទំហំវាប្រហែលជា យើងស្មានប្រហែលជា៥តឹកទេ បាទ អាម៉ាញ៉េហ្នឹងប្រហែលជា៥តឹកទេ កម្ពស់វាប្រហែលជា២តឹកអីហ្នឹងបើតាមមើលម៉ាញ៉េហ្នឹង។ អាហ្នឹងកាលគេហៅម៉ាញ៉េហ្នឹងដូចពួក អាណាស្សូ-ណាល់ម៉េចមិនដឹងទេបាទ អាហ្នឹងមានមែន ក្នុងហ្នឹងខ្ញុំដឹងថាមានមែន ពីព្រោះខ្ញុំបានចាក់ដែរក្នុងហ្នឹង មិនមែនថាអត់ទេ។ ប៉ុន្តែចាក់ចម្រៀងហៅថា ចម្រៀងកសិករ ថ្ងៃត្រង់ដូចយើងសម្រាកសម្រាន្តម៉ោងនេះហ្នឹង ងូតទឹកងូតអីហ្នឹង យើងចាក់លេងធម្មតាទេ មិនមែនចាក់មានផ្លូវការអ្វីទេបាទ។

[១៥:៤៦:២៦]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកឃើញហើយនៅទល់មុខលោកហ្នឹងគឺមានកុំព្យូទ័រនៅអេក្រង់កុំព្យូទ័រពីខាងមុខ លោកអាចប្រៀបធៀបរវាងអេក្រង់កុំព្យូទ័រហ្នឹងទៅនឹងម៉ាញ៉េនៅក្រាំងតាចាន់

តើម៉ាញ៉េនៅក្រាំងតាចាន់វាតូចជាងអេក្រង់កុំព្យូទ័រនេះ មុខលោកនេះ ឬក៏វាធំជាង លោកអាចធ្វើការប្រៀបធៀបជាមួយនឹងកុំព្យូទ័រនៅមុខលោកនេះបានទេ?

**ឆ៖** បាទ ក្នុងម៉ាញ៉េនោះ គឺបើកម្ពស់វាទាបជាង បើការស្មាន បើកម្ពស់ពីលើក្រោមអាហ្នឹងវាអាចទាបជាង តែបើមកខាងអាហ្នឹងវាអាចប៉ុនកុំព្យូទ័រខាងមុខបាទ។

**ស៖** តើវាត្រឹមត្រូវដែរទេ ដែលថាសំឡេងវាចេញមកពីម៉ាញ៉េហ្នឹងផ្ទាល់តែម្តង គឺមិនបានភ្ជាប់ទៅស្ពីទៀតទេ។ តើអ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺម៉ាញ៉េហ្នឹងចាក់លេងជាការធម្មតា វាដូច -- អានេះ គេថាមិនជាផ្លូវការអីទេ គ្រាន់តែយើងចាក់លេងជាការធម្មតា កំសាន្តលេងជាការធម្មតា មិនមែនចេះតែយកទៅលក្ខណ:ថា បង្វែរបង្វិលទៅជាបំព្រួញសំឡេង ឬបំប៉ោងសំឡេងនោះគឺមិនមែនទេបាទ។

**ស៖** ខ្ញុំយល់ថាចម្លើយរបស់លោកច្បាស់ហើយ។ ប៉ុន្តែដើម្បីធានាឲ្យវាប្រាកដប្រជាថែមទៀតនោះ តើគេមានតខ្សែចេញពីម៉ាញ៉េហ្នឹងដើម្បីភ្ជាប់ទៅជាមួយនឹងធុងបាសអំភ្លីអីណាផ្សេងទៀតទេ?

**ឆ៖** ខ្ញុំជម្រាបលោកដោយត្រង់ស្មោះថា លក្ខណ:តខ្សែៗពីព្រោះថ្មវាអត់មានអូសកាសែតរួចទេ គឺគេតខ្សែចេញពីអាក្បាលអាគុយចូលទៅម៉ាញ៉េហ្នឹងតែម្តង។ ពីព្រោះយកភ្លើងពីអាគុយទៅចូលម៉ាញ៉េបានវាឮបាន តែប៉ុណ្ណឹងទេ។ អត់មានខ្សែចេញទៅមីក្រូ អូខេ ឯណា បាសតូច បាសធំអីទៀតទេបាទ គ្មានទេ។

[១៥:៤៩:១១]

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅសល់តែ១០នាទីទៀតទេដល់ម៉ោងបួនហើយ។ លោកប្រធានដល់ពេលដែលខ្ញុំសួរសំណួរដូចដែលខ្ញុំបានស្នើសុំ ស្នើសុំធ្វើសវនាការអសាធារណ:។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវអង្គជំនុំជម្រះបានយល់ព្រម ហើយនិងអនុញ្ញាតឲ្យធ្វើផ្នែកចុងក្រោយ ចុងម៉ោងនេះជាអសាធារណ:។ ដូច្នេះ ខាងមន្ត្រីរៀបចំតុលាការសម្របសម្រួលរៀបចំនូវប្រព័ន្ធដើម្បីឲ្យសមស្របទៅនឹងដំណើរការសវនាការជាអសាធារណ: ហើយនិងនៅក្នុងកិច្ចដំណើរការសវនាការអសាធារណ:នេះ អង្គជំនុំជម្រះ ទី១បង្គាប់ឲ្យផ្តាច់ប្រព័ន្ធសំឡេង និងរូបភាពចេញទៅសាធារណជន ហើយបញ្ជាទី២

គឺអង្គជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនេះ នៅចូលរួមសវនាការដដែល ក្នុងនាមជាភាគី ប៉ុន្តែសូមឲ្យរក្សានូវព័ត៌មាន កុំបាច់ចែករំលែកនូវព័ត៌មានដែលបានស្ដាប់នៅក្នុងអំឡុងពេលសវនាការអសាធារណៈនេះទៅបុគ្គលណាមួយដទៃទៀតឡើយ។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ បើសិនជាអង្គជំនុំជម្រះសម្រេចឲ្យមានសវនាការជាអសាធារណៈបែបនេះ តើយើងអាចស្នើសុំថាកុំបាច់បំលែងសំឡេងបានទេ ព្រោះកន្លែងមកលោក ខៀវ សំផន ក៏មានបញ្ហាក្នុងការស្ដាប់សំឡេងហ្នឹងវាអត់សូវច្បាស់ដែរបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងហើយយើងបានចំណាយពេលរយៈពេលខ្លីមួយសម្រាប់ឲ្យខាងមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលខាងផ្នែកបច្ចេកទេសនេះឲ្យវាសមស្របក្នុងការធ្វើសវនាការអសាធារណៈវិញ លែងទៅធ្វើសវនាការបំលែងសំឡេងនិងរូបភាពទៀតហើយ ព្រោះផ្ដាច់ប្រព័ន្ធទៅខាងក្រៅហើយ ផ្ដាច់សំឡេងហើយនិងផ្ដាច់រូបភាពទៅខាងក្រៅហើយ។ ប៉ុន្តែគេកំពុង គេត្រូវការ ព្រោះត្រូវការពេលវេលា។ អ៊ីចឹងហើយបានយើងប្រាប់អម្បាញ់មិញនេះ។

*(សវនាការសាធារណៈផ្អាកនៅម៉ោង ១៥:៥១នាទី)*

*(សវនាការបន្តធ្វើជាអសាធារណៈវិញ)*